ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Nov-2012, 15:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី១២៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

លោក ស៊ីម៉ុន មេសិនប៊ឺជ

*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់

(*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោកស្រី នូស៊ីន សាការ៉ាទី

*(Ms. Nushin SAKARATI)*

លោក សំ សុគង់

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោក ប៉ាស្កាល់ អូប៊ីង

*(Mr. Pascal AUBOUIN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា សុង ឆវិន្ត | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្ដើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោកស្រី នូស៊ីន សាកាវ៉ាទី | អង់គ្លេស |
| លោក ស៊ុំ ជា (TCW-690) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ុំ ជា ហៅ ជា** (TCW-690)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ ២
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី៖ ........ ទំព័រ ៦
សួរដោយលោក ឌេល លីសាក់ ផ្តើមពី៖ ........ ទំព័រ ១៥
សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី៖ ........ ទំព័រ ៣៦
សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី ផ្តើមពី៖ ........ ទំព័រ ៤៤
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ ៤៩
សួរដោយលោក សុន អរុណ ផ្តើមពី៖ ........ ទំព័រ ៥៤
សួរដោយលោក ហ្សាស្តេី ប៉ៅ ផ្តើមពី៖ ........ ទំព័រ ៥៩
សួរដោយលោក ម៉ៃខល កាណាវាស ផ្តើមពី៖ ........ ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:១៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះតាមកាលវិភាគដែលបានគ្រោងទុកអង្គជំនុំជម្រះនឹងដំណើរការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-690។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! ក្នុងសវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយសារមូលហេតុសុខភាព និងបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ប៉ុន្តែយោងតាមពាក្យសុំលះបង់សិទ្ធិមានវត្តមានដែនកំណត់របស់ខ្លួន តាមរយៈឯកសារ E237 ជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការនៃការស្ដាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-690 និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-89 ដែលត្រូវបានកោះហៅមកនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃនេះ។ សាក្សីដែលត្រូវផ្ដល់សក្ខីកម្មដែលមានរហស្សនាម TCW-690 មានវត្តមានរួចជាស្រេច រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងនេះនោះទេ។ សាក្សីរូបនេះបានធ្វើសម្បថចំពោះមុខរូបលោកតាដំបងដែកកាលពីព្រឹកមិញរួចហើយ។

ចំពោះមេធាវីអន្តរជាតិរបស់ក្រុមលោក ខៀវ សំផន នឹងមានវត្តមានដោយមកយឺតបន្តិច។

សូមអរគុណលោកប្រធាន។

[០៩:០៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទអៀង សារី ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ ឯកសារ E237 តាមរយៈមេធាវីការពារក្ដីរបស់គាត់។ គាត់សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ស្ដាប់សក្ខីកម្មសាក្សីចំនួន ១០រូប និងដើមបណ្ដឹងរដ្ឋប្បវេណី ៦រូប។ ក្នុងចំណោមសាក្សីចំនួន ១០រូប ក៏មានឈ្មោះសាក្សីដែលមានរហស្សនាម TCW-690 ម្នាក់ផងដែរ។ យោងតាមរបាយ-ការណ៍គ្រូពេទ្យនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលទទួលព្យាបាលលោក អៀង សារី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ បានបញ្ជាក់ថា លោក អៀង សារី បច្ចុប្បន្នកំពុងតែសម្រាកទទួលការព្យាបាលនៅផ្នែកជំងឺទូទៅនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ នៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនការពិភាក្សាដេញដោល ស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដោយមានដែនកំណត់ ដែលគាត់មានបញ្ហាសុខភាពត្រូវសម្រាក ដើម្បីទទួលការព្យាបាលនៅមន្ទីរពេទ្យ តែរូបកាយនិងស្មារតីសមស្រប។

អង្គជំនុំជម្រះសាលាដំបូងសម្រេចធ្វើសវនាការស្ដាប់សក្ខីកម្មដែលមានរហស្សនាម TCW-690 ដោយមិនវត្តមានលោក អៀង សារី ដែលអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលបានចែងថា នៅពេលដែលមានមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែរូបកាយនិងបញ្ញាស្មារតីសមស្របអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តនីតិវិធីដោយមិនមានវត្តមានជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-690 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលមកក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក ស៊ុំ ជា៖**

**ឆ៖** ខ្ញុំឈ្មោះ ស៊ុំ ជា។

**ស៖** បាទ អរគុណលោក ស៊ុំ ជា។ ហើយក្រៅពីឈ្មោះ ស៊ុំ ជា តើលោកធ្លាប់ប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ? មានឈ្មោះហៅក្រៅទេ?

**ឆ៖** អត់ទេ។

**ស៖** អរគុណលោក ស៊ុំ ជា។ ហើយតើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** បច្ចុប្បន្ននេះ ខ្ញុំ ៥៩ឆ្នាំហើយ។

**ស៖** អរគុណលោក ស៊ុំ ជា។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំពីដើមកើតនៅភូមិបឹងណាយ សង្កាត់បឹងណាយ ស្រុកព្រៃឈរ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្ននេះគឺរស់នៅ ភូមិវាល សង្កាត់សំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ហើយតើលោក ស៊ុំ ជា លោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ធ្វើស្រែ កាត់សក់ ធ្វើប្រាំង។

[០៩:០៨:៣៣]

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ វាល់ ស៊ុំ។ ម្តាយឈ្មោះ ជឹម ស៊ី។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ប្រាក់ សំអាត។ អត់មានកូន ស៊ុំកូនគេមួយមក។

**ស៖** លោក ស៊ុំ ជា តើលោកចេះអក្សរខ្មែរដែរឬទេ?

**ឆ៖** ចេះដែរ ប៉ុន្តែចេះតិចៗ។

**ស៖** បាទ អរគុណ។ ហើយលោក ស៊ុំ ជា តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គល ដែលត្រូវទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តី០០២នេះទេ។ ហើយក៏ពុំជាប់ជាញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបដែរ គឺលោក នួន ជា, លោក អៀង សារី និងលោក ខៀវ សំផន។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** ហើយទន្ទឹមនឹងដែរ ក្រឡាបញ្ជីបានរាយការណ៍ថា លោកបានធ្វើ -- បានស្បថរួចហើយ នៅមុខអ្នកតាដំបងដែក មុននឹងលោកចូលមកកាន់បន្ទប់ផ្តល់សក្ខីកម្មនេះ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ បានស្បថរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងនាមលោកជាសាក្សីចូលរួមនៅក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ លោក ស៊ុំ ជា ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ ហើយដែលនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

[០៩:១១:០៣]

ករណីយកិច្ច លោក ស៊ុំ ជា ក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែករណីឆ្លើយតបនឹងសំណួរ ឬអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

លោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដោយភាគី ឬចៅក្រមអង្គជំនុំជម្រះសួរ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ស៊ុំ ជា តើលោកមានដែលបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក?

[០៩:១២:០៤]

**លោក ស៊ុំ ជា៖**

**ឆ៖** បាទ ដែលបាន។

**ស៖** ធ្វើផ្តល់កិច្ចសម្ភាសន៍ -- ការសម្ភាសហ្នឹងប៉ុន្មានលើក? ហើយនៅកន្លែងណា?

**ឆ៖** សម្ភាសបានមួយលើក និង បានមួយលើក។

**ស៖** លោកចាំទេថា ធ្វើហ្នឹងនៅពេលណាដែរ?

**ឆ៖** ភ្លេចទៅហើយ ភ្លេចថ្ងៃខែ ៣, ៤, ៥ឆ្នាំហើយ។

**ស៖** ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានស្តាប់អ្នក -- បុគ្គលណាម្នាក់អាននូវកំណត់ហេតុស្តាប់ចម្លើយ ដែលលោកបានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍លើកមុនហ្នឹងឲ្យលោកស្តាប់រំឭកការចងចាំដែរឬទេ?

**ឆ៖** បានស្តាប់ហើយ។

[០៩:១៣:១៦]

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងលោកចាំ ថាតើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុដែលលោកបានស្តាប់ការអានឲ្យស្តាប់ ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយរបស់លោកបានផ្តល់សម្ភាសកាលពីលើកមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដអ៊ីចឹងមែន បានឯកភាពហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី។

[០៩:១៤:០៧]

ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា តំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ ក្នុងការសួរសាក្សីរូបនេះ គឺតែមួយព្រឹកនេះទេ សូមជ្រាប។ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពដល់លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅក្នុងសវនាការនេះ ហើយក៏សូមសួស្តីផងដែរទៅលោក ស៊ុំ ជា។

មុននឹងចាប់ផ្តើមសួរសំណួរទៅលោកសាក្សី ស៊ុំ ជា ខ្ញុំសូមអនុញ្ញាតទៅលោកប្រធាន ដើម្បីផ្តល់ជូននូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកសាក្សីឈ្មោះ ស៊ុំ ជា ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលេខឯកសារគឺ D94/9 និងសូមអនុញ្ញាតផងដែរដើម្បីដាក់បង្ហាញឯកសារ។

**ប្រធានអង្គជំនុំ៖**

ទំនងជាតាមយើងបានទទួលព័ត៌មាន ហើយបានសួរបញ្ជាក់គាត់អំមិញ គាត់មិនចេះអក្សរទេ។ គាត់ចេះតិចតួចបំផុត អ៊ីចឹងដូចទំនងជាមិនមានប្រយោជន៍អ្វីទេ នៅក្នុងការជូនឯកសារជាក្រដាសជូនទៅសាក្សីដើម្បីអានបញ្ជាក់នោះ។ សូមតំណាងសហព្រះរាជអាជ្ញាពិនិត្យបញ្ហានេះ ហើយតាំងសំណួរដេញដោលតែម្តង។ នេះជាការសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃសាក្សី។ អ៊ីចឹងហើយបានជាយើងបានបញ្ជាក់ សួរបញ្ជាក់ទៅគាត់អំពីសមត្ថភាពនៃការរៀនសូត្រ កម្រិតយល់ដឹងអំពីភាសាខ្មែរនេះ គឺគាត់បានបង្ហាញថា គាត់មិនចេះទេ។ ចេះតិចតួចបំផុត ដែលមិនអាចអាននូវខ្លឹមសារនៃឯកសារដែលមានបំណងជូននេះបានទេ។ យើងអនុញ្ញាតឲ្យដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ ក្នុងករណីត្រូវប្រើប្រាស់។

[០៩:១៦:៣០]

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សួស្តីលោកសាក្សី ស៊ុំ ជា នាងខ្ញុំមានសំណួរមួយចំនួនចង់សាកសួរទៅលោក ហើយសំណួរទី១ របស់ខ្ញុំចង់សួរទៅលោក ចង់ដឹងថា តើលោកបានធ្វើជាទាហានខ្មែរក្រហមនោះ គឺចាប់ផ្តើមនៅឆ្នាំណាដែរ?

**លោក ស៊ុំ ជា៖**

**ឆ៖** បាទ ខ្ញុំធ្វើទាហានខ្មែរក្រហម គឺឆ្នាំ៧២។

**ស៖** ចាស អរគុណ។ ហើយក៏ចង់សួរលោកដែរថា ហេតុអ្វីបានជាពេលនោះលោកចាប់ផ្តើមធ្វើជាទាហានខ្មែរក្រហម?

[០៩:១៧:០៤]

**ឆ៖** ដោយសម្តេច សីហនុ ស្រែកហៅឲ្យចូលព្រៃម៉ាគី បានជាខ្ញុំចូលជាខ្មែរក្រហម។

**ស៖** តើកាលដែលលោកចូលធ្វើជាទាហានខ្មែរក្រហម លោកចូលដោយស្ម័គ្រចិត្ត ឬក៏មានការណែនាំ ឬមានការបង្ខំពីអ្នកណាដែរ?

**ឆ៖** ចូលតាមស្ម័គ្រចិត្ត។

**ស៖** លោកថា លោកបានចូលធ្វើជាទាហានខ្មែរក្រហមគឺនៅក្នុងឆ្នាំ៧២ អ៊ីចឹងពេលដែលលោកចូលធ្វើជាទាហានខ្មែរក្រហមដំបូងហ្នឹង តើលោកស្ថិតនៅក្នុងកងពលណា?

**ឆ៖** ខ្ញុំចូលក្នុងកងពលទី១។

[០៩:១៨:០៩]

**ស៖** តើកងពលរបស់លោកឈរជើងនៅកន្លែងណាដែរ ចាំបានទេពេលនោះ?

**ឆ៖** ខ្ញុំឈរជើងនៅបឹងណាយ។ បឹងណាយនៅស្រុកភូមិតែម្តង។ កងពលនុ៎ងឈ្មោះ វឿង ៗ។

**ស៖** ឈ្មោះ វឿង ជាមេកងពល ឬក៏ជាអ្នកណា? គាត់មានតួនាទីធ្វើអ្វីដែរ?

**ឆ៖** ជាកងពល។

**ស៖** លោកចាំបានទេថា នៅក្នុងកងពលលេខ១នោះ មានទាហានចំនួនប៉ុន្មាននាក់នៅក្នុងកងពលមួយៗហ្នឹង?

**ឆ៖** ជំនាន់នុ៎ងកងពលមិនទាន់រៀបចំឲ្យបាន ពីព្រោះអត់ស្គរមានទ័ពចូល អត់ទាន់គ្រប់។

**ស៖** លោកសាក្សី ខ្ញុំសូមនាំលោកទៅកាន់កំណត់ហេតុស្តាប់ចម្លើយដែលលោកបានធ្វើជាមួយនឹងសហចៅក្រមស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបសួរ ដែលចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០០៨ ដែលមានលេខឯកសារ D94/9, ត្រង់ ERN ជាភាសាខ្មែរគឺលេខ 00205057, និង ERN ជាភាសាអង់គ្លេសគឺលេខ 00223345, និង ERN ជាភាសាបារាំង គឺលេខ 00705376។ នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកថា “តើនៅជិតបែកភ្នំពេញ ថ្ងៃ១៧ មេសា ៧៥ ទ័ពរបស់លោកឈរជើងនៅឯណា?” ពេលនោះលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា ដកស្រង់ “ទ័ពខ្ញុំវាយនៅបាសិត”។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោក សួរថា តើទ័ពខ្មែរក្រហម គឺកងពលលេខ១ ដែលលោកនៅក្នុងនោះចាប់ផ្តើមវាយបាសិតពីពេលណា?

**ឆ៖** ភ្លេចខែថ្ងៃហើយ ប៉ុន្តែឈរជើងនៅបាសិត។

[០៩:២១:១៣]

**ស៖** អ៊ីចឹងលោកឈរជើងនៅបាសិតប្រហែលជាប៉ុន្មានឆ្នាំ បានមានវាយមកភ្នំពេញដែរឬទេ?

**ឆ៖** ឈរជើងប្រហែលជាល្បាក់ ២ខែ វ៉ៃដាច់បាសិតចូលភ្នំពេញ។

**ស៖** លោកថា លោកឈរជើងនៅបាសិតប្រហែលជា១២ខែ បានចាប់ -- ២ខែ។ ចាស សូមអរគុណ។ អ៊ីចឹង២ខែ នៅបាសិត ហើយចាប់ផ្ដើមវាយចូលមកភ្នំពេញ។ លោកចាំទេថា ចាប់ផ្ដើមវាយចូលភ្នំពេញហ្នឹង វាយដំបូងហ្នឹងមកតាមច្រកណា? ហើយមានកងពលប្រហែលជាប៉ុន្មាននាក់ពេលនោះ?

**ឆ៖** វ៉ៃមិនដឹងជាប៉ុន្មានកងពល ប៉ុន្តែដឹងថាកងពលទី១របស់ តារឿង ហ្នឹង។ វាច្រើនកងពល។

**ស៖** តែចង់ដឹងថា នៅក្នុងកងពលលេខ១ ដែលលោកឈរជើងហ្នឹង មានសមាជិកប្រហែលជាប៉ុន្មាននាក់? ហើយពេលវាយចូលភ្នំពេញហ្នឹង គឺមកតាមច្រកណា? មានទិសដៅពីណាទៅណាដែរលោកចាំបានទេពេលនោះ?

**ឆ៖** ខ្ញុំនៅឈរវ៉ៃខាងៗជើងបាសិត អ៎! ខាងត្បូងបាសិត។

**ស៖** វាយ ទៅឈរខាងត្បូងបាសិតឆ្ពោះមកភ្នំពេញ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:២៣:១៩]

**ស៖** អ៊ីចឹងពេលដែលឡើងមកខាងត្បូងបាសិត ហើយឆ្ពោះមកភ្នំពេញហ្នឹង លោកចាំទេថា មកតាមផ្លូវណា? ច្រកណា?

**ឆ៖** កាលនុ៎ង ទាហានអ្នករត់មកទាំងយប់ ហើយកាត់វាល ទើបមកទៅលើឃ្មួញ និងត្រឡោកបែក។

**ស៖** ចាស សូមអរគុណ។ ហើយនៅត្រង់ ENR ដដែល ដែលលោកបានបន្តឆ្លើយថា បន្ទាប់មកវាយចូលភ្នំពេញ តាមច្រកឃ្មួញ ហើយចូលដល់ទីក្រុងភ្នំពេញតាមផ្លូវត្រឡោកបែក ផ្លូវរទេះភ្លើង។ ហើយឃើញមានកាំភ្លើងរប៉ាត់រប៉ាយតាមថ្នល់ ហើយក៏មានអ្នកកាន់ទង់ជ័យ-ស និងមានប្រជាជនដើរពេញផ្លូវ ហាក់ដូចជាច្របូកច្របល់ណាស់ពេលនោះ។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោក សួរថា តើក្រុមមនុស្សដែលកាន់ទង់ជ័យ-ស ដែលលោកនិយាយរៀបរាប់ប្រាប់អ្នកស៊ើបអង្កេតនោះ ពួកគាត់ជាប្រជាជនស៊ីវិល ឬជាទាហាន លន់ នល់ ឬក៏ទាំងពីរតែម្ដង?

[០៩:២៤:៤៥]

**ធ៖** មិនដឹងជាខាងណាៗ បើកឡើងទៅឃើញតែទង់ជ័យ-ស។ ទាំងប្រជាជន រឿងទាហាន រឿងអីបាត់ឈឹងមិនដឹង ខោអាវ ឃើញកាំភ្លើងនៅរាយប៉ាយនៅតាមថ្នល់។

**ស៖** អ៊ីចឹងអ្នកដែលកាន់ទង់ជ័យ-សហ្នឹង តើខ្ញុំយល់ជាការត្រឹមត្រូវទេលោកសំដៅថាទាំងប្រជាជនស៊ីវិល និងទាហាន លន់ នល់ ផងដែរនោះ?

**ធ៖** បាទ ត្រឹមត្រូវ។

**ស៖** អ៊ីចឹងពេលដែលទាហានខ្មែរក្រហមចូលមកដល់ភ្នំពេញ គឺទ័ពកងពលលេខ១របស់លោកវ៉ៃចូលមកដល់ភ្នំពេញហ្នឹង លោកចាំបានទេថា ចូលមកដល់នៅថ្ងៃខែឆ្នាំណា?

**ធ៖** ចូល៧៥ ប៉ុន្តែមិនដឹងថ្ងៃខែ ថ្ងៃណា ភ្លេចបាត់ហើយ។

**ស៖** នៅពេលដែលទ័ពខ្មែរក្រហមបានចូលមកដល់ភ្នំពេញភ្លាមក្នុងឆ្នាំ៧៥ ហ្នឹង តើទាហានខ្មែរក្រហមបានធ្វើដូចម្តេចចំពោះអ្នកដែលកាន់ទង់ជ័យ-ស ដែលលោកបានរៀបរាប់ពីមុននោះ?

**ធ៖** ទាហានខ្មែរក្រហមគ្រាន់តែចូលមកដល់ ឲ្យប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញចំនួន ៥ថ្ងៃ ធ្វើម៉េចចេញឲ្យផុត។ ហើយបើអ្នកណាមិនចេញ កងពលគេថាធ្វើម៉េចឲ្យតែបានចេញទៅ។

[០៩:២៦:៥២]

**ស៖** ទាហានខ្មែរក្រហមនៅពេលដែលចូលដល់ក្រុងភ្នំពេញ បានប្រាប់ប្រជាជនឲ្យជម្លៀសចេញពីក្រុងភ្នំពេញ។ អ៊ីចឹងសួរថា តើទាហានខ្មែរក្រហមបានទទួលបញ្ជាពីអ្នកណាដើម្បីឲ្យជម្លៀសប្រជាជនភ្នំពេញ -- ប្រជាជននៅក្នុងភ្នំពេញចេញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងក្នុង ទាំងក្រៅបន្ទប់សវនាការ។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការតាំងសំណួរនេះ ដោយសារតំណាងសហព្រះរាជអាជ្ញាបានសួរអំពីទាហានខ្មែរក្រហម ហើយនិងកងទ័ពខ្មែរក្រហមជាទូទៅ គឺថាទាហានដទៃទៀតក៏មានប្រតិបត្តិការនៅកន្លែងផ្សេងៗគ្នានោះផងដែរ ដែលតាមរយៈបទពិសោធន៍ពីយោធាអង្គភាពផ្សេងៗ ហើយបទពិសោធន៍របស់ប្រជាជន គឺវាអាស្រ័យទៅលើថាតើទាហានរូបនេះគាត់ធ្វើប្រតិបត្តិការពេល

នោះនៅកន្លែងណា? ខ្ញុំមិនជំទាស់ទៅនឹងសំណួរនេះទេ ប៉ុន្តែគួរបញ្ជាក់ថាតើសាក្សីនោះគ្រាន់តែសួរថា តើសាក្សីបានឃើញអ្វី? ហើយគាត់ជាផ្នែកមួយតូចនៃកងពលលេខ១ នៃភូមិភាគឧត្តរតែប៉ុណ្ណោះ។ ដូច្នេះបើសិនគាត់សួរពីទាហានកងទ័ពខ្មែរក្រហមជាទូទៅ នោះគឺវាទូលំទូលាយពេកការតាំងសំណួរបែបនេះ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យតំណាងសហព្រះរាជអាជ្ញាសួរសំណួរឲ្យជាក់លាក់ ទៅលើសាក្សីរូបនេះ។ សូមអរគុណ។

[០៩:២៨:៤៨]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធាន តាមពិតសំណួររបស់ខ្ញុំគឺបានតពីចម្លើយដែលសាក្សីបានឆ្លើយថា នៅពេលដែលចូលមកដល់ភ្នំពេញ គឺទាហានខ្មែរក្រហមប្រាប់ប្រជាជនឲ្យជម្លៀស។ អ៊ីចឹងសួរថា ក្នុងនាមជាទាហានតើគាត់បានទទួលព័ត៌មានបញ្ជាពីអ្នកណា ដើម្បីប្រាប់ប្រជាជនឲ្យជម្លៀសចេញ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរ!

**លោក ស៊ុំ ជា៖**

**ឆ៖** ពីវរសេនាតូច ឈ្មោះ ប្រធានវរៈ ឈ្មោះ បងហាក់។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តើប្រធានវរសេនាតូចឈ្មោះ ហាក់ នោះ ប្រាប់លោកដោយផ្ទាល់ ហើយប្រាប់ថាយ៉ាងម៉េចដែរ នៅពេលដែលចូលមកដល់ភ្នំពេញហ្នឹង?

**ឆ៖** មិនមែនប្រាប់ដោយផ្ទាល់ទេ គឺប្រាប់នៅក្នុងអង្គភាពទាំងអស់តែម្តង នៅក្នុងអង្គភាពរបស់គាត់ ធ្វើម៉េចឲ្យតែបានប្រជាជនហ្នឹងចេញ។

**ស៖** តើនៅពេលដែលឈ្មោះ ហាក់ ប្រាប់ទៅអង្គភាពទាំងមូលហ្នឹង គាត់បាននិយាយសម្តីថាម៉េច ដើម្បីប្រាប់ទៅកងពលរបស់លោក កងពលលេខ១ ហ្នឹង?

**ឆ៖** ហ្នឹងគាត់ថា បញ្ជាថា ឲ្យប្រជាជនហ្នឹងគឺជម្លៀសចេញទៅឲ្យ ៧ថ្ងៃ គឺសឹមចូលត្រឡប់មកវិញ គឺឲ្យបាន ៧ថ្ងៃសិន ព្រោះគេបោសសម្អាតនៅទីក្រុងភ្នំពេញហ្នឹង។

**ស៖** លោកថា មេវរសេនាតូចឈ្មោះ ហាក់ ជាអ្នកបញ្ជា ឬក៏ប្រាប់ទៅដល់កងពលដើម្បីឲ្យជម្លៀសប្រជាជនចេញ។ អ៊ីចឹងចង់សួរលោកថា លោកដឹងទេថា តើវរសេនាតូចឈ្មោះ ហាក់ ហ្នឹងគាត់

បានទទួលបញ្ជាពីនរណា ឬពីថ្នាក់ណាដែរដើម្បីទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញនោះ?

**ផ៖** ព្រោះ ហាក់ ហ្នឹងក៏នៅក្រោម វឿង ដែរ។ វឿង ហ្នឹង គាត់កងពល, បងហាក់ ហ្នឹងវរ-សេនាតូចទេ។ ប៉ុន្តែ បងហាក់ ហ្នឹងមិនដឹងពីណាមក អីពីណាមកខ្ញុំមិនដឹងដែរ។

**ស៖** ចាស សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល នៅពេលដែលអ្នកស៊ើបអង្កេតសួរលោក គឺនៅត្រង់ ERN ដដែល មុនដែលខ្ញុំបានអាននេះ ហើយចុះមកក្រោមបន្តិច នៅពេលដែលអ្នកស៊ើបអង្កេតសួរថា "ពេលនោះ មេមានប្រាប់យ៉ាងម៉េចទេ បើសិនប្រជាជនមិនព្រមចេញ?" ហើយលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា "កាលនោះគាត់និយាយថា ធ្វើម៉េចក៏ដោយឲ្យតែចេញ។ មេដែលប្រាប់ផ្ទាល់នោះជាមេវរសេនាតូចឈ្មោះ ហាក់"។ អ៊ីចឹង សំណួរដែលខ្ញុំចង់សួរលោក សួរថា សូមលោកជួយពន្យល់ពាក្យថា "ធ្វើម៉េចក៏ដោយ ឲ្យតែចេញនោះ" តើមានន័យថាដូចម្តេចក្នុងកាលៈទេសៈ ពេលវេលាកាលនោះ?

[០៩:៣២:៣៧]

**ផ៖** នេះនៅក្នុងកងធំខ្ញុំ ស្រួល ប្រជាជនហ្នឹងប្រាប់ឲ្យចេញ ចេញ។ ប៉ុន្តែបើកងគេធ្វើបាបដល់ប្រជាជន។ មានវ៉ៃ មានស្អីៗអ៊ីចឹងទៅ។ ធ្វើម៉េចឲ្យតែបានចេញ។

**ស៖** អ៊ីចឹងពាក្យដែលថា "ធ្វើម៉េចឲ្យតែបានចេញ" ហ្នឹងតើខ្ញុំយល់ជាការត្រឹមត្រូវទេ មានន័យថា ត្រូវបើសិនជាត្រូវសម្លុត សម្លុត, គំរាមៗ ឬក៏ត្រូវភ្លង់កាំភ្លើង ឬក៏ធ្វើបាបវាយម៉េចក៏ដោយ ឲ្យតែប្រជាជនចេញ។ តើពាក្យហ្នឹងមានន័យថាអ៊ីចឹង! តើខ្ញុំយល់ត្រឹមត្រូវទេ?

**ផ៖** បាទ ត្រឹមត្រូវ។

**ស៖** ចាស សូមអរគុណ។ ហើយក្នុងចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតដដែល នៅត្រង់ ERN ជាភាសាខ្មែរ 00205057 និង ERN ជាភាសាអង់គ្លេស គឺ 00223346 និង ERN ជាភាសាបារាំង 00705377។ នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកថា "រីឯក្រុមទ័ពផ្សេងទៀតលោកមានដឹងទេថា ពេលជម្លៀសប្រជាជន មានជួបអ្នកដែលមិនព្រមចេញទេ? ហើយគេធ្វើយ៉ាងដូចម្តេចជាមួយនឹងប្រជាជនទាំងនោះ?" ហើយលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា "ទ័ពផ្សេងហ្នឹងមានភ្លង់កាំភ្លើងឲ្យភ័យ ឲ្យប្រជាជន មានអ្នកមិនព្រមចេញហ្នឹង គឺវាយធ្វើបាប មានបាញ់សម្លាប់។ គឺខាងទ័ពបូព៌ាហ្នឹងខ្លាំងជាងគេ"។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោក សួរថាតើការវាយធ្វើបាប ការបាញ់សម្លាប់ដែលបានធ្វើឡើងកងទ័ពបូព៌ានោះ គឺធ្វើឡើងលើប្រជាជនស៊ីវិល ឬមានការវាយធ្វើបាប

និងសម្លាប់ដល់ទាហាន លន់ នល់ និងពិសេសទាហានដែលសុំចុះចាញ់ដែរឬទេ ពេលនោះ?

[០៩:៣៤:៥៥]

**ឆ៖** ចូលដល់ទីក្រុងភ្នំពេញ មិនដឹងជាអ្នកណាទាហាន មិនដឹងអ្នកណាជាប្រជាជនទេ គឺឲ្យតែមិនព្រមចេញឃើញតែកងគេធ្វើបាបប្រជាជនហ្នឹង។ ធ្វើម៉េចសម្អុត ធ្វើម៉េចឲ្យតែបានចេញពីទីក្រុងភ្នំពេញហ្នឹង។

**ស៖** អ៊ីចឹងសូមលោកជួយរៀបរាប់លម្អិតបន្តិចមើល៍ថា តើការធ្វើបាបប្រជាជនហ្នឹង គេធ្វើយ៉ាងម៉េចខ្លះ?

**ឆ៖** បើប្រជាជនរឹងទទឹង មានកងខ្លះហ្នឹង គេៗបាញ់ៗសម្លាប់ចោលម្នាក់ ពីរនាក់ទៅ លឿនតែម្តងប្រជាជនចេញ។

**ស៖** អ៊ីចឹងស្ថានភាពប្រជាជននៅពេលនោះយ៉ាងម៉េចដែរ?

**ឆ៖** ទាល់តែប៉ុណ្ណឹងបានប្រជាជនលឿនចេញទៅ ចេញលឿនប្រហែលជា ៥ថ្ងៃចេញអស់រលីងគ្មានសល់នៅទីក្រុងភ្នំពេញ។

**ស៖** តើនៅពេលដែល -- នៅក្នុងឆ្នាំ៧៥ នៅពេលដែលទ័ពលោកចូលមកទីក្រុងភ្នំពេញហ្នឹង តើលោកមានឃើញអ្នកមានជំងឺ ឬអ្នករងរបួសអីនៅតាមផ្លូវ ហើយពួកគាត់នៅក្នុងស្ថានភាពបែបណាដែរពេលនោះ?

[០៩:៣៦:៣៨]

**ឆ៖** មួយជំនាន់នុ៎ងប្រជាជនពិបាកវេទនាដោយនៅក្នុងមន្ទីរពេទ្យ ដែលកូនចៅយកទៅ អូសតាមរទេះទៅ នៅតាមផ្លូវហ្នឹងវេទនាណាស់ ពេទ្យកាល់ម៉ែត និងពេទ្យធំហ្នឹង ខ្ញុំឃើញកាលហ្នឹង អ្នកខ្លះងាប់កណ្តាលផ្លូវទៅ។

**ស៖** ខ្ញុំនឹងចូលមកដល់ផ្នែកមួយទៀតទាក់ទងទៅនឹងគោលដៅ និងស្ថានភាពនៅពេលដែលទ័ពខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ។ តើគោលដៅដែលទ័ពរបស់លោក គឺកងពលលេខ១ បានទទួលបញ្ជាឲ្យជម្លៀសប្រជាជនហ្នឹង ជម្លៀសប្រជាជននៅម្តុំណា? ហើយត្រូវមានគោលដៅឆ្ពោះទៅកន្លែងណាដែរ?

**ឆ៖** ខាងខ្ញុំហ្នឹងជម្លៀសប្រជាជនតាំងពីផ្សារថ្មីរហូតដល់ស្ពានជ្រោយចង្វា និងគីឡូលេខ៩ហ្នឹង។ ហ្នឹងគេចែកមុខព្រួញគ្នាត្រឹមហ្នឹង។

**សៈ** តើលោកចាំបានទេថា តើលោកបានទទួលបញ្ជាឱ្យជម្លៀសប្រជាជនពីផ្សារថ្មី ដល់ទួលគោក ស្ពានជ្រោយចង្វា និងគីឡូម៉ែត្រលេខ៩ហ្នឹង លោកបានទទួលបញ្ជាហ្នឹងនៅពេលណា? ហើយនៅកន្លែងណាដែរ ដែលលោកបានទទួលបញ្ជាហ្នឹង?

[០៩:៣៨:៣២]

**ផៈ** អាហ្នឹងដឹងនៅ៧៥ តែមិនដឹងថ្ងៃខែណា។

**សៈ** បើលោកអត់ចាំថ្ងៃខែ លោកចាំបានទេ ថាកន្លែងណាដែលលោកបានទទួលបញ្ជា? បានទទួលបញ្ជាហ្នឹងពីកន្លែងណា?

**ផៈ** បងៗ ហាក់ អ្នកជម្លៀស -- ប្រាប់ឱ្យជម្លៀសចេញ។

**សៈ** អ៊ីចឹង បងហាក់ ហ្នឹងបានប្រាប់កងពលទាហានខ្មែរក្រហមឱ្យជម្លៀសប្រជាជនចេញ។ អ៊ីចឹងជម្លៀសប្រជាជនមានគោលដៅជម្លៀសពីភ្នំពេញហ្នឹងទៅកន្លែងណាដែរ?

**ផៈ** អត់ដឹងទេ គ្រាន់តែជម្លៀសឱ្យចេញពីទីក្រុងភ្នំពេញ មិនដឹងទៅទិសដៅៗខាងណា អត់ដឹង។

**សៈ** ពាក់ព័ន្ធទៅនឹងផ្នែកមួយទៀតនៃការបោសសម្អាត ឬសម្លាប់ទាហាន លន់ នល់ ដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត។ តើលោកនៅចាំបានទេថា ជាក់ស្តែងនៅពេលដែលទាហានកងពលលេខ១ ដែលចូលមកដល់ក្នុងភ្នំពេញដើម្បីជម្លៀសប្រជាជនហ្នឹង។ ជម្លៀសប្រជាជនប៉ុន្មានថ្ងៃ? ប្រាំ ប្រាំមួយ ឬប្រាំពីរថ្ងៃ សូមលោកឆ្លើយបញ្ជាក់ឱ្យច្បាស់កន្លែងនេះ?

**ផៈ** ជម្លៀសចេញ ៤, ៥, ៦ថ្ងៃ គឺអស់ពីទីក្រុងភ្នំពេញ។

**សៈ** នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយដដែលជាមួយនឹងអ្នកស៊ើបអង្កេត នៅត្រង់ ERN ជាភាសាខ្មែរគឺ 00205058, ជាភាសាអង់គ្លេសគឺ 00223346 និងជាភាសាបារាំងគឺ 00705378 នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកថា “ក្រោយមក គេធ្វើទៀត ពេលប្រជាជនចេញអស់ពីទីក្រុងភ្នំពេញ?” ពេលនោះលោកបានឆ្លើយថា “៧, ៨ថ្ងៃ ពេលដាក់មីក្រូផ្សាយ។ ចំពោះទាហាន លន់ នល់ បើអ្នកណាមានស័ក្តិធំៗ ស័ក្តិប៉ុន្មាន? (សុំទោស) ធ្លាប់ធ្វើការកន្លែងណាឱ្យចូលមកធ្វើការកន្លែងដើមវិញ។ កាលណោះ ខ្ញុំចង់ -- អ្នកខ្លះចង់បានធំ តែខ្លួនពីមុនធ្លាប់ធ្វើជាទាហានតូចតាចធម្មតា គឺថាស័ក្តិ៣ ស័ក្តិ៤អ៊ីចឹង ក៏ងាប់អស់ទៅ។ ខ្លះចង់រស់ ខំលាក់ការណ៍ដែរ តែចាប់បានដដែលហ្នឹង ព្រោះស្រាវជ្រាវតាមប្រវត្តិ”។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោកនៅពេលនេះ សួរថា តើលោកនៅចាំបានទេ កន្លែងណាឱ្យពិតប្រាកដដែលគេ ដែលជាកន្លែងដែលកងទ័ពខ្មែរក្រហមយកទាហាន លន់ នល់ ដែលត្រូវបានគេ

បញ្ជោតឲ្យចូលត្រឡប់មកវិញនោះ ទៅសម្លាប់ចោល?

[០៩:៤២:១៨]

**ឆ៖** ក្រោយពីប្រជាជនជម្លៀសអស់តាមកងពល តាមវរសេនាតូច គេដាក់មីក្រូ គេបើកឡាន ទៅ។ បើសិនជាអ្នកណាបានធ្វើស្អី ស័ក្តិប៉ុន្មានឲ្យចូលមកធ្វើការវិញ។ រួចអ្នកខ្លះចេះតែភរ អ្នកខ្លះគ្មានធ្វើស្អីផង ចេះតែភរស័ក្តិប៉ុននេះ ស័ក្តិប៉ុននោះ។ យកមក គេសម្លាប់ចោលវិញដដែល។ សម្លាប់ហ្នឹង គឺសម្លាប់នៅម្តុំព្រែកព្នៅយើងនេះ។ អាហ្នឹង ខ្ញុំឮនៅក្នុងកងរបស់ខ្ញុំហ្នឹង និយាយប្រាប់។

**ស៖** តើលោកចាំបានទេថា អ្នកណាជាអ្នកប្រាប់លោក ហើយឈ្មោះអីដែរ?

**ឆ៖** មួយឈ្មោះ គឿន អ្នកនិយាយប្រាប់។ គឿន ហ្នឹងគេដែលដល់ណាស់ រឿងសម្លាប់នេះ សម្លាប់អីហ្នឹង។

**ស៖** ចុះឈ្មោះ គឿន ដែលប្រាប់លោកដោយផ្ទាល់ហ្នឹង មានប្រាប់ពីវិធីដែលទាហានខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ ទេ។ តើវិធីដែលគេសម្លាប់ហ្នឹងបែបណា គេមានប្រាប់លោកទេ?

**ឆ៖** ហ្នឹងអត់ប្រាប់ ប៉ុន្តែគ្រាន់តែគាត់ថា គ្រាន់តែទាហានហ្នឹងចង់បានស័ក្តិធំប៉ុន្មាន ស័ក្តិតូចហ្នឹងត្រឡប់មកវិញ គាត់នឹងយកទៅសម្លាប់ចោល។ គ្មានបានប្រាប់ថ្ងៃហ្នឹង ឬវៃ ឬអី ប៉ុន្តែដល់តែរួចទៅបានយកអាត្រាក់ហ្នឹងឈូសលុបខ្មោចហ្នឹង។

[០៩:៤៤:៣៩]

**ស៖** ខ្ញុំនៅមានសំណួរចុងក្រោយមួយទៀត ដើម្បីសួរលោក។ នៅក្នុងចម្លើយដដែល ដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវតាមខ្សែរកទាហាន លន់ នល់ រកអីហ្នឹង សួរថា លោកដឹងថា តើវិធីណាដែលគេស្រាវជ្រាវរកខ្សែទាហាន លន់ នល់? ហើយប្រសិនបើគេស្រាវជ្រាវរកឃើញនោះតើគេធ្វើយ៉ាងម៉េចជាមួយនឹងទាហាន លន់ នល់?

**ឆ៖** បាទ គេស្រាវជ្រាវ គេបើកឡានទៅដាក់មីក្រូ គេឃោសនាទៅ អ្នកណាធ្វើស័ក្តិប៉ុន្មានៗ ឲ្យឡប់មកចូលមកធ្វើការវិញ។ គេចាប់ដោយចំណុចហ្នឹង។

**កញ្ញា សុង ឆវ័ន្តៈ**

សូមអរគុណលោក ស៊ុំ ជា ដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ ហើយបន្តមកទៀតនេះ គឺសហការីអន្តរជាតិរបស់ខ្ញុំ គាត់នឹងមានសំណួរមួយចំនួនដើម្បីសាកសួរលោក។ អរគុណលោកប្រធាន។

[០៩:៤៦:០៦]

**លោក ឌេល លីសាក់៖**

សូមជម្រាបសួរលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោក ស៊ុំ ជា។ ខ្ញុំឈ្មោះ ដេល លីសាក់ ខ្ញុំជាតំណាងខាងព្រះរាជអាជ្ញា ហើយខ្ញុំនឹងធ្វើការចោទសួរលោកមួយចំនួននៅក្នុងថ្ងៃនេះ។ ជាដំបូង ខ្ញុំសូមចាប់ផ្តើមដោយនិយាយត្រឡប់ទៅរកពេលវេលាមួយ គឺពេលវេលាមុនពេលដែលធ្វើការវាយរំដោះទីក្រុងភ្នំពេញ។ លោកបានជម្រាបសហការីរបស់ខ្ញុំថា លោកបានចូលរួមជាមួយនឹងទាហានបដិវត្តន៍នៅក្នុងឆ្នាំ៧២ ហើយនៅពេលនោះ គឺគេផ្ទេរលោកទៅបឹងស្នាយ ហើយលោកបានបញ្ជាក់ផងដែរ -- បឹងណាយ គឺគេផ្ទេរលោកទៅភូមិបឹងណាយ ហើយគេបានប្រាប់ថា -- ហើយក្រោយមកក្រុមរបស់លោកទៅភ្នំបាសិត ហើយក្រោយមកលោកបានមកវាយរំដោះទីក្រុងភ្នំពេញ។ ដូច្នេះ ជាដំបូងខ្ញុំចង់ធ្វើការសួរលោក ថាតើមានទីតាំងណាផ្សេងទៀតដែលទាហានរបស់លោក ឬកងរបស់លោកហ្នឹងធ្លាប់បោះទីតាំងស្នាក់នៅចន្លោះពីឆ្នាំ៧២ រហូតទៅដល់រយៈពេលដែលលោកមកនៅតំបន់ភ្នំបាសិត តើក្នុងចន្លោះពីឆ្នាំ៧២ រហូតមកដល់ពេលដែលលោកភ្នំបាសិតហ្នឹង តើកងពលរបស់លោក ឬក៏ទាហានរបស់លោកហ្នឹងធ្លាប់មានទៅបោះទីតាំងកន្លែងណាផ្សេងទៀតដែរឬទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** ខ្ញុំចូលដំបូងនៅភូមិបឹងណាយ ឃុំបឹងណាយ មិនមែន -- ហើយទ័ពក៏ឈរជើងនៅហ្នឹង

ដែរ ៧២ហ្នឹងអត់ទាន់មានកាំភ្លើងអីល្អទេ។ បាទ ហ្នឹងចូលៗ ដំបូងហើយហ្នឹង។ ហើយបានវៃហូរហែ

មកតាមផ្លូវជាតិលេខ៧ រហូតធ្លាក់មកដល់បាសិត ឆ្នាំជិតចូល៧៥ ហើយ។

[០៩:៤៨:២៩]

**ស៖** តើលោកចាំដែរឬទេថា នៅពេលដែលលោកវាយប្រយុទ្ធហ្នឹង តើលោកវាយប្រយុទ្ធនៅតំបន់ណាខ្លះចន្លោះពីឆ្នាំ៧២ ដល់៧៥ គឺខ្ញុំចង់សួរថា រយៈពេលដែលលោកធ្វើការវាយមុននឹងមកដល់ទីក្រុងភ្នំពេញហ្នឹង តើលោកឆ្លើយកាត់ទីតាំង ឬក៏ឆ្លងកាត់តំបន់ណាខ្លះដែរ?

**ឆ៖** វៃនៅកំពង់ចាម។ នៅខ្វិត នៅស្គន់ វៃរហូតដល់ថ្នល់កែង រហូតដល់ព្រៃកក្តាម។ ដាច់

ព្រែកក្តាមបានចូលមកដល់ស្ពានទឹកថ្លា, ស្ពានទឹកថ្លារួចបានចូលដល់បាសិត។ ប៉ុន្តែភ្លេចឆ្នាំ វ៉ៃតាំងពី៧២ មករហូតដល់៧៥។

**ស៖** សូមអរគុណលោក។ តើលោកអាចប្រាប់យើងបានទេថា លោកមានតួនាទី ឬក៏មានឋានៈអ្វីដែរនៅក្នុងកងពលលេខ១ នោះ? គឺនៅក្នុងចន្លោះពេលឆ្នាំ៧៥ អ៎! ៧២ ដល់ខែមេសា ឆ្នាំ៧៥នុំង លោកមានតួនាទីអ្វីដែរ?

**ឆ៖** អត់មាននាទីអីផង។

**ស៖** តើលោកជាៗទាហានរបស់ខាងកង ឬមួយក៏ខាងកងអនុសេនាតូច ឬក៏តើមានជាកង មានជាឈ្មោះអ្វីដែរទេ នៅពេលដែលលោកធ្វើទាហានពីឆ្នាំ៧២ ដល់៧៥នោះ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយមួយសាហ្នឹង។ ដឹងថាវរសេនាតូចហ្នឹងមាន បងហាក់ វរសេនា--កងពលធំហ្នឹងមាន វឿង។ ផ្លាស់ប្តូរៗ វង្វេងមិនដឹងជាណាណី ភ្លេចហើយ។

**ស៖** លោកបានបញ្ជាក់អំពីខេត្តកំពង់ចាមជាតំបន់ៗមួយ ដែលលោកធ្លាប់បានឆ្លងកាត់ពេលវាយប្រយុទ្ធ។ តើលោកអាចប្រាប់បានទេថា នៅពេលណាដែលទីរួមខេត្តកំពង់ចាមហ្នឹងត្រូវបានទាហានខ្មែរក្រហមរំដោះ? តើនៅក្នុងថ្ងៃខែឆ្នាំណា?

[០៩:៥១:៥៤]

**ឆ៖** ខ្ញុំភ្លេចបាត់។ បើតាមផ្លូវមួយកំណាត់ៗហ្នឹង តាំងពី៧២មក វ៉ៃ៧២, ៧៣ ហ្នឹងផ្តាច់ នៅតែទីក្រុងកំពង់ចាមមួយ។ ដាច់មករហូតដល់ៗព្រែកក្តាម ដល់នេះ នៅទីក្រុងកំពង់ចាម។ ៧២, ៧៣, ៧៤ ហ្នឹងដាច់អស់។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ថាមានអ្វីកើតឡើងចំពោះប្រជាជននៅក្នុងទីរួមខេត្តកំពង់ចាម បន្ទាប់ពីគេរំដោះ គឺថាបន្ទាប់ពីខ្មែរក្រហមបានរំដោះនៅក្នុងឆ្នាំ៧២ ឬក៏៧៣នោះ?

**ឆ៖** អត់ដឹងផង ព្រោះខ្ញុំទ័ព។ ទ័ពគេមិនឲ្យដើរផង ក្នុងកង ក្នុងក្រុម គេមិនឲ្យដើរ ដើរលេងផ្តេសផ្តាសទេ អត់ទេ វិន័យគេរឹងណាស់។

**ស៖** តើលោកចាំដែរឬទេ ថាតើប្រជាជននៅកំពង់ចាមហ្នឹង គេឲ្យបន្តរស់នៅក្នុងទីរួមស្រុក ឬក៏ទីរួមខេត្ត ឬមួយក៏គេបង្ខំ ឬក៏តម្រូវឲ្យពួកគាត់ហ្នឹងជម្លៀសទៅតាមជនជទដែរឬទេ?

**ឆ៖** អត់ដឹងដែរ អត់ដឹង។ ព្រោះទ័ពនៅមុខ ដឹងថានៅមុខតែម្តង។ គេមិនទាំងឲ្យមកលេងផ្ទះ គេមិនឲ្យដឹងឪពុកម្តាយយើងនៅផ្ទះផង។

[០៩:៥៤:០៨]

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ថាតើវរសេនាតូច ឬក៏ក្រុមវរសេនាធំរបស់លោកហ្នឹង បានចូលរួមនៅក្នុងការវាយប្រយុទ្ធនៅឧដុង្គដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** សហការីរបស់ខ្ញុំបានសួរលោកកន្លងមកហើយ ថាតើមានទាហានប៉ុន្មាននាក់នៅក្នុងកងពលរបស់លោក ហើយលោកបានបញ្ជាក់ថានៅពេលដែលលោកចូលដំបូង គឺមិនសូវជាមានទាហានច្រើនប៉ុន្មានទេ គឺថានៅពេលនុ៎ងកងពលមិនទាន់បង្កើតជាគ្រប់ទ្រង់ទ្រាយនៅឡើយ។ អ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះគឺថា នៅពេលដែលលោកចូលរួមក្នុងការវាយប្រយុទ្ធនៅទីក្រុងភ្នំពេញ នៅថ្ងៃ -- នៅខែមេសា ឆ្នាំ៧៥ ហ្នឹង តើមានទាហានប្រហែលប៉ុន្មាននាក់នៅក្នុងកងពលលេខ១ របស់លោកនោះ?

**ឆ៖** អត់ដឹងទេ។ អត់ដឹងកងពលគេរៀប ដឹងតែតាមក្រុមហ្នឹង គឺមួយក្រុមៗហ្នឹងពីរដណ្ដប់នាក់។ ប៉ុន្តែរឿងកងពលគឺក្ដាប់មិនបានទេ។ ក្ដាប់អត់បាន ទាល់តែប្រធានកងពល បានគេក្ដាប់បាន។

**ស៖** តើលោកចាំដែរឬទេថា មានទាហានប៉ុន្មាននាក់ ឬក៏មានកងប៉ុន្មានកង ដែលស្ថិតនៅក្នុងវរសេនាតូចរបស់លោក គឺវរសេនាតូចដែលដឹកនាំដោយ បងហាក់ នោះ តើមានទាហានប៉ុន្មានរូបប៉ុន្មាននាក់ ឬក៏មានប៉ុន្មានកង ប៉ុន្មានក្រុមដែរ?

**ឆ៖** បងហាក់ ហ្នឹងក៏អត់ដឹង គាត់ក្ដាប់មួយវរសេនាតូច។ មួយវរសេនាតូចមិនដឹង -- វា ៗអត់គ្រប់ទេមួយសាហ្នឹង អត់គ្រប់ជាលក្ខណៈ។ ពីដើមមួយក្រុមពីរដណ្ដប់នាក់ ដល់វ៉ៃៗងាប់អស់រលីងទៅនៅសល់បួនប្រាំនាក់ ខ្លះមួយក្រុមសល់ពីរបីនាក់ ក៏ឃើញដែរ។ អត់មានលក្ខណៈរាប់ឲ្យពេញដូចសព្វថ្ងៃគ្មានទេ អត់ទេ។

[០៩:៥៧:១៤]

**ស៖** សូមអរគុណ។ សូមថ្លែងអំណរគុណដែលលោកបានផ្ដល់នូវព័ត៌មានតាមដែលលោកបានដឹង។ ឥឡូវនេះខ្ញុំសូមបន្តទៅនិយាយអំពីការវាយរំដោះទីក្រុងភ្នំពេញ និងការជម្លៀសពីទីក្រុងភ្នំពេញ។ លោកបានជម្រាបមកសហការីរបស់ខ្ញុំថា លោកបានវាយទីក្រុងភ្នំពេញចេញពីបាសិតមក គឺលោកឆ្លងកាត់ឃ្លាញ គឺឆ្លងកាត់តាមច្រកឃ្លាញ។ ចំពោះអ្នកដែលមិនស្គាល់អំពីទីតាំងហ្នឹង តើលោកអាចជម្រាបបានដែរទេ អំពីទីតាំងរបស់បាសិត ហើយនិងឃ្លាញ តើបាសិត ហើយឃ្លាញហ្នឹងវាមានទីតាំងឆ្ងាយប៉ុន្មានដែរ ធៀបជាមួយនឹងទីក្រុងភ្នំពេញរបស់យើងនេះ?

**ឆ៖** បាទ បាសិតហ្នឹង គឺជាខ្សែក្រវាត់ទីក្រុងភ្នំពេញ ដល់វ៉ៃបែកបាសិតទៅ វារត់កាត់ទៅតាមរនះព្រៃ ទៅលើៗឃ្លួញ។ ឃ្លួញហ្នឹងនៅខាងលិចបាសិត។ ល្បាក់ពីបាសិតទៅប្រហែលជាប្អូនប្រាំគីឡូ ប៉ុណ្ណឹង គ្រាន់ប្រហែល។ ទៅដល់ឃ្លួញហ្នឹងបានកាត់ទៅលើត្រឡោកបែក ចូលទួលគោកបត់ទៅកើតវិញ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺបាសិតហ្នឹងមានទីតាំងនៅខាងជើងទីក្រុងភ្នំពេញ។ តើអ៊ីចឹងមែនទេ?

[០៩:៥៩:០៨]

**ឆ៖** បាទៗ។

**ស៖** នៅក្នុងរយៈពេលដែលលោកវាយរំដោះមកកាន់ទីក្រុងភ្នំពេញហ្នឹង តើលោកអាចប្រាប់បានទេ តើមានអ្វីកើតឡើងចំពោះទាហាន លន់ នល់ ដែលត្រូវបានទាហានខ្មែរក្រហមចាប់ខ្លួននោះ តើមានអ្វីកើតឡើង?

**ឆ៖** អត់មានអីកើតឡើង។

**ស៖** តើធ្លាប់មានពេលណាមួយដែលកងរបស់លោក ដែលវរសេនាតូចរបស់លោកចាប់បានទាហាន លន់ នល់ គឺថានិយាយអំពីមុនពេលដែលវាយរំដោះទីក្រុងភ្នំពេញ? តើធ្លាប់មានពេលណាដែលទាហានលោកចាប់បានទាហាន លន់ នល់ ទេ?

**ឆ៖** កងខ្ញុំហ្នឹងមិនដែលចាប់បាន បើកងគេ គឺគេចាត់តាំងមួយកងៗហ្នឹង ដើម្បីឲ្យដាក់ក្បាលមីក្រូ គេឃោសនាឲ្យទាហានត្រឡប់មកវិញហ្នឹង ទាហានមកធ្វើការវិញ។ ដល់ចាប់ៗបាន ដូចឃោសនាអ៊ីចឹង ថាអ្នកណាធ្វើការអី ឲ្យមកធ្វើការហ្នឹងវិញ។ គេចាប់បានអ៊ីចឹង។

[១០:០១:១៤]

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ ថាតើយើងយល់អំពីសំណួរហ្នឹងទាំងអស់គ្នាឬក៏អត់? ខ្ញុំចង់និយាយអំពីរយៈពេលមុនពេលដែលលោកមកដល់ទីក្រុងភ្នំពេញ។ ថាតើមុនពេលដែលលោកមកដល់ភ្នំពេញហ្នឹង តើធ្លាប់មានពេលណាមួយ គឺថានៅពេលដែលប្រយុទ្ធ គឺថាលោកចាប់បានទាហាន លន់ នល់។ ថាតើនៅពេលដែលចាប់បានទាហាន លន់ នល់ ហ្នឹង គេធ្វើអ្វីជាមួយពួកទាហាន លន់ នល់ ទាំងអស់នោះ?

**ឆ៖** វ៉ៃចូលទីក្រុងភ្នំពេញ អត់មានឃើញតែម្តងទាហាន លន់ នល់។ មិនឃើញ ស្គាល់ជ្រាប

មិនដឹង -- ទាហានវាដោះខោអាវអស់រលីងហើយ អត់មានៗចាប់បានទេបាទ។ មិនដឹងណាមួយទាហាន និងណាមួយប្រជាជនទេ។ ដោយចាប់បានៗ គេដាក់ក្បាលមីក្រូ អំមិញដូចខ្ញុំនិយាយអំមិញហ្នឹង ដើរឃោសនា អ្នកណាធ្វើស័ក្តិប៉ុន្មានៗហ្នឹង ឲ្យត្រឡប់មកចូលធ្វើការទីក្រុងភ្នំពេញវិញ បានគេចាប់បាន។ អាហ្នឹងចាប់បានខ្លះទេ ក្រៅពីហ្នឹងទៅតាមសហករណ៍អស់រលីងហើយ។

[១០:០២:៤៩]

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរបន្ថែមទៀតទៅលើទាហានដែលត្រូវបានគេចាប់ខ្លួន បន្ទាប់ពីត្រូវបានប្រកាសតាមវិទ្យុនោះ តាមមីក្រូនោះ។ ឥឡូវនោះខ្ញុំចង់សូមសួរបន្តទៅទៀត និយាយពីការបញ្ជាដែលលោកបានទទួលនៅពេលដែលលោកបានចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃដំបូង តាមរយៈបញ្ជារបស់មេកងវរសេនាតូចរបស់លោក។ លោកបានជម្រាបថា លោកបានទទួលបញ្ជា អ្វីក៏ដោយគឺថាត្រូវតែធ្វើយ៉ាងណាឲ្យតែខាង ប្រជាជនត្រូវតែចេញទីក្រុងភ្នំពេញ។ ខ្ញុំចង់ត្រឡប់ទៅចូលផ្នែកមួយដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត គឺឯកសារ D94/9 ត្រង់ ERN ជាភាសាខ្មែរ 00205057, ERN ជាភាសាអង់គ្លេស 00223346, ERN ជាភាសាបារាំង 00705377។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនោះនៅលើអេក្រង់កុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០៤:៣៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីលោកបានប្រាប់ទៅអ្នកស៊ើបអង្កេតរបស់ការិយាល័យតំណាង -- ការិយាល័យសហចៅក្រមស៊ើបអង្កេតថា "ទាហានដទៃទៀតបានភ្ជង់កាំភ្លើងបំភិតបំភ័យប្រជាជន ប្រសិនប្រជាជនរឹងទទឹងមិនចេញ មានវាយធ្វើបាប មានបាញ់សម្លាប់ គឺខាងទ័ពបូព៌ាហ្នឹងខ្លាំងជាងគេ"។ សំណួរទី១ របស់ខ្ញុំគឺ តើលោកបានឃើញការបាញ់ប្រហារ ការសម្លាប់នោះដែរឬទេ ក្រោយពេលលោកចូលមកដល់ទីក្រុងភ្នំពេញនោះ?

**ឆ៖** ខាងកងខ្ញុំហ្នឹង អត់មានធ្វើបាបប្រជាជន ជម្លៀសដោយស្រួល។ ខ្ញុំឈរជើងនៅទួតបារាំង កន្លែងទូតបារាំងសព្វថ្ងៃហ្នឹង។ ហើយកងគេនៅមួយថ្នាក់ៗរហូតដល់ផ្សារថ្មី មកជើង ហើយកងខ្ញុំនៅចំ

នៅទួតបារាំងហ្នឹងតែម្តង។ ហើយជម្លៀសស្រួលណាស់ប្រជាជននៅកន្លែងហ្នឹង។ ប៉ុន្តែខាងបូព៌ាខាងអីរាងរឹងទទឹង អាហ្នឹងគេធ្វើបាបមួយពីរទៅ គេបាញ់មួយពីរទៅបានលឿនតែម្តង ប្រជាជន។ ដូចខ្ញុំលើកពីដំបូង អ៊ីចឹង។

**ស៖** តើលោកបានឃើញព្រឹត្តិការណ៍ហ្នឹង! ដែលអង្គភាពដទៃទៀតហ្នឹង បានសម្លាប់ និងបានបាញ់ប្រហារទៅលើប្រជាជនហ្នឹង លោកបានឃើញអ៊ីចឹងដែរឬទេ?

**ឆ៖** ឮតាមក្រុមហ្នឹងគេប្រាប់ថា ណោះខាងនោះគេធ្វើបាបប្រជាជនឲ្យចេញលឿន។ ហើយខ្ញុំថា ខាងយើងស្រួលណាស់ ឲ្យចេញទៅ ព្រូៗ អស់រលីង។ មួយជំនាន់ប្រជាជនតិច មិនដូចសព្វថ្ងៃនេះទេ តិច។

[១០:០៧:១២]

**ស៖** អ្នកណាដែលបានប្រាប់លោកថា ទាហានក្រុមដទៃទៀតបានធ្វើបាបប្រជាជន បានបាញ់សម្លាប់ប្រជាជននោះ?

**ឆ៖** បាទ បងហាក់ ហ្នឹង ជាវរសេនាតូច។ បើថាបើមិន មិនធ្វើបាបខ្លះទេ ធ្វើម៉េចទៅរួច។

**ស៖** ហើយលោកក៏បានបញ្ជាក់ផងដែរ នៅក្នុងចម្លើយរបស់លោក ដែលខ្ញុំទើបបានអាននោះគឺថា ទ័ពភូមិភាគបូព៌ាជាទ័ពដែលខ្លាំងជាគេ។ តើលោកមានបានឃើញព្រឹត្តិការណ៍ណាមួយពាក់ព័ន្ធទៅនឹងទ័ពខាងបូព៌ា ឬក៏ថាបញ្ហានេះ គឺថាលោកបានដឹងតាមរយៈគេប្រាប់លោក ឬក៏យ៉ាងណានោះ?

**ឆ៖** បាទ តាមគេប្រាប់។

**ស៖** ដូច្នេះ ខ្ញុំស្តាប់ឮ តើលោកអាចជម្រាបបានទេ ថាអ្នកណាប្រាប់លោកថា ទ័ពខាងបូព៌ាហ្នឹង គឺ មានការធ្វើ ប្រព្រឹត្តមិនត្រឹមត្រូវ ប្រព្រឹត្តធ្ងន់ធ្ងរមកលើប្រជាជនហ្នឹង អ្នកណាប្រាប់លោក?

**ឆ៖** នៅក្នុងក្រុមហ្នឹងគេអ្នកប្រាប់។

**ស៖** តើលោកមានដឹងថាមានទាហានខ្មែរក្រហមណាដែលចូលរួមនៅក្នុងការធ្វើបាប ការបាញ់សម្លាប់ប្រជាជននៅក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហ្នឹង ហើយគេមានដាក់ទណ្ឌកម្មអីដាក់វិន័យអីទៅលើអ្នកដែលប្រព្រឹត្តអ៊ីចឹងដែរទេ?

**ឆ៖** គ្មានទេ គ្មានគេដាក់វិន័យ គ្មានទាំងតុលាការផង។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរទៅកាន់ចម្លើយរបស់លោកដែលបានឆ្លើយជូនតំណាងសហចៅក្រមស៊ើបអង្កេតនោះ លោកឆ្លើយជូនអ្នកស៊ើបអង្កេតនៅលើឯកសារយោងនេះគឺ ERN ជាភាសាខ្មែរ

00205057, ERN ជាភាសាអង់គ្លេស 00223346 ហើយ ERN ជាភាសាបារាំង 00705377។ បាទ នេះ គឺនៅត្រង់ផ្នែកមួយដែលខ្ញុំទើបតែបានអានមុននេះគឺថា “គេបានប្រាប់យើងថាឲ្យប្រាប់ប្រជាជនទៅចាកចេញពី៤ ទៅ ៥ថ្ងៃ ដើម្បីធ្វើការបោសសម្អាតទាហាន លន់ នល់ និងដោយបញ្ឆោតថា បន្តិចទៀតគេវាយគ្នាផ្ទុះងាប់ទៀតឥឡូវហើយ”។ សូមបញ្ឈប់ការដកស្រង់។ តើបញ្ហានេះដែលលោកបានទទួលនេះ បញ្ហាដែលលោកបានទទួលពីមេវរសេនាតូចរបស់លោក?

**ផ៖** បាទ ត្រឹមត្រូវចម្លើយ កន្លែងនិយាយត្រឹមត្រូវ។ ធ្វើម៉េចឲ្យតែប្រជាជនបានចេញ។

[១០:១២:២២]

**ស៖** តើមេវររបស់លោកហ្នឹង ដែលប្រាប់ថាការជម្លៀសប្រជាជនគឺសូមដកស្រង់ “គឺដើម្បីបោសសម្អាតទាហាន លន់ នល់” មេបញ្ជាការរបស់លោកហ្នឹងជាអ្នកប្រាប់លោកឬ?

**ផ៖** អាហ្នឹងមេអ្នកប្រាប់ ឲ្យជម្លៀសប្រជាជនចេញ។

**ស៖** តើវររបស់លោកហ្នឹងក៏ត្រូវបញ្ជាក់ថា ឲ្យបញ្ឆោតប្រជាជនដែលថា “គេទុក -- គឺគេនឹងវាយប្រហារមកលើទីក្រុងឥឡូវនេះទៀតហើយ” តើមានបញ្ឆោតប្រជាជនអ៊ីចឹងទេ?

**ផ៖** បាទ គេបញ្ឆោតប្រជាជនអ៊ីចឹង ថាឲ្យចេញទៅប្រយ័ត្នគេបាញ់គ្នាផ្ទុះ។ ប្រជាជនភ័យចេញទៅយ៉ាងលឿន។

**ស៖** នៅពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញ តើលោកមានបានឮទាហានខ្មែរក្រហមណានិយាយតាមមីក្រូហ្វូន ដែលថាប្រជាជនត្រូវតែចាកចេញពីទីក្រុងដោយសារថា អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។ តើលោកមានបានឮអ៊ីចឹងទេ?

**ផ៖** អាហ្នឹងចេះតែភរប្រជាជន ធ្វើម៉េចឲ្យតែបានចេញពីទីក្រុងភ្នំពេញ។ បើមិនចេញហ្នឹងប្រយ័ត្នគេទម្លាក់គ្រាប់បែក ប្រយ័ត្នគេបាញ់គ្នាក្នុងទីក្រុងភ្នំពេញហ្នឹង គ្រោះថ្នាក់ គ្រោះអី។

[១០:១៤:៤៥]

**ស៖** តើបញ្ហាដែលមេបញ្ជាការវរៈរបស់លោកបានទទួលមកហ្នឹងដែល គឺថា តម្រូវឲ្យប្រជាជនទីក្រុងភ្នំពេញទាំងអស់ត្រូវតែចាកចេញ រួមទាំងមនុស្សចាស់ជរា រួមទាំងអ្នកជំងឺដែលនៅសម្រាកនៅមន្ទីរពេទ្យនុ៎ងផងដែរឬទេ?

**ផ៖** បាទ អាហ្នឹងឲ្យចេញទៅទាំងអស់តែម្តង។ អ្នកពិការ អ្នកជំងឺ។ កូនចៅ គេអូសយកទៅ។ ទៅតាមពោធិ៍ចិនតុង ទៅតាមផ្លូវជាតិ គឺឡូលេខ៤ហ្នឹងទៅ។ បែកខ្ញែកគ្នាមិនដឹងទៅណា។ ធម្មតាអ្នក

ជម្លៀស អ្នកជម្លៀសដឹងស្រាប់ហើយ។ ធ្វើម៉េចឲ្យតែចេញពីទីក្រុងភ្នំពេញ ហៅថានេះ ចេះតែទៅ។

**ស៖** ខ្ញុំចង់អានផ្នែកមួយនៃចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនូវសំណួរមួយចំនួនដូចខាងក្រោម ទំព័រដែលខ្ញុំត្រូវអាននោះ គឺ ERN ជាភាសាខ្មែរ 00205058, ERN ជាភាសាអង់គ្លេស 00223346, ERN ជាភាសាបារាំង 00705377។

**លោក ឌេល លីសាក់៖**

លោកប្រធានយើងខ្ញុំសុំការអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:១៧:០៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះ លោកបានរៀបរាប់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដូចខាងក្រោមនេះ៖ សូមដកស្រង់ "ស្ថានភាពរបស់ប្រជាជននៅពេលនោះគឺថា វេទនាណាស់ មានអ្នកខ្លះយំ ម៉ែយំ កូនយំ វេទនាណាស់។ ខ្លះស្លាប់នៅក្នុងពេទ្យធំ។ ឥឡូវនេះ គឺថាជាពេទ្យកាល់ម៉ែតបច្ចុប្បន្ននេះ។ អ្នកជំងឺគេដាក់រទេះរុញ។ អ្នកជំងឺខ្លះគ្មានបងប្អូនត្រូវដេកស្លាប់នៅមន្ទីរពេទ្យក៏មាន"។ សំណួរដំបូងរបស់ខ្ញុំនោះ តើលោកបានឃើញអ្នកជំងឺត្រូវបានគេជម្លៀសរុញរទេះចេញហ្នឹង លោកបានឃើញនៅត្រង់ណា? នៅកន្លែងណា?

**លោក ស៊ុំ ជា៖**

**ឆ៖** ឃើញនៅពេទ្យកាល់ម៉ែត កូនចៅគេអូសម្តាយ ឪពុកគេដែលឈឺៗហ្នឹង។ វេទនាណាស់ខ្លះយំ ខ្លះស្រែកអឺចឹងទៅ។ មើលទៅ វាវេទនាពេក។

[១០:១៨:៥០]

**ស៖** លោកបានបញ្ជាក់ប៉ុន្មាននាទីមុននេះ គឺថាអង្គភាពរបស់លោក គឺស្ថិតនៅជិតស្ថានទូតបារាំង។ លោកអាចជម្រាបជូនតុលាការបានទេ ថាតើមន្ទីរពេទ្យណាដែលទាក់ទងនៅជិតស្ថានទូតបារាំងដែលវាជិតទីតាំងនៃអង្គភាពរបស់យើង របស់លោកឈរជើងហ្នឹង លោកអាចបញ្ជាក់បន្តិចមន្ទីរពេទ្យមួយណា?

**ឆ៖** ពេទ្យកាល់ម៉ែត ព្រោះខ្ញុំនៅទូតបារាំង។ កងខ្ញុំនៅទូតបារាំងហ្នឹង។

**ស៖** តើលោក ឬក៏ក្រុមរបស់លោកមានទៅធ្វើដំណើរ ទៅកាន់មន្ទីរកាល់ម៉ែតដែរឬទេ ក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងហ្នឹង?

**ឆ៖** បាទ ទៅ។

**ស៖** ហើយថាតើមានកងទ័ពប៉ុន្មាននាក់ដែលបានធ្វើដំណើរទៅមន្ទីរពេទ្យកាល់ម៉ែត្រនុ៎ង?

**ឆ៖** ទៅពីរបីនាក់។

**ស៖** តើហេតុអីបានជាលោកធ្វើដំណើរទៅកាន់មន្ទីរពេទ្យកាល់ម៉ែត? មូលហេតុអី?

**ឆ៖** អាហ្នឹងគេឲ្យយាមតាមថ្នាល់ចាប់ពីគីឡូលេខ៩ មកទល់នឹងផ្សារថ្មី គេឲ្យនៅចាំយាម ធ្វើម៉េចឲ្យប្រជាជនចេញអស់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើអស់រយៈពេលប៉ុន្មានដែរ ដែលទើបគេអាចឲ្យអ្នកជំងឺទាំងអស់ចាកចេញពីមន្ទីរពេទ្យកាល់ម៉ែតហ្នឹង វាអស់រយៈពេលប៉ុន្មានដែរ?

[១០:២២:០២]

**ឆ៖** អស់ល្បាក់ ៥ថ្ងៃ អស់តែម្តងទីក្រុងភ្នំពេញ។

**ស៖** តើវរសេនាតូចរបស់លោកមានបានទទួលបាយទឹកត្រូវផ្តល់ឲ្យប្រជាជនចែកទៅជូនប្រជាជន ដែលត្រូវចាកចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** អត់ទេ។ អត់មានចែកមានអី។

**ស៖** តើកងវរសេនាតូចរបស់លោកហ្នឹង មានបានទទួលបញ្ជាពីមេបញ្ជាការដែលថា គឺថាអ្នកដែលត្រូវ ប្រជាជនដែលត្រូវចាកចេញពីទីក្រុងភ្នំពេញហ្នឹង គឺត្រូវតែផ្តល់បាយទឹកទៅឲ្យគាត់ មានបានទទួលបញ្ជាបែបនេះដែរឬទេ?

**ឆ៖** អត់មានទេ។ ទ័ពហ្នឹងមិនចង់មានបាយស៊ីផង។ យកអង្ករអីណាទៅឲ្យអីណា។

[១០:២៣:៥០]

**ស៖** ថាតើត្រឹមត្រូវទេ ដែលខ្ញុំថាអ្នកដែលត្រូវភៀសខ្លួននោះ គឺថាត្រូវតែទទួលខុសត្រូវខ្លួនឯងចំពោះចំណីអាហារទឹក ក៏ដូចជារបស់របរចាំបាច់មួយចំនួន ដើម្បីឲ្យខ្លួនអាចរស់រានមានជីវិតបានក្នុងពេល ដែលខ្លួនធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញនោះ អ៊ីចឹងទេ?

**ឆ៖** ត្រូវហើយអាហ្នឹង។ ត្រូវតែត្រៀមទៅខ្លួនឯង អង្ករ បាយអីដាក់ខ្លួនឯង គ្មានអង្គការអីណាជួយយកទៅទេ។ ដឹងស្រាប់ហើយអាពត ហ្នឹង។

**ស៖** ខ្ញុំចង់ត្រឡប់ចូលទៅប្រធានបទមួយដែលលោកបានឆ្លើយទៅសហការីរបស់ខ្ញុំ គឺការប្រឹងប្រែងរកទីកន្លែង និងកំណត់អត្តសញ្ញាណទាហាន លន់ នល់ ក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោកបានរៀបរាប់រួចមកហើយ អំពីការផ្សាយសំឡេង ដើម្បីបញ្ឆោតឱ្យ -- ដើម្បីបញ្ចុះបញ្ចូលឱ្យទាហាន លន់ នល់ ចុះចាញ់នោះ។ តើលោកអាចបញ្ជាក់ជូនតុលាការបានទេ ថាតើ -- បាទខ្ញុំ--

**លោក ឌេល លីសាក់៖**

លោកប្រធានប្រហែលជាខ្ញុំសូមការអនុញ្ញាតអាននូវផ្នែកមួយនៃចម្លើយរបស់សាក្សី។ បាទ ខ្ញុំសូមបង្ហាញនូវ ERN ជាភាសាខ្មែរ 00205058, អង់គ្លេស 00223346, ERN ជាភាសាខ្មែរ 00 -- ជាភាសាបារាំង 00705378។

[១០:២៦:១៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ នៅចម្លើយរបស់លោកត្រង់ផ្នែកនេះ លោកបានរៀបរាប់ថា “បន្ទាប់ពី ៧ ទៅ ១០ ថ្ងៃ គឺគេបានរៀបចំមីក្រូបំពងសំឡេងផ្សាយ” ហើយសូមដកស្រង់ “សម្រាប់អ្នកណាដែលឋានៈប៉ុនណាក៏ដោយ នៅទីណាក៏ដោយសូមឱ្យទៅកាន់អង្គភាពដើមរបស់ខ្លួន” បញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកលោកបាននិយាយតទៅទៀតថា “អ្នកទាំងនោះ គឺបានស្លាប់”។ សំណួរដែលខ្ញុំចង់សួរបញ្ជាក់នេះគឺថាតើទាហាន លន់ នល់ ទាំងអស់ដែលគេកំណត់អត្តសញ្ញាណបាទនោះ ត្រូវបានគេសម្លាប់ ឬក៏គេសម្លាប់តែទាហានណាដែលមានឋានន្តរស័ក្តិក្នុងកម្រិតណាមួយនោះ?

**លោក ស៊ុំ ជា៖**

**ឆ៖** អានេះឱ្យទាហាន មិនប្រកាន់ថាឋានៈ មិនចាំបាច់ថាឋានៈទេ យកសម្លាប់ទាំងអស់។

**ស៖** ហើយបន្តមកផ្នែកខាងក្រោមនៃកិច្ចសម្ភាសន៍របស់លោកជាមួយខាងសហចៅក្រមស៊ើបអង្កេតអំពីការព្យាយាមស្វែងរកទាហាន លន់ នល់ លោកក៏បានបញ្ជាក់ផងដែរថា “អ្នកខ្លះចង់រស់នៅហើយចង់លាក់បាំងការពិត ប៉ុន្តែពួកគាត់ត្រូវបានចាប់ ពីព្រោះថាគេធ្វើការស្រាវជ្រាវ ហើយរកឃើញតាមរយៈការធ្វើប្រវត្តិរូប” សូមបញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំដែលចង់សួរលោក គឺថាតើគេធ្វើបែបណា ដើម្បីឱ្យដឹង ដើម្បីរកឱ្យឃើញថាអ្នកណាខ្លះជាទាហាន លន់ នល់ ហើយត្រូវបានគេចាប់ខ្លួនតាមរយៈការធ្វើប្រវត្តិរូបនោះ?

[១០:២៨:៣៤]

**ឆ៖** អាហ្នឹងគេស្រែកតាមមីក្រូ។ បើអ្នកឯងចង់បានធ្វើការវិញ អ្នកស័ក្តិប៉ុន្មាន ស័ក្តិ៥ ឬស័ក្តិ៣, ស័ក្តិ២ ហ្នឹងឲ្យចូលមកធ្វើការវិញ។ គេដាក់មីក្រូអ៊ីចឹង។

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់ទៅលើចំណុចនេះ។ តើលោកដឹងដែរឬទេ ថាតើប្រជាជនទាំងអស់ដែលគេជម្លៀសពីទីក្រុងភ្នំពេញ ត្រូវតម្រូវឲ្យគេធ្វើ -- ត្រូវគេតម្រូវឲ្យធ្វើប្រវត្តិរូបគ្រប់គ្នា ឬក៏អត់ទេ?

**ឆ៖** អត់ទេ។ ខាងក្រោយខ្ញុំអត់ដឹង ដឹងតែខាងទ័ពខាងមុខ។ ប្រជាជន ខ្ញុំអត់ដឹងទេ និងទាហាន លន់ នល់ ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** លោកក៏បានបញ្ជាក់នៅក្នុងចម្លើយជាមួយនឹងខាងសហចៅក្រមស៊ើបអង្កេតផងដែរ គឺមានលេខឯកសារយោងដែលមាន ERN ខ្មែរ 00205058, ភាសាអង់គ្លេសគឺមានលេខ 00223346, ហើយភាសាបារាំងគឺមានលេខ 00705378។ លោកបានបញ្ជាក់ថា "ទាហាន លន់ នល់ ដែលត្រឡប់មកកន្លែងទីតាំងរបស់គេ បន្ទាប់ពីមានការផ្សព្វផ្សាយហ្នឹង ត្រូវបានគេចាប់ដាក់ឡានក្រុង ហើយយកទៅសម្លាប់នៅព្រៃកញ្ចៅ"។ តើលោកដឹងថា មាននរណាខ្លះដែលចូលរួមនៅក្នុងការសម្លាប់នេះដែរ -- សំណួរដែលខ្ញុំចង់សួរលោកគឺថា តើលោកដឹងថា ព្រៃកញ្ចៅហ្នឹងនៅទីកន្លែងណាដែរទេ?

**ឆ៖** ឮពួកហ្នឹងនិយាយថា ខាងលិចព្រៃកញ្ចៅ ប៉ុន្តែមិនដឹងខាងណា នៅខាងលិចហ្នឹង។ ឈ្មោះ គឿន ហ្នឹងអ្នកប្រាប់។ គឿន ហ្នឹងដែដល់។

**ស៖** លោកបានបញ្ជាក់ថា បុគ្គលដែលចូលរួមនៅក្នុងការសម្លាប់ហ្នឹងបានប្រាប់លោកអំពីការណ៍នេះ គឺលោកនិយាយថា ឈ្មោះ គឿន ដែលជាអ្នកប្រាប់លោក។ តើមានទាហានណាផ្សេងទៀត មកពី

កងវរសេនាតូចរបស់លោក បានចូលរួមនៅក្នុងការសម្លាប់នេះដែរឬទេ?

[១០:៣២:០៤]

**ឆ៖** បាទ មានឈ្មោះគឿន ហ្នឹងមួយទេ។ គាត់ហ្នឹងដែដល់។

**ស៖** តើលោកដឹងថា មានទាហានកងពលដទៃទៀតចូលរួមនៅក្នុងក្រុមអ្នកសម្លាប់មនុស្សនេះដែរឬទេ ឬមួយក៏មានតែ គឿន ម្នាក់នេះទេ?

**ឆ៖** បាទ មានច្រើន ប៉ុន្តែខ្ញុំមិនដឹងកងពលណាៗ អត់ដឹង។ ព្រោះយកឡាន -- គឿន ថាយកឡានទៅប្រហែលជា១០ ប្រមូលតាំងពីស្ពាន់មករហូត រហូតដល់ព្រៃកក្ដាម។ អាហ្នឹងប្រជាជនកំពុង

ជម្លៀសទៅហើយហ្នឹង។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានដែរឬទេថា ការសម្លាប់នេះកើតឡើងប្រហែលជាប៉ុន្មានដែរ តើក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហ្នឹង គឺប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ ដែលមានការសម្លាប់មនុស្សនៅព្រៃកញ្ចៅនេះ។ តើលោកអាចប្រាប់បានដែរឬទេ?

**ឆ៖** ល្បាក់ទាហានហ្នឹងប្រហែលជា១ថ្ងៃ, ១ថ្ងៃមួយយប់ហ្នឹងប៉ុណ្ណឹង មិនយូរទេ រហ័សដែរ។ ព្រោះទាហានវាចេញទៅតាមពោធិ៍ចិនតុង ទៅគ្រប់មុខសញ្ញាទាំងអស់ ទាំងទាហាន ទាំងប្រជាជនហ្នឹង មិនមែនចេញតែ -- ចេញមួយមុខហ្នឹងទេ។ ប៉ុន្តែខាងឧត្តរហ្នឹងវាទទួលតាមព្រៃកក្តាម តាមអីហ្នឹង ផ្លូវដែលចេញទៅរួច មួយចំហៀងខាងហ្នឹង។ ខាងកើតទន្លេទៅបូព៌ាទៅ។ អ៊ីចេះទៅនិរតីទៅ។ ចែកទៅតាមមុខព្រួញ។

[១០:៣៤:៣៧]

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហានៅក្នុងការបកប្រែ ឬក៏ការសួររបស់ខ្ញុំហើយមើលទៅ គឺលោកបាននិយាយអំពីហេតុការណ៍មួយដែលគេចាប់ទាហាន លន់ នល់ ដាក់ឡាន ហើយយកទៅសម្លាប់ចោល។ យកទៅសម្លាប់នៅជិតព្រៃកញ្ចៅ។ តើការសម្លាប់ទាហាន លន់ នល់ នៅជិតព្រៃកញ្ចៅហ្នឹងកើតឡើងនៅពេលណាដែរ?

**ឆ៖** នៅដែលថ្ងៃដែលដាច់ភ្នំពេញបាន ៥ថ្ងៃហ្នឹង ប៉ុន្តែមិនដឹងថ្ងៃខែប៉ុន្មាន ប៉ុន្តែដឹង៧៥ហ្នឹងដែរដាច់ភ្នំពេញ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ឥឡូវនេះខ្ញុំចង់អានឲ្យសាក្សីស្តាប់នូវចម្លើយរបស់អតីតទាហានមួយរូបទៀតដែលផ្តល់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត នៅឯកសារដែលមានលេខ D166/117។ នេះគឺជាកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត ដែលធ្វើនៅថ្ងៃ០៦ ខែមីនា ឆ្នាំ២០០៩។ ខ្ញុំគិតថាសាក្សីនេះមិនត្រូវបានគេកោះអញ្ជើញឲ្យមកបង្ហាញសក្ខីកម្មនៅទីនេះទេ ប៉ុន្តែឈ្មោះគាត់មាននៅក្នុងកំណត់ត្រា។ ហើយខ្ញុំនឹងបង្ហាញឈ្មោះសាក្សី -- ខ្ញុំនឹងមិនបង្ហាញឈ្មោះសាក្សីនេះទេ ប៉ុន្តែខ្ញុំចង់សួរថាតើៗគួរ -- ប៉ុន្តែជាទូទៅគឺយើងអាចផ្តល់សាក្សីនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយនេះ។ ដូច្នេះប្រសិនបើលោកប្រធានមិនអនុញ្ញាត -- មិនជំទាស់ទេ ខ្ញុំសូមអនុញ្ញាតផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយហ្នឹងទៅមេធាវីដើម្បីជួយដល់សាក្សី ពិនិត្យមើលទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ហើយនៅ

ពេលនោះខ្ញុំនឹងធ្វើការអាននូវកិច្ចសម្ភាសន៍ជាមួយសាក្សីរូបនោះ។

[១០:៣៧:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៧:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រី។ សូមជម្រាបសួរលោកទាំងអស់ដែលនៅក្នុង និងខាងក្រៅសវនាការ។

ខ្ញុំមិនជំទាស់ទៅលើអ្វីដែលខាងព្រះរាជអាជ្ញាចង់បន្តនោះទេ។ ប៉ុន្តែកាលពីសប្តាហ៍មុនគឺថាខាងគាត់បានជំទាស់ទៅលើបញ្ហាប្រហាក់ប្រហែលគ្នានេះ ហើយនៅពេលដែលព្រះរាជអាជ្ញាមួយបានមកដល់ គាត់ប្រើប្រាស់នូវបច្ចេកទេសនេះ ប៉ុន្តែនៅពេលដែលខាងមេធាវីការពារក្តីគាត់ឡើង ព្រះរាជអាជ្ញាជំទាស់ទៅលើបញ្ហានេះ ទាក់ទងទៅនឹងលោក ហ្វីលីព ស្សូត។ ដូច្នេះ ខ្ញុំមិនជំទាស់ទៅលើសំណួរទេ ប៉ុន្តែវាគ្រាន់តែជាបញ្ហានៃវិធីសាស្ត្រ។ ហើយខ្ញុំគិតថា ប្រហែលជានៅពេលនោះគឺមេធាវីខាង នួន ជា គាត់ចង់លើកយកសៀវភៅរបស់ ហ្វីលីព ស្សូត ប៉ុន្តែខាងព្រះរាជអាជ្ញាបានជំទាស់ទៅលើការងារនេះ។

[១០:៣៨:២៦]

ដូច្នេះ ហើយគឺថាព្រះរាជអាជ្ញាគាត់ហាក់ដូចជាប្រើប្រាស់នូវវិធីទាំងពីរតែម្តង គឺថានៅពេលដែលគាត់ធ្វើ គាត់ធ្វើបាន ប៉ុន្តែនៅពេលដែលខាងមេធាវីការពារក្តីធ្វើ បែរជាមានអ្នកដទៃឡើងមកជំទាស់ទៅលើខាងមេធាវីការពារក្តីទៅវិញ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ ប្រសិនបើខ្ញុំចាំមិនខុសទេ បញ្ហាដែលមេធាវី កាណាវាស បាននិយាយ គឺនិយាយអំពីបញ្ហាដែលថា ទាក់ទងទៅនឹងលោក ហ្វីលីព ស្សូត ហើយលោក ហ្វីលីព ស្សូត គឺនឹងមកបង្ហាញខ្លួនក្នុងនាមជាសាក្សីនៅទីនេះ។ ដូច្នេះ អ្វីដែលខ្ញុំចង់អាននៅពេលនេះគឺជាចម្លើយរបស់សាក្សី គឺគិតថាវាជាបញ្ហាដែលខ្ញុំចង់លើកឡើងនូវឯកសារ ប៉ុន្តែអ្វីដែលគាត់និយាយនោះ គឺជាឯកសារទាក់ទងទៅនឹងលោក ហ្វីលីព ស្សូត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងព្រះរាជអាជ្ញា យកជូនសាក្សីប្រឹក្សា អ៊ំ! មេធាវីប្រឹក្សាពិនិត្យ និងណែនាំដល់សាក្សីក្នុងការមិនបង្ហាញអត្តសញ្ញាណ ឈ្មោះអ្នកនៅក្នុងឯកសារនោះ។

[១០:៣៩:៥០]

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:៤០:១៦]

**ស៖** អ្វីដែលខ្ញុំចង់ឲ្យលោកសាក្សីពិនិត្យមើល គឺចម្លើយរបស់សាក្សីនេះដែលបានបញ្ជាក់ថា គាត់នៅក្នុងកងវរសេនាតូច៣១ នៃកងពលធំ៣១០ ខាងពាយ័ព្យ ហើយមេបញ្ជាការវរសេនាតូចរបស់គាត់ គឺឈ្មោះ ហាក់ គឺមាននៅក្នុង ERN 00287535, ភាសាអង់គ្លេស គឺមានលេខ 00293364 ហើយភាសាបារាំងគឺមានលេខ 00355872 រហូតដល់ 355873។ ដោយមិនអានឈ្មោះបុគ្គលរូបនេះ។ តើលោកអាចប្រាប់បានដែរឬទេ ថាតើលោកស្គាល់ ឬក៏ចាំបុគ្គលដែលផ្តល់នូវចម្លើយនេះដែរឬទេ?

**ឆ៖** អត់ស្គាល់ផង។

**ស៖** ផ្នែកនៃចម្លើយរបស់គាត់ ដែលខ្ញុំចង់អានឲ្យលោកស្តាប់ គឺនៅ ERN ខ្មែរ 00287536, ភាសាបារាំងគឺមានលេខ 00355873 និងភាសាអង់គ្លេសគឺមានលេខ 00293365។ ហើយបុគ្គលរូបនេះពណ៌នាអំពីការចូលទៅក្នុងសមរភូមិនៅក្នុងថ្ងៃ១៦ ខែមេសា ឆ្នាំ៧៥ ហើយនៅពេលនោះ គឺគាត់ត្រឡប់មកកងពលរបស់គាត់នៅក្នុងខែឧសភា ឆ្នាំ៧៥ ដែលមានទីតាំងនៅវត្តភ្នំ ហើយគាត់បានដឹងនូវព័ត៌មានដូចតទៅនេះ។ ខ្ញុំសូមដកស្រង់ "នៅពេលនោះ នៅក្នុងខែឧសភា ឆ្នាំ៧៥ ខ្ញុំដឹងថាមានបញ្ជាមួយពី សុន សេន ដែលជាអ្នកគ្រប់គ្រង ឲ្យទៅចាប់មនុស្សដែលជាអ្នករាជការមានឋានៈ ឋានន្តរស័ក្តិធំៗរបស់របបរ លន់ នល់ ហើយដែលមិនព្រមចាកចេញពីទីក្រុងភ្នំពេញ ព្រមទាំងអ្នកជំងឺដែលជាទាហាន លន់ នល់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា។ ខ្ញុំប្រកែកមិនចូលរួម តែខ្ញុំដឹងហេតុការណ៍កើតឡើង ដោយសារតែខ្ញុំជាប្រធានកងអនុសេនាធំលេខ៣ របស់កងពល៣១០។ អ្នកដែលចូលរួមចាប់មនុស្សនោះ បាននិយាយប្រាប់ខ្ញុំផ្ទាល់ថា គេចាប់មន្ត្រី លន់ នល់ យ៉ាងច្រើន និងអ្នកបម្រើរបស់ពួកគេពីភ្នំពេញយកទៅវៃសម្លាប់ទម្លាក់ក្នុងអណ្តូងនៅតំបន់ទួលគោក"។ សូមបញ្ចប់ការដក

ស្រង់។ តើលោកអាចប្រាប់ខ្ញុំបានដែរឬទេថា តើលោកធ្លាប់ឮអំពីការចាប់ខ្លួន និងការសម្លាប់មន្ត្រី លន់ នល់ និងទាហាន លន់ នល់ នេះដែរឬទេ?

[១០:៤៣:៥៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្ពើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមគាំទ្រទៅលើអ្វីដែលមេធាវី កាណាវាស បាននិយាយ ព្រោះថាបញ្ហានេះ គឺយើងមានកើតឡើងកាលពីសប្តាហ៍មុននៅពេលដែលខ្ញុំសួរសាក្សី ហើយនៅពេលនោះ គឺចៅក្រម ឡាវែន៍ គាត់បាននិយាយអំពីបញ្ហាទាក់ទងទៅនឹងការដកស្រង់កំណត់ហេតុរបស់សាក្សី ដែលសាក្សីគាត់មិនបានដឹង គឺមិនបានឃើញដោយផ្ទាល់។ ការនេះគឺមិនត្រឹមត្រូវទេ។ ចៅក្រម ឡាវែន៍ បានសម្រេចថា មិនអាចធ្វើបែបនេះបានទេ។ គឺយើងអាចចោទសួរសំណួរដោយចំហទាក់ទងតែទៅនឹងបទពិសោធន៍ដែលគាត់បានដឹងនោះ មិនអាចយកអ្វីដែលបានចោទសួរ ដែលបានឆ្លើយនៅក្នុងចម្លើយរបស់សាក្សីនោះទេ។ កាលពីសប្តាហ៍មុន គឺខាងព្រះរាជអាជ្ញាជំទាស់បែបនេះមែន។ ហើយនៅពេលនោះគឺយើងមិនជំទាស់ទេ។ ប៉ុន្តែឥឡូវនេះ គឺដូចដែលមេធាវី កាណាវាស បានលើកឡើងអ៊ីចឹង គឺយើងហាក់ដូចជាមានវិធានផ្សេងគ្នា យកមកប្រើប្រាស់នៅពេលនេះ។ ដូច្នេះ ខ្ញុំចង់ឲ្យខាងព្រះរាជអាជ្ញាគោរពទៅតាមគោលការណ៍ ទៅតាមច្បាប់ដែលបានអនុវត្តដូចគ្នា ដោយចោទសួរទៅលើបទពិសោធន៍ផ្ទាល់របស់សាក្សី។ បើសិនជាគាត់មិនចាំទេ យើងអាចរំឭកទៅលើអ្វីដែលគាត់ចាំ។ ដូច្នេះយើងមិនគួរនិយាយទៅលើអ្វីដោយផ្ទាល់នោះទេ។ មិនគួរអានដោយផ្ទាល់នោះទេ យើងគួរតែគោរពទៅតាមច្បាប់ដែលបានអនុវត្ត។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេបលោកប្រធាន។ បញ្ហាដែលយើងនិយាយគឺថា យើងមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីចោទសួរសាក្សីរូបនេះអំពីចម្លើយតបរបស់សាក្សីដទៃទៀត។ ខ្ញុំយល់ស្របថានៅក្នុងស្ថានភាពមួយប្រសិនបើខ្ញុំអានចម្លើយមួយដែលសាក្សីគាត់អត់ដែលដឹង អត់ដែលជាប់ពាក់ព័ន្ធអីសោះអាហ្នឹងវាជាបញ្ហាមួយ។ ប៉ុន្តែសាក្សីដែលផ្តល់ចម្លើយដែលខ្ញុំអានហ្នឹង គឺគាត់មកពីកងវរសេនាតូច

ជាមួយគ្នា គឺកងវរសេនាតូចដែលដឹកនាំដោយ ហាក់ ជាមួយគ្នា ហើយគាត់បានផ្តល់ -- ហើយសាក្សីបាននិយាយអំពីការសម្លាប់ទាហាន លន់ នល់ រួចទៅហើយ។

[១០:៤៦:១៧]

ដូច្នេះ ខ្ញុំគ្រាន់តែបង្ហាញនូវព័ត៌មានមួយទៀតដែលទាក់ទងទៅនឹងការសម្លាប់ខាងទាហាន លន់ នល់ ដែលមកពីសាក្សីមួយរូបទៀតដែលក្នុងកងវរសេនាតូចជាមួយគ្នា។ ដូច្នេះខ្ញុំគ្រាន់តែចង់ឲ្យសាក្សីរូបនេះបញ្ជាក់ថា តើគាត់បានដឹង ឬក៏អត់? នេះគឺជាស្ថានភាពមួយផ្សេងគ្នា គឺខុសពីអ្វីដែលមេធាវីការពារក្តីបានលើកឡើង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីមានបញ្ហាអីទៀតទេ? បើមិនមានទេ យើងនឹងសម្រេចលើបញ្ហានេះ។ មិនគប្បីនិយាយបញ្ហាដដែលទេ ហើយមិនមានឲ្យឆ្លើយតបពីរដងទេ នេះយើងបានកំណត់គ្នារួចហើយលើនីតិវិធីនៃការ ដំណើរការនីតិវិធីដេញដោលនៅទីនេះ។

**លោក ហ្សាស្តេី ប៉ោះ៖**

ខ្ញុំសូមគោរពទៅតាមសេចក្តីសម្រេចរបស់លោកប្រធាន។ ហើយខ្ញុំនឹងអនុវត្តតាមការសម្រេចនេះ។

[១០:៤៧:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥២:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះទេ។ ដោយសារសំអាងលើឯកសារ E1/59 ទំព័រ៣០ ជាភាសាខ្មែរ ដែលបានសម្រេចរួចហើយលើបញ្ហានេះ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគី យកចម្លើយផ្សេងទៀតដោយយកមកដកស្រង់សួរដេញដោលចំពោះសាក្សីមួយផ្សេងទៀតទេ។ មេធាវី ឬក៏ភាគីអាចចោទសំណួរទូទៅផ្អែកលើខ្លឹមសារដែលខ្ញុំបានយល់ដឹងដោយសារការអាននូវឯកសារ ដែលជាសំអាងនៅក្នុងការសួរនោះបាន។ នេះជាអ្វីដែលយើងបានសម្រេចហើយ ហើយរឿងដដែលមិនគួរឲ្យមានដដែលជាដដែលដូច្នេះទេ។

បញ្ហាមួយទៀត គឺសូមរំឭកថាអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីប្រើប្រាស់នូវកំណត់ហេតុរបស់សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅពេលខាងមុខ ដើម្បីតាំងសំណួរដល់សាក្សីដែលកំពុងផ្តល់សក្ខី-កម្មនោះទេ។ នេះបញ្ហាប្រៀបធៀបទៅនឹងករណីដែលកើតមានឡើងចំពោះអ្នកជំនាញ ដែលអង្គជំនុំជម្រះគ្រោងថា នឹងអញ្ជើញគាត់មកផ្តល់សក្ខីកម្ម គឺ ហ្វីលីព ស្សត ដែលមានបញ្ហាលើកឡើងនេះ។

[១០:៥៣:២៤]

អ៊ីចឹងបញ្ហានេះ ដោយសារមូលហេតុ អង្គជំនុំជម្រះមានកាលវិភាគក្នុងការកំណត់ផែនការកោះហៅអ្នកជំនាញរូបនោះមកផ្តល់សក្ខីកម្ម។ អ៊ីចឹងហើយបានជាមានបញ្ហាដែលអង្គជំនុំជម្រះពឹងផ្អែកទៅលើអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ប្រតិចារឹកសវនាការថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២។

លោកតំណាងសហព្រះរាជអាជ្ញាបើសិនជាសំណួរអ្វី គឺអាចសួរបាន តែមានលក្ខណៈជាសំណួរទូទៅប៉ុណ្ណោះ មិនអាចដកស្រង់នូវសក្ខីកម្មសាក្សីដទៃទៀត ដែលមិនកោះហៅមកផ្តល់សក្ខីកម្មមកសួរសាក្សីនេះបានទេ។

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានអ្វីបញ្ជាក់បន្ថែមទេ លើអ្វីដែលបានកត់សម្គាល់ដោយសំអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលសម្រេចដោយលោកកាលពីសប្តាហ៍មុន គឺមានភាពពាក់ព័ន្ធ និងបង្កើតជាបញ្ហាដែលធ្វើឲ្យមានបញ្ហាចម្រូងចម្រាសរហូតដល់ថ្ងៃនេះ។

[១០:៥៤:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ស្ថានភាពថ្ងៃនេះហាក់ដូចជាខុសប្លែកបន្តិចបន្តួចពីស្ថានភាពដែលអង្គជំនុំជម្រះបានសម្រេចកាលពីសប្តាហ៍មុន។ កាលពីសប្តាហ៍មុននោះ គឺមានការយោងទៅលើការវិភាគរបស់សាក្សីដែលជាអ្នកជំនាញខាងប្រវត្តិសាស្ត្រ ដែលនឹងមកផ្តល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះនេះ។ ដូច្នេះ វាមិនសមស្របទេ ក្នុងការយោងទៅលើការវិភាគរបស់សាក្សី អ្នកជំនាញរូបនេះ។

ថ្ងៃនេះ សំណួរដែលបានសួរដោយសហព្រះរាជអាជ្ញា បានយោងទៅលើហេតុការណ៍មួយ ដែលជាហេតុការណ៍លើកឡើងដោយសាក្សី។ នេះមិនមែនជាការវិភាគទេ គឺវាជាការយោងទៅលើហេតុ-ការណ៍ដែលសាក្សីបានឆ្លើយ។ ដូច្នេះ សហព្រះរាជអាជ្ញា សូមរៀបចំសំណួរជាលក្ខណៈទូទៅ ក្នុងការសួរទៅលើសាក្សី ដើម្បីឲ្យគាត់ឆ្លើយអំពីការដឹងឮរបស់គាត់ផ្ទាល់ទៅលើហេតុការណ៍ ដែលយើងចង់ចោទសួរនេះ។

[១០:៥៦:១៧]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាកុំអាលទាន់ឆ្លើយ អ៎! កុំអាលទាន់តាំងសំណួរ!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ៅ៖**

ខ្ញុំមិនចង់ឲ្យមានបញ្ហាស្មុគស្មាញទេ ប៉ុន្តែប្រហែលជាខ្ញុំត្រូវការការណែនាំទៅលើបញ្ហាដែលខ្ញុំបាននិយាយយោងរួចមកហើយ គឺថា អ្វីដែលខ្ញុំចង់និយាយមិនមែនសំដៅតែទៅលើសក្ខីកម្មរបស់អ្នកជំនាញ ហ្វីលីព ស្ហូត នោះទេ។ ក៏ប៉ុន្តែ ខ្ញុំនិយាយយោងទៅលើលោក -- សក្ខីកម្មរបស់លោក ហេង សំរិន ដែលខ្ញុំចង់ចោទសួរទៅលើសាក្សី។ ប៉ុន្តែនៅពេលនោះគឺមានការជំទាស់។ នេះគឺជាអ្វីដែលខ្ញុំចង់និយាយ គឺអំពីសក្ខីកម្មរបស់បុគ្គលដទៃទៀត ដែលមិនមែនជាអ្នកជំនាញ។ ដូច្នេះហើយ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះហាក់ដូចជាមិនច្បាស់លាស់ទេចំពោះបញ្ហាមួយនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា អាចតាំងសំណួរចុងក្រោយមួយសំណួរទៀត!

សំណួរចុងក្រោយអំមិញលោកមានបំណងចង់សួរទេ ឬក៏អត់ទេ?

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមសួរសំណួរផ្សេងទៀត។ ដោយសារផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដូច្នេះថាតើយើងគួរតែសម្រាកនៅពេលនេះ ឬមួយក៏យ៉ាងម៉េច? ខ្ញុំគិតថា ប្រហែលជាខ្ញុំត្រូវការពេលវេលាប្រហែល ១០នាទី។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់។ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ ដល់សាក្សី និងមេធាវីប្រឹក្សាសាក្សី គឺលោក លឹម ប៊ុនហេង នៅបន្ទប់រង់ចាំសាក្សី និងអ្នកជំនាញ ហើយឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងកំណត់អម្បាញ់មិញនេះ គឺម៉ោងដប់មួយ ដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៥៨ នាទី ដល់ម៉ោង១១:២៣ នាទី)*

[១១:២៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរប្រហែលជាពីរបីសំណួរតែប៉ុណ្ណោះ។ មុនពេលដែលខ្ញុំប្រគល់វេទិកាជូនទៅខាងដើមបណ្តឹងរដ្ឋប្បវេណី។ ពីព្រឹកនេះ លោកបានពណ៌នាប្រាប់យើងអំពីការសម្លាប់ទាហាន លន់ នល់ ដែលកើតឡើងនៅព្រែកផ្តៅ។ តើលោកដឹងថា មានការសម្លាប់ទាហាន លន់ នល់ ឬក៏មន្ត្រី លន់ នល់ នៅទួលគោកដែរឬទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** មានតែទាហាន លន់ នល់ ទេ។ រឿងមន្ត្រីរឿងអី អត់។ ប្រជាជនអីអត់ អត់ឃើញមាន។

[១១:២៤:៥៩]

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ថាតើតាមដែលលោកចាំ ពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាន លន់ នល់ ហ្នឹង តើវាមានអ្វីកើតឡើងនៅពេលនុំង?

**ឆ៖** អាហ្នឹង ដែលគេធ្វើនយោបាយដាក់មីក្រូទៅឃោសនា ថាអ្នកធ្វើបុណ្យស័ក្តិអី ឲ្យចូលមកធ្វើការវិញ អាត្រង់ហ្នឹង ដែលមានមូលហេតុនោះ។

**ស៖** ផ្នែកចុងក្រោយដែលខ្ញុំចង់សួរលោក គឺពាក់ព័ន្ធទៅនឹងមេបញ្ជាការវរសេនាតូចរបស់លោកគឺ បងហាក់។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើកិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សីរបស់លោក គឺ

ឯកសារដែលមានលេខ 00205058, ភាសាអង់គ្លេស គឺមានលេខ 00223347, និងភាសាបារាំង គឺមានលេខ 00705379។ ហើយនៅក្នុងផ្នែកនៃការសម្ភាសរបស់លោកនេះ លោកបានបញ្ជាក់ថា “ហាក់ បន្ទាប់មក ឡើងក្លាយខ្លួនទៅជាវរសេនាធំ ទទួលបន្ទុកខាងទ័ពអាកាសនៅពោធិ៍ចិនតុង។ ហើយបន្ទាប់ពីនោះមក គាត់ក្លាយទៅជាមេដឹកនាំទាហាន ដែលត្រូវបានគេយកទៅបោសសម្អាត”។ តើលោកអាចប្រាប់បានដែរឬទេ ថានៅពេលណាដែល បងហាក់ ត្រូវបានគេដំឡើងទៅជាប្រធានវរសេនាធំ ទទួលបន្ទុកខាងទ័ពអាកាស ខាងយន្តហោះ នៅពោធិ៍ចិនតុងនោះ?

**ឆ៖** ឮតាមកងៗ គ្នាឯង ថាគាត់ហ្នឹង ឡើងហើយ ឡើងទៅវរសេនាធំ ខាងកប៉ាល់ហោះ។ ឮតាមគេ។

[១១:២៧:៣២]

**ស៖** តើលោកដឹងដែរឬទេ ថាតើតួនាទីហ្នឹង គឺនៅក្នុងកងពលធំផ្សេងគ្នា ឬមួយក៏ជាមួយគ្នា?

**ឆ៖** ដឹងអាម៉េចទេអាហ្នឹង មិនដឹងគេដកទៅខាង -- ព្រោះដកផុតពីអង្គភាពទៅហើយ ឲ្យទៅធ្វើកាន់ខាងកប៉ាល់ហោះហ្នឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់ត្រាសម្រាប់កំណត់ត្រាប្រតិចារឹកខាង អូ.ស៊ី.ភី បានពិនិត្យមើលទៅលើបញ្ជីអ្នកទោស គឺE3/234 គឺមានឈ្មោះរបស់ អៀង ហាក់ ដែលត្រូវបានគេកំណត់ថាជាប្រធានវរៈបី -- ជាប្រធានកងពល៣៤ ហើយជាសមាជិកកងពល៣១០។ ហើយខ្ញុំសូមបញ្ចប់ការចោទសួររបស់ខ្ញុំនៅថ្ងៃនេះ ហើយខ្ញុំសូមប្រគល់វេទិកានេះ ជូនទៅខាងតំណាងព្រះរាជអាជ្ញា សូមលោកប្រធានមេត្តាសម្រេច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំសូមនិយាយដោយសង្ខេប ដោយមិនចំណាយពេលវេលាច្រើន ទៅលើខាងព្រះរាជអាជ្ញា -- ខាងដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែ ខ្ញុំជំទាស់ចំពោះវិធីសាស្ត្រដែលខាងព្រះរាជអាជ្ញាបានប្រើប្រាស់ដែលចោទសួរសំណួរដដែលៗ ហើយចុងក្រោយអានអំពីបញ្ជីឈ្មោះអ្នកទោសនៅ ស-២១ ចូលទៅក្នុងកំណត់ប្រតិចារឹក។ ខ្ញុំមិនជំទាស់នោះទេ ប៉ុន្តែគេគួរតែធ្វើនៅពេលចុងបញ្ចប់នៃការផ្តល់សក្ខីកម្មទៅលើ

សាក្សីនេះ គឺនៅពេលដែលភាគីទាំងអស់ គាត់មានឱកាសដើម្បីសួរទៅលើសាក្សីរូបនេះ។

[១១:២៩:៤៥]

ដូច្នេះហើយការ -- នេះគឺជាការបង្ហាញអំពីបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ គឺជាការសំខាន់។ ហើយធ្វើដូច្នេះ ហាក់ដូចជាផ្តល់ព័ត៌មានបន្ថែមទៅដល់សាក្សី។ ដូច្នេះ ខ្ញុំស្នើដល់ខាងព្រះរាជអាជ្ញា ថាប្រសិនបើគាត់ចង់អានខាងព័ត៌មានទាក់ទងទៅនឹងបញ្ជីឈ្មោះអ្នកទោស ស-២១ គួរតែអាននៅពេលដែលសាក្សីបានបញ្ចប់សក្ខីកម្មទាំងអស់របស់គាត់។ គឺថានៅពេលមុនពេលដែលគាត់ចាកចេញពីបន្ទប់សវនាការ។ នេះគឺជាគោលជំហររបស់មេធាវីការពារក្តី។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខាងអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាស ប្រសិនបើខាងសាលាដំបូងអនុញ្ញាត ខ្ញុំនឹងធ្វើបែបនេះមែន។ ប៉ុន្តែនេះគ្រាន់តែជាប្រធានបទចុងក្រោយដែលខ្ញុំចង់កត់ត្រាចូលទៅក្នុងប្រតិចារឹក ទាក់ទងទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើអង្គជំនុំជម្រះសម្រេចថា ខ្ញុំត្រូវអានបញ្ជីអ្នកទោសហ្នឹងនៅពេលចុងបញ្ចប់នៃការផ្តល់សក្ខីកម្មរបស់សាក្សីហ្នឹង ខ្ញុំនឹងធ្វើបែបនេះបាន ប្រសិនបើអង្គជំនុំជម្រះតម្រូវឲ្យធ្វើបែបនេះ។

[១១:៣០:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣២:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអាចធ្វើដូច្នេះ ដូចអ្វីដែលតំណាងសហព្រះរាជអាជ្ញាបានធ្វើកន្លងមកនេះ ដោយមិនគប្បីយកពេលវេលាផ្សេងទៀតទៅធ្វើទេ។ ហើយដោយសារការបង្ហាញហេតុផលនេះ គឺខាងភាគីចោទប្រកាន់គឺត្រូវលើកឡើងមុន ហើយប្រសិនបើភាគីដទៃទៀតហ្នឹងមានការជំទាស់តវ៉ាយ៉ាងណានោះ គឺជារឿងសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការអាចតវ៉ាបាននៅក្នុងអំឡុងពេលនៃការដំណើរការ ឬក៏ក្នុងពេលដែលខ្លួនមានពេលវេលាក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ឬក៏អ្នកជំនាញ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី។

បាទ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមានសំណួរ។

[១១:៣៣:៥៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សម្រាប់លោកសាក្សីរូបនេះ មេធាវីនាំមុខផ្ទេរសិទ្ធិទៅលោកស្រីមេធាវី ទី ស្រ៊ីនណា និងលោកស្រីមេធាវី នូស៊ីន សាកាវ៉ាទី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

ជាដំបូងនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល! សូមជម្រាបសួរលោកសាក្សី។

[១១:៣៤:៣០]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំមានសំណួរខ្លះដើម្បីតាំងសួរទៅលោក ហើយនិងសូមឲ្យលោកសហការក្នុងការបំភ្លឺជូនអង្គជំនុំជម្រះ ហើយនិងសូមធ្វើការវិលត្រឡប់ទៅខាងដើមបន្តិច ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅមុនឆ្នាំ១៩៧៥ ដែលលោកធ្លាប់បានដឹង បានឮ និងបានជួបប្រទះ។ ខ្ញុំសូមធ្វើការបញ្ជាក់បន្តិចថាតើនៅកាលដែលលោករស់នៅក្នុងព្រៃជាទាហានខ្មែរក្រហមហ្នឹង តើលោកចាំបានឬទេ ថាតើពេលនុ៎ងមានចំនួនប៉ុន្មានកងពលដែរ?

**ឆ៖** អត់ដឹងប៉ុន្មានកងពល អត់ដឹង។

**ស៖** ចុះលោកមានដឹងពីទំនាក់ទំនងរវាងកងពលមួយ ទៅកងពលមួយទៀតទេ?

**ឆ៖** មួយជំនាន់ហ្នឹងក៏អត់ដឹងទេ។ គេតាមរយៈគេអ្នកធំៗ ឯងតូចៗ មិនឲ្យដឹង។

**ស៖** ចុះនៅពេលហ្នឹង គេមានបានបណ្តុះបណ្តាលទាហានតូចៗ ដូចជាពួកលោកអ៊ីចឹងទៅលើការវាយប្រយុទ្ធដើម្បីកម្ទេចខ្មាំង ឬក៏ដណ្តើមយកទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** អាហ្នឹងគេបណ្តុះបណ្តាលហើយ ដើម្បីគេរើសទ័ពឲ្យបានច្រើន ដើម្បីវ៉ៃ វ៉ៃបែកទីក្រុងភ្នំពេញ។

[១១:៣៦:២២]

**សៈ** តើពេលនោះគេបណ្ដុះបណ្ដាលយ៉ាងម៉េចដែរ?

**ផៈ** ក្នុងការរៀនសូត្រ ក្នុងការរើសទ័ព ក្នុងការបំផុសឲ្យឈឺចាប់ អាមេរិកាំងទម្លាក់គ្រប់បែក ទម្លាក់អីដើម្បីធ្វើអីចឹង ឲ្យយើងឈឺចាប់ ឲ្យយើងចូលទ័ពឲ្យបានច្រើន។

**សៈ** ខ្ញុំសូមសួរលោកបន្តទៀត លោកថា គេមានការបំផុសឲ្យមានការឈឺចាប់។ តើលោកអាចចាំបានឬទេ ថាតើកាលនុ៎ង នរណាគេជាអ្នកបំផុសឲ្យមានការឈឺចាប់នោះ?

**ផៈ** តារឿង អីហ្នឹង និងមេឃុំ មេអី តាមសង្កាត់ហ្នឹងគេអ្នកបំផុស ដោយសារអាមេរិកាំងវាទម្លាក់គ្រប់បែក ឆេះផ្ទះ ឆេះសម្បែង។

**សៈ** យោងតាមបទពិសោធន៍របស់លោក ខ្ញុំចង់សួរថា តើនៅពេលនុ៎ង គេមានបើកកិច្ចប្រជុំរវាងកូនចៅតូចៗ ដូចជាក្រុមរបស់លោកដែរឬក៏យ៉ាងម៉េចដែរ?

**ផៈ** នេះគេឲ្យរៀនសូត្រដែរ។

[១១:៣៨:០៥]

**សៈ** ចុះគេមានបានបណ្ដុះបណ្ដាលអំពីការកំណត់គោលដៅខ្មាំងដែរឬទេនៅពេលនោះ?

**ផៈ** គេធ្វើម៉េចឲ្យតែយើងឈឺចាប់ គេចែកមុខសញ្ញាគ្នាច្បាស់លាស់ ព្រោះខ្មាំងជាសត្រូវ ខ្មាំងជាមិត្ត។

**សៈ** ក្រៅពីពួកអាមេរិក តើគេមានបានកំណត់ថា ក្រុម លន់ នល់ ហ្នឹងក៏ជាខ្មាំងដែរឬក៏យ៉ាងម៉េចដែរ?

**ផៈ** លន់ នល់ ហ្នឹងជាខ្មាំងពេញបន្ទុកហើយ សហការជាមួយអាមេរិកទម្លាក់គ្រាប់បែក។

[១១:៣៩:២២]

**សៈ** ចុះលោកមានដែលឃើញថ្នាក់ដឹកនាំណាដែលទៅ -- ធ្លាប់មានឃើញ ឬក៏ជួបប្រទះនូវថ្នាក់ដឹកនាំណាដែលទៅតំបន់របស់លោកដែរទេនៅពេលនោះ?

**ផៈ** មានទៅដែរ ប៉ុន្តែមិនស្គាល់។ វាទៅបំផុស វាធ្វើចលនាហ្នឹងទៅបំផុស។ មានទៅ ប៉ុន្តែអត់ស្គាល់។

**ផៈ** អីចឹងលោកមានធ្លាប់ដឹង ឬក៏ឮថា ឮគេប្រកាសថា លោក ប៉ុល ពត, នួន ជា, អៀង សារី ឬក៏ ខៀវ សំផន អីមានតួនាទីអីដែរនៅក្នុងរបបនោះ អ៎! នៅក្នុងអំឡុងពេលដែលលោករស់នៅក្នុងព្រៃ លោកមានដែលធ្លាប់ដឹង ឬក៏ឮអំពីឈ្មោះពួកគាត់ដែរឬទេ?

**ធ៖** អត់ដែលមានឮផង ឮតែរើឲ្យសម្តេចសីហនុ មួយជំនាន់នុ៎ង ចូលព្រៃម៉ាគី។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់តែចំណុចនេះបន្តិចទេ។ ឥឡូវខ្ញុំសូមសួរលោកដោយពាក់ព័ន្ធជាមួយនឹងឆ្នាំ១៩៧៥តែម្តង។ ប៉ុន្តែខ្ញុំសូមបកបន្តិច មុនឆ្នាំ៧៥បន្តិចបន្តួចហ្នឹង តើនៅៗតំបន់របស់លោកហ្នឹង គេមានប្រជុំរៀបចំផែនការវាយយកទីក្រុងភ្នំពេញដែរឬទេ?

**ធ៖** អាហ្នឹងគេប្រជុំ ទៅរើខ្សែក្រវាត់នៅបាសិតហ្នឹង រើចូលទីក្រុងភ្នំពេញ។

**ស៖** តើអ្នកណាដែរ ដែលជាអ្នកដឹកនាំប្រជុំនៅពេលនោះ?

[១១:៤១:៤១]

**ធ៖** បាទ បងហាក់។

**ស៖** នៅពេលដែលលោក ហាក់ គាត់ដឹកនាំប្រជុំប្រាប់លោកអំពីផែនការហ្នឹង តើលោកមានដឹងទេថា គាត់ចេញ -- កើតចេញពីឆន្ទៈរបស់គាត់ក្នុងការវាយយកតែម្តង ឬក៏គាត់ទទួលបញ្ជាពីថ្នាក់លើដែរ ឬក៏យ៉ាងម៉េចដែរ? លោកអាចចាំបានដែរឬទេ?

**ធ៖** អានេះគាត់ គឺបញ្ជាពីថ្នាក់លើ ព្រោះគាត់ ត្រឹមវរសេនាតូចគឺមិនអាចអត្តនោម័តិរើនៅបន្ទាយមួយៗបានទេ ទាល់តែសហការគ្នាគ្រប់វរៈ គ្រប់កងពលទាំងអស់បានរើបាន។ នេះបញ្ជាមកពីថ្នាក់លើហើយ។

**ស៖** តើពេលនុ៎ងគាត់មានប្រាប់លោក ឬក៏ប្រាប់ទៅក្រុមតូចៗ ក្រុមកូនចៅហ្នឹងថា ថ្នាក់លើហ្នឹងគេឲ្យយើងធ្វើអីគេខ្លះៗ គាត់មានប្រាប់ថា ជា -- តើគាត់មាននិយាយអីខ្លះចំពោះករណីហ្នឹងជូនដល់ប្រាប់ដល់ទាហានថ្នាក់ក្រោម? លោក -- ដូចជាសម្តីរបស់គាត់ហ្នឹង និយាយកាលនុ៎ងគាត់និយាយយ៉ាងម៉េចដែរ?

[១១:៤៣:១៧]

**ធ៖** និយាយកាលនុ៎ងពាក្យគាត់ឲ្យហាត់ៗ មួយខែជាងហ្នឹង គឺថាឡើងរើយកបាសិតឲ្យបាន គឺដាច់ហើយភ្នំពេញ។ គ្រាន់តែថា ប៉ុណ្ណឹង។ ខ្ញុំបានរៀនសូត្រអ៊ីចឹងទៅ។

**ស៖** ពេលដែលលោកវាយចូលមកទីក្រុងភ្នំពេញ ពេលនុ៎ងតាមផ្លូវលោក -- ក្រុមរបស់លោកមានប្រទះឃើញទាហាន លន់ នល់ ដែរឬទេ? ហើយពេលនុ៎ងពេលដែលប្រទះឃើញហ្នឹង តើក្រុមរបស់លោកមានប្រតិកម្មយ៉ាងម៉េចដែរ?

**ធ៖** ចូលមកដល់ទីក្រុង អត់មានឃើញទាហាន លន់ នល់ អីអត់ឃើញ។ ឃើញតែប្រជាជន

ទាំងអស់តែម្តង។ ឃើញតែពាក់ខោអាវធម្មតា ហើយនិងកាំភ្លើងទុកតាមថ្នល់រប៉ាយអ៊ីចឹងទៅ។ មានឃើញប៉ុណ្ណឹង អារឿងឃើញទាហានឃើញអី អត់មានឃើញទេ។

**ស៖** សូមអរគុណលោក។ កាលពីព្រឹកមិញហ្នឹងលោកបានជម្រាបទៅខាងសហព្រះរាជអាជ្ញាថា ពេលដែលលោកចូលមកដល់គឺមានការប្រកាសឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំចង់សួរថា ក្រៅពីមធ្យោបាយនៃការប្រកាសប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញហ្នឹង តើលោកមាន -- តើគេមានប្រើមធ្យោបាយអីផ្សេងទៀត ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

[១១:៤៥:០៤]

**ឆ៖** អត់មានអីទេ មានតែដូចខ្ញុំនិយាយពីខាងដើមអ៊ីចឹង។ គ្រាន់ថាឲ្យចេញទៅឲ្យស្រួតទៅ ៤, ៥ ថ្ងៃទៀត សូមចូលត្រឡប់មកវិញ។ តែស្រួលមិនស្រួលហ្នឹង ផ្ទះទីក្រុងភ្នំពេញហ្នឹង ងាប់កូនចៅងាប់អស់ឥឡូវហើយ។ ប្រជាជនភ័យ ចេញមក គ្រាន់តែប៉ុណ្ណឹងមធ្យោបាយ។

**ស៖** តើពេលនោះមានការជួយយកអាសាពីកងទ័ពខ្មែរក្រហម ដើម្បីជួយប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** កាលនុ៎ងគ្មានបានជួយស្អីៗគាត់ទេ គ្រាន់តែប្រាប់គាត់ថាឲ្យចេញឲ្យរហ័សបន្តិចទៅ គ្រាន់តែប្រាប់ប៉ុណ្ណឹង។ ហើយគាត់ហ្នឹងក៏ចេញទាំងប្រពន្ធ ទាំងកូន អីទាំងអស់ ទាំងអ្នកជំងឺនៅដេកមន្ទីរពេទ្យអី អាកូនចៅហ្នឹង អូសរទេះយកទៅ ពិបាកវេទនា។

[១១:៤៦:២៣]

**ស៖** តើពេលនុ៎ងមានការដាក់ពង្រាយទាហានខ្មែរក្រហមយាមកាមគ្រប់ច្រកល្ហក ដើម្បី -- គ្រប់ច្រកល្ហកដើម្បីកុំឲ្យប្រជាជនដើរសម្រុកចូលទីក្រុងភ្នំពេញវិញ ដែរឬទេ?

**ឆ៖** កាលនោះ មានទ័ពយាមៗមួយពួកៗហ្នឹងបីនាក់ៗអ៊ីចឹងទៅ។ ប៉ុន្តែរឿងប្រជាជនចេញហើយ គ្មានថាចូលត្រឡប់មកវិញបានទេ អត់មានចូលបានទេ។ តែចេញទៅៗហើយ។ ទៅស្រេៗអស់តែម្តង គ្មានពិបាកអីទេ។ ប្រជាជនស្រួលសឹងអី។

**ស៖** ចុះពេលនុ៎ង មានការដាក់តាំងប៉ុស្តិ៍ដើម្បីធ្វើការឆែកឆេរប្រជាជនដែរឬទេ? ហើយបើគេដាក់ តើគេដាក់នៅកន្លែងណាខ្លះ? លោកអាច -- សូមលោកជួយរកនឹកមើល៍!

**ឆ៖** ដាក់នៅក្បាលស្ពានជ្រោយចង្វាហ្នឹងមួយ ហើយដាក់នៅផ្សារថ្មីនេះមួយ។ អាហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើពេលនុ៎ង គេដាក់ហើយ គេធ្វើការឆែកឆេរប្រជាជនដើម្បីអី? លោកមានដឹងពីគោលបំណងនៃការឆែកឆេរនោះទេ?

[១១:៤៨:១២]

**ឆ៖** គ្មានគិតឆែកឆេររឿងអី គិតការពារតែខ្លាចទាហាន លន់ នល់ បង្កប់អីក្នុងផ្ទះ ក្នុងអី ចេញមក គ្រាន់តែយាមអ៊ីចឹង។ ប៉ុន្តែរឿងប្រជាជនអត់មានពិបាកអីទេ។ តែចេញហើយ គ្មានត្រឡប់មកវិញ។

**ស៖** កាលពីព្រឹកមិញ ខ្ញុំក៏ -- លោកបានជម្រាបជូនសហចៅក្រម អ៊ំ! សហព្រះរាជអាជ្ញាថា លោកកាន់ប៉ុស្តិ៍នៅខាងមុំស្ថានទូតបារាំង។ អ៊ីចឹង ខ្ញុំចង់សួរថា តើទិដ្ឋភាពនៅក្នុងស្ថានទូតបារាំងពេលនោះ យ៉ាងម៉េចដែរ លោកមានបានដឹងអំពីហេតុការណ៍អីកើតឡើងនៅទីនោះដែរឬទេ?

**ឆ៖** ចូលមក ដូចអត់ឃើញបារាំងនៅក្នុងហ្នឹង។ អត់មានឃើញ។ ស្ងាត់ជ្រាប។ រួចទ័ពនៅនុ៎ង។

**ស៖** ចុះមានបុគ្គលិកស្ថានទូត ឬក៏ប្រជាជនដែលគាត់រត់ទៅពួន ឬក៏ទៅសំងំនៅក្នុងស្ថានទូតនោះដែរឬទេ?

**ឆ៖** អត់មាន ប្រជាជនមួយក៏គ្មាន។ ស្ងាត់ជ្រាបតែម្តង មួយទីក្រុងភ្នំពេញគ្មានមនុស្សម្នាក់។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកបន្តទៀត ទាក់ទងទៅនឹងពីព្រឹកមិញ លោកប្រាប់ថា លោកពេលដែលលោកចូលមកដល់ ឃើញស្ថានប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ។ ពេលនុ៎ង លោកមានឃើញព្រះសង្ឃអីដើរចេញទៅ -- ត្រូវបានគេជម្លៀសចេញទៅដែរ ឬក៏អត់?

**ឆ៖** ដូចអត់ដែរ អត់ឃើញមានព្រះសង្ឃសោះ។ ក្រែងតែមុខព្រួញឯណាទៀត បើមុខព្រួញត្រង់ទូតបារាំងហ្នឹង គ្មាន អត់ឃើញព្រះសង្ឃដើរតាមហ្នឹងទេ។

[១១:៥០:៥២]

**ស៖** កាលពីព្រឹកមិញដែរ ខ្ញុំក៏បានចាប់អារម្មណ៍ទៅលើសម្តីលោកមួយម៉ាត់ ដែលលោកបានលើកឡើងថា "ដឹងហើយ -- ដឹងស្រាប់ហើយ សម័យអាពត"។ តើលោកចង់មានន័យម៉េចដែរ?

**ឆ៖** អាហ្នឹង ដូចរាងភ្លេចបន្តិចហើយ។

**ស៖** បើសិនជាអាច សូមលោកជួយរកនឹកឡើងវិញ។

**ឆ៖** ដូចរាងភ្លេច។

**ស៖** ទាក់ទងទៅនឹងការវាយបានទីក្រុងភ្នំពេញ ហើយអំឡុងពេលហ្នឹង គឺប្រជាជនបានចាកចេញពីទីក្រុងភ្នំពេញអស់ហើយ។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើលោកពេលហ្នឹង នៅឯណាដែរ?

**ឆ៖** ខ្ញុំនៅទូតបារាំងហ្នឹងៗ រួចទៅបានមកនៅទួលសង្កែ។ ដល់នៅទួលសង្កែ គេឲ្យមកកាប់កក់កាប់អីហ្នឹង ធ្វើប្រាំង គេឲ្យធ្វើប្រាំង។ កក់លិចៗក្បាល គេឲ្យយកចបយកមកអីកាប់ គេថាមិនបាច់គោទេ កាប់ចប អាណាកាប់ទៅមុខកាប់ទៅ អាណាកាប់ត្រឡប់កាប់ទៅអី។ យកទ័ពហ្នឹង ធ្វើដូចគោកាប់អ្អែងខ្មែច កក់ម្ដុំត្រង់នុំង ធ្វើប្រាំង។

[១១:៥២:៤២]

**ស៖** តើលោកពេលហ្នឹង លោកមានបានដឹងអំពីការផែនការក្នុងការរៀបចំទីក្រុងឡើងវិញដែរឬទេ? ហើយគេមានការប្រកាសយ៉ាងដូចម្ដេចដែរ នៅក្នុងអំឡុងពេលនោះ?

**ឆ៖** ដូចអត់មានថា កសាងស្អីៗ អត់មាន។ ឃើញតែ ឃើញដាំដើមដូង គេគាស់អាការ៉ូតាមចិញ្ចើមថ្នល់ហ្នឹង ចាស់ៗហ្នឹង ឃើញ មកឃើញ ដើមធំៗ អាខ្លះ ចង់ផ្លែ ទើបតែឥឡូវហ្នឹងកាប់ចោលអស់ ពីដើមដាំ ផ្លូវណា ដូចផ្លូវណា ដាំៗ តែដើមដូងហ្នឹង មួយប្រឡោះៗ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងព័ត៌មានទាក់ទងរឿងនយោបាយ នៅក្នុងស្ថានភាពនៅពេលដែលបានជ័យជម្នះនៅក្នុងរបបខ្មែរ -- នៅពេល -- នៅក្នុងរបប -- នាអំឡុងពេលនោះ ខ្ញុំចង់សួរលោកថា ក្រោយពីបានជ័យជម្នះ តើថ្នាក់លើ ឬក៏អង្គការ គេមានហៅថ្នាក់ដូចជាទាហានតូចៗ ដូចជាក្រុមរបស់ពួកលោកហ្នឹង ទៅប្រជុំដើម្បីអបអរសាទរ ហើយនិងមានការប្រកាសថា អ្នកណាជាថ្នាក់ដឹកនាំនៅពេលនោះ? ហើយឥឡូវនេះ យើងបានជោគជ័យហើយ យើងត្រូវធ្វើម៉េច? យើងត្រូវមានជំហរយ៉ាងដូចម្ដេច? តើលោកមានបានចូលរួមកម្មវិធីអ៊ីចឹងដែរឬទេ?

**ឆ៖** គេបានប្រជុំ បានអី ឲ្យយើងខំកសាងប្រទេស។ ធ្វើប្រឡាយៗ ដូចប្រជាជនធ្វើប្រឡាយធ្វើទំនប់ ធ្វើស្អីៗ អូ! ភ្លឺហ្នឹង។ ធ្វើដូចប្រជាជន ដកកាំភ្លើងអស់រលីង ដកកាំភ្លើងអស់ ឲ្យធ្វើប្រឡាយធ្វើទប់ភ្លឺ ទប់អ៊ីចឹង ធម្មតាដូចប្រជាជនអ៊ីចឹង។

[១១:៥៤:៥២]

**ស៖** តើពេលនុំង មានការប្រកាសថា នរណាជាថ្នាក់ដឹកនាំហើយនៅ? ហើយគេគ្រប់គ្រងប្រទេសយ៉ាងដូចម្ដេច?

**ឆ៖** ក្រោយមកបានគេប្រាប់ មុនអត់ដឹង ថាវៃឲ្យសម្ដេច ដល់ក្រោយមកគេថាអង្គការៗ

ឯណាអ៊ីចឹងហើយ។ ដល់ក្រោយមកគេឲ្យទៅប្រជុំនៅស្តាត ទៅចាំស្តាប់លេខាបក្ស ស្តាតអូឡាំពិកយើងហ្នឹង។ ទៅ ចូលម៉ោងប្រាំមួយ ចូលប្រហែល ២, ៣ ម៉ោងក្រោយ សុទ្ធតែទ័ពទាំងអស់ ទ័ពទូទាំងប្រទេសចូលនុ៎ង។ ចូលហ្នឹងស្រាប់តែឃើញគេឈរឡើងជ្រោង។ រួច ប៉ុល ពត នៅចំកណ្តាល ធ្វើអ៊ីចេះប្រកាសថា ប៉ុល ពតៗ មើលអត់ឃើញ។ ដល់ចាប់ផ្តើមនិយាយ ជំនាន់គេ ការតស៊ូរបស់គេ ចាប់ពីផ្លូវរទេះភ្លើង រ៉ាវទេះភ្លើងហ្នឹងទៅភ្នំចោលចាបហ្នឹង។ គេនិយាយតែពីរបីម៉ាត់ គេថាអ៊ីចេះ ចាំស្តាប់ខ្សែអាត់ទៅ។ ខ្ញុំនិយាយហ្នឹងដូចខ្សែអាត់។ ខំចាំតែស្តាប់។ ដឹង -- អត់ងងុយមួយយប់។

[១១:៥៦:៣០]

**ស៖** តើលោកអាចចាំបានទេ ពេលដែលលោកចូលរួមហ្នឹងនៅក្នុងឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ៧៥ ដែរ ជិតដាច់ហើយ ភ្លេចហើយ ភ្លេចថ្ងៃភ្លេចខែ។

**ស៖** ចុះក្រោយពីគេប្រកាសថាលោក ប៉ុល ពត អ៊ីចឹងមានការប្រកាសថា បុគ្គលបន្តបន្ទាប់ទៀតត្រូវ -- ខ្ញុំសូមធ្វើការកែសំណួរ សូមទោស។ ពេលនុ៎ងលោកមានឃើញវត្តមានអ្នកផ្សេងទៀត ដូចជាថ្នាក់អ្នកដឹកនាំផ្សេងទៀត ដែលគួរឲ្យកត់សម្គាល់ដែរទេនៅពេលនោះ?

**ឆ៖** អត់ៗស្គាល់សោះ មិនស្គាល់តែម្តង។ មិនស្គាល់ ស្គាល់តែត្រឹមវរៈ ត្រឹមកងពល ស្គាល់តែប៉ុណ្ណឹង។ គេមិនឲ្យដើរ។ ពួកអ្នកធំៗហ្នឹងមិនដែលឃើញ។

**ស៖** សូមអរគុណ ខ្ញុំសូមធ្វើការបន្តសំណួរខ្ញុំតទៅទៀត។ ខ្ញុំសូមវិលទៅក្រោយបន្តិច ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញ។ លោកពីព្រឹកមិញលោកថា គេជម្លៀសចេញក្នុងរយៈពេល៤ ទៅ ៥ ថ្ងៃឲ្យប្រជាជនចេញឲ្យអស់ ហើយតាមបទពិសោធន៍របស់លោក ក៏ដូចជាតាមការសង្កេតរបស់លោកនៅអំឡុងពេលនុ៎ង តើលោកមានបានឮ ឬក៏ការប្រកាសឲ្យប្រជាជនចូលទីក្រុងភ្នំពេញទេ ក្រោយពីការបោសសម្អាតហើយ ស្អាតហើយនោះ?

[១១:៥៨:៤៣]

**ឆ៖** អាហ្នឹងហៅថា ន័យនយោបាយ ធ្វើម៉េចឲ្យប្រជាជនចេញផុតទៅ។ ចេញផុតចប់ហើយមានបានៗចូលទីក្រុងភ្នំពេញណា អាហ្នឹងហៅថាបោកប្រាស់គ្នា។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរបីសំណួរទៀត។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងការប្រកាសឲ្យចាយលុយ អ៎! ឈប់ចាយលុយ។ តើលោកមានដឹងពីបញ្ហាហ្នឹងទេ?

**ឆ៖** បាទ ដឹងតើ! ដឹងគេប្រកាសអត់ឲ្យចាយលុយ។

**សៈ** តើគេប្រកាសនៅក្នុងឆ្នាំណា? ហើយនរណាជាអ្នកចេញប្រកាសថា ឲ្យឈប់ចាយលុយនោះ?

[១១:៥៩:៥០]

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ឆ្លើយសាក្សី! ចាំរង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា!

**លោក ស៊ុំ ជា៖**

**ឆៈ** អាហ្នឹងខ្ញុំឮ ឮតែតៗគ្នា ពីមួយទៅមួយថា គេឥឡូវគេលែងឲ្យចាយលុយហើយ មាសក៏គេមិនឲ្យពាក់ដែរ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**សៈ** ខ្ញុំសូមសួរបន្តទៀត។ ទាក់ទងទៅហ្នឹងស្ថានភាពនៅបាសិត ខ្ញុំចង់សួរលោកថា ក្រោយពេលជ័យជម្នះរបស់បក្សកម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យហើយ តើលោកមានត្រូវបានគេបញ្ជូនទៅបាសិត ដែរឬទេ?

**ឆៈ** គឺបញ្ជូនឲ្យទៅធ្វើប្រឡាយ ធ្វើភ្លឺស្រែនៅបាសិតហ្នឹង ខាងកើតបាសិត ត្រង់ភូមិធំហ្នឹង។

**សៈ** តើលោកមានដឹងមូលហេតុអ្វីបានជាគេបញ្ជូនលោកទៅ? ហើយមនុស្សប្រភេទណាដែលត្រូវគេបញ្ជូនទៅភ្នំបាសិតនុ៎ង ទៅបាសិតនុ៎ង?

**ឆៈ** អានេះមិនដឹងមនុស្សប្រភេទណាទេ វាឲ្យទ័ពនោះជូនទៅធ្វើប្រឡាយ ធ្វើស្អីហ្នឹង។ កងធំកងអី វាឲ្យទៅណាទៅនុ៎ង កាលជំនាន់នុ៎ង។

**សៈ** ចុះលោកមានបានសង្កេតឃើញស្ថានភាពប្រជាជននៅទីនោះយ៉ាងម៉េចដែរ? ដូចជាការហូបចុក ការស្នាក់នៅ?

**ឆៈ** មួយសាហ្នឹងវេទនាណាស់ប្រជាជន។ មួយផ្ទះៗ ឲ្យតែកម្លាំងពេញហ្នឹងគេឲ្យធ្វើការអស់ហើយ។ រែកដី លើកភ្លឺស្រែ អស់រលីងគ្មាននៅផ្ទះទេ រកគ្រប់គ្នា។

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមអរគុណចំពោះការឆ្លើយដ៏ក្បោះក្បាយរបស់លោក ហើយនិងសុំផ្ទេរវេទិកានេះទៅឲ្យសហមេធាវីអន្តរជាតិ ដើម្បីធ្វើការតាំងសំណួរបន្ត។ សូមអរគុណ។

[១២:០២:៣១]

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមានពេល ១០នាទីទៀតតែប៉ុណ្ណោះ។

**លោកស្រី ទូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោក ស៊ុំ ជា ខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ។

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** ជាដំបូង ខ្ញុំចង់សួរអំពីការប្រព្រឹត្តចំពោះជនស៊ីវិលនៅក្នុងពេលជម្លៀសប្រជាជន។ នៅពេលដែលលោកប្រាប់ឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តើលោកមានទទួលបានការបញ្ជា ការណែនាំថាត្រូវធ្វើយ៉ាងណាចំពោះប្រជាជនដែលចាស់ ឬក៏ដែលមានជំងឺដែរឬទេ នៅពេលដែលជម្លៀសគាត់ចេញពីទីក្រុងនោះ?

[១២:០៣:១៧]

**លោក ស៊ុំ ជា៖**

**ឆ៖** អាហ្នឹងដូចខ្ញុំនិយាយពីដំបូងអ៊ីចឹង គ្មានគិតថាយ៉ាងម៉េច ថាធ្វើម៉េចឲ្យតែបានចេញពីទីក្រុងភ្នំពេញ។

**ស៖** សូមអរគុណ។ លោកបានប្រាប់ថាលោកបានចូលមន្ទីរពេទ្យកាល់ម៉ែតនៅពេលជម្លៀសនោះ។ តើមានអ្វីកើតឡើងចំពោះជនស៊ីវិលនៅក្នុងមន្ទីរពេទ្យ ដែលត្រូវទាមទារចាំបាច់ឲ្យមានការផ្ដល់សេវាសុខាភិបាលហ្នឹង? តើពួកគាត់ត្រូវគេជម្លៀសចេញដែរឬទេ?

**ឆ៖** មួយជំនាន់ហ្នឹងដូចគ្មានសេវាឯណាទៅ គិតគូរអារឿងអ្នកជំងឺ អ្នកអីគ្មានទេ គ្មានតែម្ដង។ សុខចិត្តធ្វើម៉េចឲ្យតែចេញទៅ ដឹករទេះដឹកអីឲ្យតែចេញផុតពីទីក្រុងភ្នំពេញ។ អត់មានសេវាអី អាណិតអាសូរអី។ ចាំដេកពេទ្យសិន ជាសឹមទៅ អត់ទេមួយសាហ្នឹង វេទនាណាស់ប្រជាជន ត្រូវតែចេញ។

**ស៖** តើមានការដឹកជញ្ជូនផ្នែកឱសថ ឬក៏ផ្នែកវេជ្ជសាស្ត្រដែរឬទេ នៅពេលដែលជម្លៀសប្រជាជនចេញពីពេទ្យនោះ?

**ឆ៖** កាលនោះ យើងពេទ្យទាហាន ពេទ្យអីហ្នឹងគេដើរប្រមូលៗថ្នាំពេទ្យ ទៅតាមមន្ទីរពេទ្យដូចគ្មានពេទ្យឯណា ថ្នាំពេទ្យអី យកពីក្រៅ យកពីអីមក គ្មាន គេដើរប្រមូលៗតាមមន្ទីរពេទ្យហ្នឹង?

[១២:០៥:៥២]

**ស៖** តើមានពេទ្យយោធា ដើម្បីព្យាបាលដល់ទាហានខ្មែរក្រហមដែរឬទេនៅពេលនោះ?

**ឆ៖** មានដែរ។ ទាហានហ្នឹងគេព្យាបាល។ ពេទ្យហ្នឹង គេព្យាបាលទាហានហ្នឹង។

**ស៖** តើមន្ទីរពេទ្យ ដែលគេព្យាបាលទាហានហ្នឹង តើមានមន្ទីរពេទ្យឈ្មោះអ្វីដែរនៅពេលនោះ?

**ឆ៖** គេហៅ "ពេទ្យធំ"។

**ស៖** តើពេទ្យនោះ គេប្រើប្រាស់របៀបម៉េចដែរឲ្យច្បាស់លាស់? តើគេព្យាបាលដោយរបៀបណាដែរ? សូមលោកបញ្ជាក់ផង។

**ឆ៖** ជំនាន់ហ្នឹង ខ្ញុំមិនដែលទៅមន្ទីរពេទ្យហ្នឹងផង ប៉ុន្តែគ្រាន់តែឃើញគេថា គេឲ្យថ្នាំគ្រាប់ ហើយចាក់អីចឹងទៅ ប៉ុន្តែរឿងសេរ៉ូមព្យួរគ្មានទេ គ្មានសេរ៉ូម គ្មានអីទេជំនាន់នោះ។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់សួរលោកបន្តិចអំពីវិធីសាស្ត្រ ក្នុងការជម្លៀសប្រជាជន។ តើលោកធ្លាប់ឃើញទាហានខ្មែរក្រហមចូលតាមផ្ទះប្រជាជន ដើម្បីរកមើលប្រជាជនស៊ីវិលដែលនៅក្នុងផ្ទះនោះដែរឬទេ?

**ឆ៖** ដូចអត់មានឃើញទេ ទាហាន និងប្រជាជន ដូចមិនឃើញ គ្រាន់ថាជម្លៀស ៤,៥ថ្ងៃចេញទៅស្ងាត់អស់តែម្តង ដូចគ្នាឃើញ បកក្រោយ ឬពួនសំងំអីអត់មានទេ ស្ងាត់ជ្រាបតែម្តង។

**ស៖** សូមអរគុណលោក។ លោកបានបញ្ជាក់ពីដើមមកហើយថា ពេលខ្លះទាហានបង្ខំដើម្បីឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ។ តើលោកធ្លាប់ឃើញគេធ្វើបាបនារីទេ នៅពេលដែលមានការជម្លៀសនោះ?

[១២:០៩:០០]

**ឆ៖** អត់ទេ អត់ដែលមានធ្វើបាបនារី ធ្វើបាបអីអត់ ប្រជាជន បើត្រង់កងខ្ញុំវិញ គ្រាន់តែប្រាប់ឲ្យចេញៗឲ្យស្រួតទៅប្រយ័ត្នកប៉ាល់ហោះមកទម្លាក់ ឬមួយគេបាញ់គ្នាងាប់ លឿនឡើង ចេញឲ្យលឿនឲ្យធ្វើបាបនារី ធ្វើបាបអី គ្មានទេ។

**ស៖** តើលោកធ្លាប់ឮ ឬក៏ដឹងអំពីការបៀតបៀន ឬក៏ការរំលោភផ្លូវភេទទៅលើនារីដែរឬទេ នៅពេលក្នុងជម្លៀសប្រជាជននោះ?

**ឆ៖** អត់មានទេ។ អត់បានដឹង បានអី។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរពីរបីបន្ថែមទៀត ពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ ដែលលោកបានជួបប្រទះនៅពេលជម្លៀស។ តើទាហាន លន់ នល់ ទាំងអស់ហ្នឹងមានកាន់អាវុធដែរ

 

ឬទេ? ហើយមានប្រដាប់អាវុធដែរឬទេ នៅពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញនោះ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកមានពើបប្រទះការប្រយុទ្ធគ្នាដោយអាវុធអីដែរឬទេ នៅពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញនោះ?

**ឆ៖** អត់មានទេ អត់មានវ៉ៃគ្នា។

[១២:១០:៥០]

**ស៖** តើលោកមានធ្លាប់ឃើញទាហាន លន់ នល់ ចុះចាញ់ ឬក៏លើកទង់ជ័យ-ស អីដែរទេនៅពេលនោះ?

**ឆ៖** គ្រាន់តែចូលមកភ្នំពេញ គេលើកទង់ជ័យ-ស។ មិនដឹងជាទាហាន មិនដឹងប្រជាជន ក៏អត់ដឹងសុទ្ធតែទង់ជ័យ-ស តែម្តង អ្នកណាកង់ កង់ទៅ អ្នកណាម៉ូតូ ឡានអីមួយៗសុទ្ធតែទង់ជ័យ-ស មិនដឹងជាអ្នកណាទាហាន អ្នកណាជាប្រជាជន។ តែគេដាក់ទង់ជ័យ-ស គេចុះចាញ់ហើយអាហ្នឹង។

**ស៖** បន្ទាប់ពីលោកធ្វើការប្រកាស នៅពេលដែលលោកចូលដល់ទីក្រុងភ្នំពេញហើយ គឺថាលោកប្រកាសឲ្យទាហាន លន់ នល់ ចូលមកថាតើលោកមានឃើញ ទាហាន លន់ នល់ ណាខ្លះចូលមកជាមួយក្រុមលោកដែរឬទេ?

**ឆ៖** អាហ្នឹងមានតែកងគេ កងគេទេ គេទៅដើរប្រកាសមីក្រូ ចាប់ពីស្ពានមករហូតដល់ព្រែកក្តាម ហើយនិង គឿន ហ្នឹងមួយដែរ ដែលអ្នកដឹងមកប្រាប់ខ្ញុំ។ អ្នកខ្លះគេធ្វើយុទ្ធជនហ្នឹង ក៏គេថា ធ្វើស័ក្តិ១ ធ្វើស័ក្តិ២ អាខ្លះធ្វើស័ក្តិ៥ រហូតដល់ស័ក្តិប៉ុនណាប៉ុនណី គេយកមកវ៉ៃចោលនៅព្រែកព្នៅហ្នឹង ដូចខ្ញុំរាយការណ៍ពីព្រឹក។ ហ្នឹងថា ចាញ់នយោបាយគេ ប៉ុន្តែនៅខាងក្រោយ ក៏មិនរស់ដែរជំនាន់ហ្នឹង នៅខាងក្រោយក៏តាម ខ្ញុំមកសារភាពមុនដំបូង។ នៅខាងក្រោយក៏គេស្រាវជ្រាវរកទាល់តែឃើញទាហានគ្មាននៅ គ្មានរស់មួយទេ។ ហ្នឹងឮចាស់ៗគាត់និយាយ។

[១២:១៣:២៣]

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកសាក្សី។ ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាស

សម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ សាមសិបនាទីរសៀល នេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ លោក នួន ជា សុំអនុញ្ញាតបន្តតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ខាងក្រោម ដោយសារតែឈឺខ្នង ឈឺចង្កេះ និងមិនអាចផ្តង់អារម្មណ៍ ហើយយើងខ្ញុំនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិនេះ ជូនទៅអង្គជំនុំជម្រះ។ សូមលោកប្រធានអនុញ្ញាត។

[១២:១៤:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញ១រសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាព មិនអាចអង្គុយយូរ តាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះបាន។ ដោយលោកមេធាវីការពារក្តីសន្យាថា នឹងប្រគល់មកឲ្យអង្គជំនុំជម្រះ នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក នួន ជា។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួនជា ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

[១២:១៥:២៣]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៦ នាទី ដល់ម៉ោង១៣:៣៥ នាទី)*

[១៣:៣៥:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោក ឌុច ផារី!

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-89 ដែលអង្គជំនុំជម្រះបានកោះហៅ ដើម្បីមកបម្រុងទុកសម្រាប់ថ្ងៃនេះ ឥឡូវនេះគាត់មានវត្តមានហើយនៅបន្ទប់រង់ចាំ។ ហើយលោក អៀង សារី តាមរយៈឯកសារលេខ E237 ក៏បានលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ ជាបន្ត តើលោក លោកស្រីចៅក្រមមានសំណួរអ្វី ត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួន ខ្ញុំនឹងព្យាយាមទៅឲ្យបានលឿន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី កាលពីព្រឹកមិញនេះលោកនិយាយថា មុនពេលវាយចូលភ្នំពេញ លោកនិងអង្គភាពរបស់លោកនោះគឺថា ប្រចាំការនៅបាសិត។ តើលោកដឹងថាមានការប្រើកាំភ្លើងធំ ដើម្បីបាញ់ផ្លោងចូលទីក្រុងភ្នំពេញ ពីបាសិតដែរឬទេ ជាពិសេសគឺបាញ់ចេញពីភ្នំបាសិត តម្រង់មកទីក្រុងភ្នំពេញ។ តើមានការបាញ់បែបនេះដែរឬទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** មានបាញ់ដែរ។ បាញ់ដេកា ប៉ុន្តែត្រឹមចំផ្ទះមួយរយខ្នង និងឃ្លាញ អត់មានចូលភ្នំពេញទេ។

[១៣:៣៧:៥១]

**ស៖** យើងមិនបានស្តាប់ឮចម្លើយទាំងអស់របស់លោកទេ។ ចំពោះខ្លួនខ្ញុំផ្ទាល់នោះ ខ្ញុំចង់ដឹងថា តើលោកដឹងដែរឬទេថា ការបាញ់ផ្លោងមកទីក្រុងភ្នំពេញហ្នឹង តើគេបាញ់យ៉ាងម៉េច? តើមានស៊ីបផ្លាំង ស៊ីបយុទ្ធសាស្ត្រសម្រាប់បាញ់តម្រង់មកទេ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** អត់ទេ។ អត់មានដឹងសោះ បាញ់ចូលផ្លោងចូលទីក្រុងភ្នំពេញ អត់មានដឹង។ ព្រោះខ្ញុំនៅខាងថ្មើរជើងនេះ។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់ទៅកាន់ចម្លើយរបស់លោក ដែលបានឆ្លើយកាលពីព្រឹកមិញនេះ ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីស្វែងរកអតីតយោធានៃរបប លន់ នល់។ លោកឆ្លើយថា យើងបានប្រើប្រាស់មីក្រូ ដើម្បីផ្សាយសារទៅកាន់អតីតយោធា លន់ នល់។ លោកអាចប្រាប់បានទេថាតើមីក្រូទាំងអស់ហ្នឹងមកពីខាងណា ជាកម្មសិទ្ធិរបស់កងពល ឬក៏មកពីខាងណា សម្ភារៈសម្រាប់ការផ្សាយទៅដល់អតីតទាហាន លន់ នល់ ទាំងអស់នោះ?

**ឆ៖** អត់បានដឹងយកមកពីណាផង ឃើញតែពួក គឿន ហ្នឹងគាត់ថាដាក់មីក្រូដើម្បីឃោសនារកទាហាន។ អត់ដឹងយកពីណាៗមក អត់ដឹង។

**ស៖** ចុះនៅក្នុងកងពលរបស់លោកពីមុនមកនោះ លោកធ្លាប់ឃើញមីក្រូទាំងអស់ហ្នឹងទេ?

**ឆ៖** អត់ទេ អត់ដែលឃើញទេ មិនដែលមានផង មិនដែលមានមីក្រូទេ។

**ស៖** តើមីក្រូទាំងអស់នេះក៏ប្រើសម្រាប់ផ្សាយសារជូនទៅដល់ប្រជាជន ដែលមិនមែនជាយោធាដែរ គឺប្រជាជនស៊ីវិល តើគេផ្សព្វផ្សាយសារតាមមីក្រូហ្នឹង ដើម្បីឲ្យប្រជាជនចេញទៅ ចេញពីទីក្រុង តើអ៊ីចឹងមែនទេ?

**ផ៖** បាទ អ៊ីចឹងៗមែន។

**ស៖** លោកក៏បានឆ្លើយផងដែរថា អតីតយោធាដែលត្រូវបានរកឃើញនោះ ត្រូវបានយកមកប្រមូលផ្តុំមួយកន្លែង ហើយបន្ទាប់មកនាំយកចេញទៅ។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ លោកថា គេនាំឡើងឡានកាំម៉ុង តើត្រឹមត្រូវដែរឬទេ?

**ផ៖** សួរម្តងទៀត ព្រោះចម្លើយអំមិញហ្នឹង សួរថា ទាហានហ្នឹង ទាហាន ប៉ុល ពត ឬមួយទាហាន លន់ នល់?

[១៣:៤១:២៨]

**ស៖** សូមអភ័យទោស អម្បាញ់មិញនេះខ្ញុំសួរមិនច្បាស់ ខ្ញុំនិយាយអំពី "ទាហានរបស់អតីតកងទ័ព លន់ នល់ ដែលត្រូវបានទាហានខ្មែរក្រហមរកឃើញ ហើយបន្ទាប់មកត្រូវបាននាំយកទៅសម្លាប់ចោល"។ នេះជាចម្លើយរបស់លោក។ តើអតីតយោធាលោក លន់ នល់ ទាំងអស់នេះត្រូវគេដឹកតាមឡានមែនទេ?

**ផ៖** ដឹកតាមឡាន។

**ស៖** ចុះលោកដឹងទេថាឡាននុ៎ងជាកម្មសិទ្ធិរបស់ខាងណាដែរ ជារបស់ខាងកងពល ឬក៏មកពីខាងអង្គភាពណាផ្សេង?

**ផ៖** របស់ទាហានហ្នឹងតែម្តង របស់ទាហានៗ លន់ នល់ ហ្នឹង។

**ស៖** ដូច្នេះ គឺជាសម្ភារៈរបស់យោធា លន់ នល់ ត្រូវបានប្រើប្រាស់ដើម្បីដឹកយោធា លន់ នល់ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ ត្រូវហើយ។

[១៣:៤២:៥៧]

**ស៖** នៅពេលដែលលោកនៅបាសិត ឬក៏លោកនៅភ្នំពេញ តើលោកមានស្តាប់ឮការផ្សាយតាមវិទ្យុ ជាពិសេសវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា តើលោកមានធ្លាប់ស្តាប់ឮទេ?

**ផ៖** អត់ៗមាន អត់មានស្តាប់ឮអីទេ គ្មានទាំងវ៉ាដ្យូជំនាន់នុ៎ង ហើយគ្មានទាំងថ្មដាក់ផង។

**ស៖** នៅសម័យនោះ តើលោកធ្លាប់ឮគេនិយាយអំពីឈ្មោះជនក្បត់ទាំងប្រាំពីរទេ?

**ឆ៖** អត់ផង អត់មានដឹងផង។

**ស៖** លោកបានឆ្លើយថា លោកចូលភ្នំពេញ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា លោកចូលភ្នំពេញភ្លាមតែម្តង ក្រោយពីមានការរំដោះ ឬក៏លោកចាំសិន បានចូលមកតាមក្រោយ?

**ឆ៖** អាហ្នឹងចូលគ្រប់មុខព្រួញទាំងអស់តែម្តង អត់មានចូលទៅ ម្តងមួយកង ម្តងមួយកងតូច មួយក្រុម អត់ទេ។ ទាល់តែតេអូ មកចូលទូទាំងប្រទេសតែម្តងបានចូលបាន។

[១៣:៤៥:០២]

**ស៖** កាលពីព្រឹកមិញនេះ លោកបានរៀបរាប់អំពីភូមិភាគដែលបានចាត់តាំងលោកឲ្យលោកចូលក្នុងកងរបស់លោក។ ខ្ញុំដូចជាមិនច្បាស់សោះ មិនដឹងថាតើត្រូវយល់យ៉ាងម៉េច? ភូមិភាគ ផ្នែក ឬក៏មុខព្រួញរបស់លោកនោះ គឺថាដូចជាទូលំទូលាយណាស់ ថាមានផ្សារថ្មី ជ្រោយចង្វា ទួលគោក។ តើលោកដឹងយ៉ាងម៉េចបានថា មុខព្រួញនោះស្ថិតនៅក្រោមការគ្រប់គ្រងនៃកងពលរបស់លោក? តើលោកដើរយាមនៅក្នុងមុខព្រួញទាំងអស់នោះ ឬក៏យ៉ាងម៉េច?

**ឆ៖** នេះព្រោះ បងហាក់ វរសេនាតូចហ្នឹងគាត់ចាត់តាំងថា ពីផ្សារថ្មីមករហូតដល់គីឡូលេខ៩ មកចាំយាមមួយគន្លាក់ៗអីចឹង កាលដាច់ភ្នំពេញហ្នឹង។

**ស៖** ដើម្បីឲ្យយើងទាំងអស់គ្នាបានយល់ច្បាស់នោះ គីឡូម៉ែត្រលេខ៩នោះ ស្ថិតនៅលើផ្លូវណាដែរឲ្យប្រាកដទៅ? តើស្ថិតនៅផ្លូវដែលមានមន្ទីរពេទ្យកាល់ម៉ែតហ្នឹង មែនដែរឬទេ?

**ឆ៖** ទៅខាងជើងស្ពានជ្រោយចង្វា គីឡូលេខ៩។

[១៣:៤៧:០៥]

**ស៖** ដូច្នេះ នេះគឺជាចំណុចមួយដែលនៅជិតព្រែកព្នៅ តើអីចឹងមែនទេ? គឺស្ថិតនៅលើផ្លូវជាតិលេខ៥ ដែលតម្រង់ទៅកំពង់ឆ្នាំង។ តើតាមផ្លូវហ្នឹងមែនទេ?

**ឆ៖** ត្រូវហើយ តាមផ្លូវហ្នឹង។

**ស៖** ចុះចំពោះលោកផ្ទាល់នៅពេលនុ៎ង តើលោកឈរជើងនៅកន្លែងណា ហើយលោកមានតួនាទីអ្វីដែរនៅកន្លែងនោះ?

**ឆ៖** អត់មាននាទីអីផង គ្រាន់តែគេចាត់តាំងឲ្យយាមនៅមុខពេទ្យកាល់ម៉ែតហ្នឹង។

**ស៖** ដូច្នេះ គឺថាលោកយាមកន្លែងផ្សេងៗគ្នាចាប់ពីផ្សារថ្មី ទៅដល់ព្រែកព្នៅ ឬក៏លោកត្រូវឈរ

យាមនៅកន្លែងណាមួយជាក់លាក់តែម្ដង ដោយមិនធ្វើដំណើរទៅមកទេ?

**ឆ៖** ខ្ញុំនៅតែមុខពេទ្យកាល់ម៉ែតហ្នឹង ជាមួយខ្ញុំ អានោះកងគេដោយខ្លួន។ បាទ តាំងពីផ្សារថ្មីមកកងគេ ហើយកងគេហ្នឹង ដឹងតែនៅមុខពេទ្យកាល់ម៉ែតតែមួយ។

**ស៖** នៅមន្ទីរពេទ្យកាល់ម៉ែត លោកនិយាយថា លោកបានឃើញអ្នកជំងឺ ហើយគេបង្ខំឱ្យអ្នកជំងឺចេញពីពេទ្យ។ ចុះលោកមានឃើញគ្រូពេទ្យដែរឬទេនៅក្នុងពេទ្យនោះ? ហើយគេមានសុំ ឬក៏ប្រាប់ឱ្យអ្នកជំងឺចេញពីពេទ្យ ទុកអ្នកជំងឺចោលទេ?

**ឆ៖** អង្កាល់ហ្នឹង ពេទ្យក៏រត់ចែកជើងគ្នាដែរ គ្មានឃើញពេទ្យ ឃើញអីទេ ឃើញអ្នកជំងឺ។ មិនដឹងបង មិនដឹងប្អូនគេ មិនដឹងម៉ែឪគេតែប៉ុណ្ណឹង ដែលគេជម្លៀសអ្នកជំងឺចេញទៅ។ អត់មានឃើញពេទ្យទេ ស្ងាត់តែម្ដង។

**ស៖** តើលោកដឹងយ៉ាងម៉េចបាន ចំពោះរឿងនោះ។ ចូលទៅក្នុងពេទ្យផ្ទាល់តែម្ដង ដើម្បីពិនិត្យមើលថា គ្មានមនុស្ស ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អាហ្នឹងខ្ញុំចូលទៅបានដឹង អត់មានមនុស្ស។ មួយក៏គ្មាន ពេទ្យក៏គ្មាន។ អ្នកជំងឺយកតែ ២ថ្ងៃទេអស់ក្នុងមន្ទីរពេទ្យ យកខ្មោច កូនចៅគេមកយកទៅបាត់អស់រលីង។

**ស៖** តើលោកមានបានទៅមើលអគារសាធារណៈផ្សេងៗទៀតទេ? ឧទាហរណ៍ ដូចជាលោកដែលចូលទៅក្នុងបរិវេណក្រសួង មន្ទីរ ឬក៏ធនាគារជាតិកម្ពុជា លោកធ្លាប់ចូលទៅកន្លែងអស់ហ្នឹងទេ?

**ឆ៖** អត់ទេ។ អត់ដែលចូលទេ។ ព្រោះគេមិនឱ្យដើរតែម្ដង ទាក់ទងពីៗក្រុមមួយទៅក្រុមមួយគេមិនឱ្យដើរទាក់ទងផង។ ទៅដើរ ទៅប៉ិានដើរចូលអីណា អត់ អត់ប៉ិានទេ ជំនាន់នុងដឹងស្រាប់ហើយ។

**ស៖** នៅពេលដែលលោកយាមតាមផ្លូវ លោកធ្លាប់ឃើញមានបរទេសដើរកាត់មុខលោកទេ? ហើយមានការបញ្ជាជាក់លាក់ណាមួយពាក់ព័ន្ធនឹងជនបរទេសដែរឬទេ?

[១៣:៥១:៥២]

**ឆ៖** ដែលឃើញហ្វីលីពីន នៅត្រង់កន្លែងខាងលិច ត្រង់ផ្លូវប្រជាធិតេយ្យ ត្រង់អង់ស្លូលអ៊ីចេះឥឡូវអាពេតវ៉ារ៉ៃចូលបាត់ហើយអាហ្នឹង។ មុំក្បែរចេតិយ អង់ស្លូលធំនោះ ឃើញហ្វីលីពីននៅហ្នឹង។ ឃើញតែ២, ៣ថ្ងៃស្រាប់តែបាត់ទៅ។ បាត់ហ្វីលីពីននុំងទៅ។

**ស៖** តើលោកដឹងទេថា មានរឿងអ្វីកើតឡើងដែរចំពោះជនជាតិហ្វីលីពីនហ្នឹង?

**ឆ៖** អត់ដឹង។ អត់ដឹងរឿងអីផង តែសួរគេថា ទៅកន្លែងហ្នឹងឃើញហ្វីលីពីន នៅហ្នឹង រួចឥឡូវ

ទៅណាបាត់ទៅ? គេថា អ្ហឺ! មិនដឹងទៅខាងណាទេ។ គេយកទៅបាត់ទៀតហើយមើលទៅ។

**ស៖** លោកសាក្សីនៅពេលដែលលោកយាមនៅមុខពេទ្យកាល់ម៉ែត គឺវានៅជិតស្ថានទូតបារាំង សំណួរ តើលោកមិនដែលឃើញពួកបស្ចិមប្រទេសណាម្នាក់ទេឬ?

**ឆ៖** ជំនាន់នុំងគ្មានទេ។ គ្មានបរទេសណា គ្មានកាសែតថាមកថត មកអីទេ។ អត់មានសោះតែម្តង មួយក៏គ្មានដែរ។

[១៣:៥៣:៥៧]

**ស៖** ចុះនៅក្នុងបរិវេណអគារស្ថានទូតបារាំង តើមានមនុស្សទេ? លោកច្បាស់ទេថា គ្មានមនុស្ស?

**ឆ៖** អត់មានផង ម្នាក់ក៏អត់មានដែរ បារាំងក៏មិនឃើញ អីក៏មិនឃើញបានៗ ហាក់ យកទ័ពទៅដាក់ត្រង់នុំង ដាក់ក្នុងនុំង។

**ស៖** ខ្ញុំមិនដឹងថា មានកំហុសខាងផ្នែកបកប្រែ ឬក៏យ៉ាងណាទេ? ខ្ញុំឮការបកប្រែថា ស្ថានទូតអាមេរិកទៅវិញ។ ខ្ញុំមិននិយាយអំពីស្ថានទូតអាមេរិកទេ ខ្ញុំនិយាយអំពីស្ថានទូតបារាំង។ ហើយសម័យនោះក៏ ឬក៏សម័យនេះ គឺដូចគ្នា ទីតាំងនៅជិតមន្ទីរពេទ្យកាល់ម៉ែត។ តើខ្ញុំនិយាយនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រូវហើយ និយាយពីខាងទូតអាបារាំង ទូតបារាំងអំមិញនេះ។ អត់មានប្រជាជននៅៗក្នុងនុំងទេ។ ទូតក៏មិនឃើញ ស្អីក៏មិនឃើញ អស់រលីងតែម្តង។

**ស៖** តើនៅពេលណាដែលលោកចាប់ផ្តើមយាមនៅមុខស្ថានទូតបារាំង? តើភ្លាមៗបន្ទាប់ពីចប់សង្គ្រាម ឬក៏រយៈពេលក្រោយមកទេ?

**ឆ៖** តាំងពីចូលទៅ គឺយាមរហូត ព្រោះតែទាហាន ប៉ុល ពត គេប្រុងប្រយ័ត្នជាប់ វាមិនមែនឲ្យទៅសំងំដេក ដើម្បីយកសុខទេ ត្រូវតែយាមតែម្តង។ យាមតាំងពីដាច់រហូត នៅកន្លែងនុំង។

[១៣:៥៦:១៨]

**ស៖** ដូច្នេះ គឺថាលោកនៅយាមជាប្រចាំតែម្តង នៅមុខស្ថានទូតបារាំង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមវេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា និងសហការីរបស់ខ្ញុំ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរលោក ស៊ុំ ជា! ជាដំបូង ខ្ញុំសូមមានសំណួរបួនប្រាំ។ ជាដំបូង ខ្ញុំសូមសួរលោក ទី១ គឺពេលដែលលោកចូលធ្វើកងទ័ពនៅឆ្នាំ១៩៧២ បើតាមឯកសារ ហើយនិងលោកឆ្លើយពីព្រឹកមិញ។ ពេលនោះ លោកប្រហែលជាអាយុ១៨ឆ្នាំ អ៊ីចឹងមែនទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** បាទៗ។

**ស៖** អរគុណ។ ពេលដែលលោកចូលធ្វើកងយោធានោះ តាមការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ ពីព្រឹកមិញ លោកបានជម្រាបតុលាការអ៊ីចឹង មែនឬ? មែនទេ?

[១៣:៥៨:៣១]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បើអ៊ីចឹង លោកជា -- ពេលដែលចូលហ្នឹង លោកដាក់ចិត្តថាលោកចូលធ្វើកងទ័ពរបស់សម្តេច នរោត្តម សីហនុ។ លោកអត់ទាន់ស្គាល់ខ្មែរក្រហមនៅឡើយទេ។ រឿងហ្នឹងពិតជាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទៗ ត្រឹមត្រូវ។

**ស៖** អរគុណ។ ពេលដែលលោកចូលធ្វើជាយោធារបស់សម្តេច នរោត្តម សីហនុ ឆ្នាំ១៩៧២ ដោយស្ម័គ្រចិត្ត ដោយគ្មានគេបង្ខំ ដោយគ្មានគេអូសទាញអីទេ លោកស្ម័គ្រចិត្ត។ ពេលហ្នឹង ពីព្រឹកមិញ លោកបានឆ្លើយបានជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីថា លោកមិនដែលបានមានវិទ្យុ ស្តាប់វិទ្យុអីទេ។

លោកបានដំណឹងថា ឲ្យចូលព្រៃម៉ាគីហ្នឹង តាមប្រភពណាមក?

**ឆ៖** បើអង្កាល់ដែលដាច់ភ្នំពេញហ្នឹង វាគ្មានវ៉ាដ្យូទេ បើនៅក្នុងភូមិ៧២ហ្នឹងមាន ១វ៉ាដ្យូបាទ។ បានសម្ដេចអំពាវនាវហ្នឹង ដើម្បីឲ្យចូលព្រៃម៉ាគីហ្នឹង។

**ស៖** អរគុណ។ អ៊ីចឹងមានន័យថា ដោយលោកបាន -- ដោយលោកបានស្ដាប់វិទ្យុនូវការអំពាវនាវរបស់សម្ដេច សីហនុ ឲ្យចូលព្រៃម៉ាគីដើម្បីតស៊ូ។ ចាប់ពីពេលដែលលោកបានចូលធ្វើជាយោធារបស់សម្ដេច សីហនុ រហូតដល់ពេលណា? ឬរហូតដល់ពេលឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមក ឈប់ ឬក៏មានរយៈពេលណាដែលលោកចេញពីកងទ័ព?

**ឆ៖** ឆ្នាំ៨០ បានខ្ញុំត្រឡប់មកផ្ទះវិញ។

[១៤:០១:១៨]

**ស៖** ពេលដែលលោកចូលធ្វើជាកងទ័ព ពេលហ្នឹងលោកចូលធ្វើជាកូនយោធាធម្មតាទេ អត់មានឋានន្តរស័ក្តិ ឬបុណ្យស័ក្តិអ្វីទេ ឬក៏មុខងារអ្វីធំដុំដែរទេ ឬក៏គ្រាន់ជាកងពលធម្មតា ជាយោធាធម្មតាអ៊ីចឹង?

**ឆ៖** បាទ ជាយោធាធម្មតា។

**ស៖** រហូតដល់ពេលលោក --

**ប្រធានអង្គជំនុំ៖**

មីក្រូ ក្បាលមីក្រូ!

**លោក សុន អរុណ៖**

សូមទោស។

**សួរដោយលោក សុន អរុណ៖**

**ស៖** តាំងពីលោកចាប់ចូលធ្វើជាយោធា រហូតដល់លោកប្រតិបត្តិការក្នុងឋានៈធ្វើជាយោធា មានន័យថា ធ្វើសឹកសង្គ្រាមរាល់ពេល រហូតដល់វៃបានចូលដល់ភ្នំពេញ លោកមានឡើងឋានៈជាអ្វីទេ?

**ឆ៖** ខ្ញុំអត់មានឡើងឋានៈជាស្អីទេ ព្រោះខ្ញុំ វាគេយកតែអ្នកប៉ិនៗ។ បើអ្នកខ្លាច គេមិនសូវឲ្យឡើងប៉ុន្មានទេ។

**ស៖** រហូតមកដល់ឆ្នាំ១៩៧៥ និងបន្តរហូតមកដល់១៩៧៩ លោកថា លោកបានចេញពីកងទ័ពឆ្នាំ១៩៨០។ រយៈពេលនុ៎ង លោកមានឋានៈជាអ្វីដែរទេ?

**ឆ៖** អត់មាន។

**ស៖** អរគុណ។ បើលោកមិនមានមុខងារអ្វីធំដុំទេ លោកជា ពាក្យខ្មែរធម្មតាគេហៅថា កូនទាហាន។ ហើយនៅក្នុងលោកឋានៈជាកូនទាហាននៅក្នុងក្រុម មិនអ៊ីចឹងណ៎ា។ ក្នុងក្រុមមានលោកមាននិយាយព្រឹកមិញជម្រាបតុលាការថា លោកនៅក្នុងក្រុមមួយដែលមាន ១២នាក់។ ក្នុង១២នាក់ហ្នឹង លោកមិនអាចដើរទៅណាបានទេ លោកបញ្ជាក់អ៊ីចឹង។ លោក -- គេដាក់ត្រង់ណានៅត្រង់ហ្នឹង មិនអ៊ីចឹងណ៎ា។ បើអ៊ីចឹង លោកឆ្លើយជម្រាបព្រះរាជអាជ្ញាព្រឹកមិញថា មានតែកងទ័ព កងពលខាងបូព៌ាទេ ដែលបានបាញ់សម្លាប់ប្រជាជននៅក្នុងភ្នំពេញដែលអ្នកណាដែលមិនព្រមចេញ ឬក៏រួញរានឹង -- គេឲ្យភៀសខ្លួនមិនព្រមទៅ។ សម្ដីនេះ ថាតើប្រាកដជាអ៊ីចឹង លោកបានឃើញនឹងភ្នែកទេ ឬក៏លោកឮគេថា?

[១៤:០៤:៥៦]

**ឆ៖** អាហ្នឹង ខ្ញុំឮគេថា កងជាមួយហ្នឹងថា ពួកបូព៌ាហ្នឹងបាញ់ប្រជាជនដើម្បីឲ្យៗចេញពីទីក្រុងភ្នំពេញ។ អាហ្នឹងៗឮគេថាទេ ខ្ញុំវាៗមិនច្បាស់ទេ ប៉ុន្តែជួនណាវាថាលេង បើវានិយាយតែអ៊ីចឹង។

**ស៖** ពេលដែលលោកឮគេថា គឺឮក្នុងកងជាមួយគ្នាហ្នឹង? កង១២នាក់ហ្នឹងថា ឬក៏ឮអ្នកដទៃប្រាប់?

[១៤:០៥:២៧]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំស្ដាប់ -- ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណ៎ា!

**លោក ស៊ុំ ជា៖**

**ឆ៖** បាទ ក្នុងក្រុមទាំងអស់គ្នាហ្នឹង គាត់ហ្នឹងក៏និយាយអ៊ីចឹង។

**សួរដោយលោក សុន អរុណ៖**

**ស៖** អរគុណ។ លោកជាកងយោធាមួយក្រុម១២នាក់ដែរ ហើយកង១២នេះ ក៏គេមិនឲ្យដើរទៅណាដែរ ម៉េចក៏ដឹងៗថា កងខាងបូព៌ាហ្នឹងគេមានបាញ់មនុស្ស ស្លាប់មនុស្ស?

**ឆ៖** ព្រោះអ្នកទៅយាមហ្នឹងបានដឹង។ អ្នកយាមហ្នឹងបាទ គេមកនិយាយប្រាប់ខ្ញុំ។

**ស៖** តាមចម្លើយរបស់លោកពីព្រឹករហូតដល់ឥឡូវ បើតាមខ្ញុំស្ដាប់បាន លោកបាននិយាយជម្រាបតុលាការថា ពេលដែលវាយចូលភ្នំពេញ កងឯកភាពមួយៗតាំងពីថ្នាក់ក្រុមទៅរហូត គឺនៅត្រង់

ណាទៅត្រង់ហ្នឹង មិនអាចដើរបានទេ។ ហើយចុះអ្នកដទៃដែលនិយាយប្រាប់លោកនោះ ម៉េចក៏គេដឹង? សូមលោកជម្រាបតុលាការ ថាហេតុអីបានគេដឹង? គេបានដើរ ឬក៏លោកមិនបានដើរ?

[១៤:០៧:២៣]

**ឆ៖** ពួកទៅចាំយាមហ្នឹង នៅក្នុងក្រុមហ្នឹងគេដឹង គេអ្នកទៅចាំយាមនៅព្រំប្រទល់ផ្សារថ្មីហ្នឹង បានគេដឹង។ គេអ្នកប្រាប់ខ្ញុំហ្នឹង។

**ស៖** បើដូច្នេះមានន័យថា លោកអាចដើរពីពេទ្យកាល់ម៉ែតទៅផ្សារថ្មីបានដែរ អ៊ីចឹង?

**ឆ៖** ដើរអត់បានទេ ដោយពេលគេដូរគ្នាថា បីនាក់ទៅយាមអ៊ីចឹង គេដូរគ្នាមកស៊ីបាយ។ ស៊ីបាយដល់វេនយាមបីៗនាក់ ផ្លាស់ប្តូរគ្នាតាមម៉ោងអ៊ីចឹងទៅ។ ២ម៉ោង ឬ៣ម៉ោង ម្នាក់ៗអ៊ីចឹងទៅ គេដូរគ្នាមក បានប្រាប់ បានដឹង។

**ស៖** អរគុណលោក។ ពីព្រឹករហូតមកដល់ឥឡូវ ខ្ញុំតាមខ្ញុំស្តាប់បាន គឺលោកភាគច្រើនណាស់ដែលលោកនិយាយឈ្មោះ គឿន។ គឿន ហ្នឹងជានរណា?

[១៤:០៨:៥១]

**ឆ៖** គឿន ហ្នឹងពីដើមវរសេនា -- កងធំ។ ដល់ខូចសីលធម៌ទៅធ្លាក់មកនៅយុទ្ធជនវិញ គាត់ហ្នឹងប៊ិានណាស់ ប៊ិានហ្នឹងសម្លាប់មនុស្ស ប៊ិាននឹងអី ប៉ុន្តែឥឡូវគាត់ស្លាប់ហើយ ដោយងាប់បន្តគ្នាអ៊ីចឹងងាប់ហើយ ឈ្មោះ គឿន។

**ស៖** លោកបានជម្រាបតុលាការមួយចំនួនធំពីរឿងឈ្មោះ គឿន ហ្នឹងប្រាប់លោក ពីរឿងគេចាប់ ខាងខ្មែរក្រហមចាប់ពេលដែលចូលមកដល់ភ្នំពេញ ចាប់អ្នកណាធ្វើយោធារបប លន់ នល់ យកសម្លាប់ចោលនៅខាងលិចព្រែកព្នៅ។ អាហ្នឹងបើតាមសម្តីលោកឆ្លើយជម្រាបព្រះរាជអាជ្ញាថា គឿន ហ្នឹងប្រាប់។ ត្រង់ហ្នឹងបានខ្ញុំចង់ដឹងច្បាស់លាស់ថា គឿន ជាអ្នកណា? គឿន ហ្នឹងនៅក្រុមជាមួយលោក ជាអ្នកទទួលខុសត្រូវធំដុំ ឬក៏ថាកូនទាហានដូចលោកអ៊ីចឹង បានជាដឹងរឿងរហូតដល់គេយកទៅសម្លាប់នៅព្រែកព្នៅនោះ?

**ឆ៖** គឿន ហ្នឹង គាត់អ្នកប៊ិាន ពីដើមធ្វើកងធំ ប៉ុន្តែខូច ខុសសីលធម៌ទៅ គេទម្លាក់មកយុទ្ធជនមក។ មិនមែនធ្វើអីធំដុំទេ ប៉ុន្តែគាត់ហ្នឹងអ្នកប៊ិានណាស់ ប៊ិានវ៉ៃមនុស្សប៊ិានវ៉ៃអី។ បាទ ឈ្មោះ គឿន ហ្នឹង។

**ស៖** ខ្ញុំយល់ថា គឿន ហ្នឹងមនុស្សប៊ិាន។ ប៉ុន្តែខ្ញុំគ្រាន់ចង់ដឹងថា ហេតុអីបាន គឿន ហ្នឹងដឹង

រឿងរហូតដល់ទៅគេយកមនុស្ស ជាពិសេសយោធារបស់ លន់ នល់ ហ្នឹងយកទៅសម្លាប់ចោលខាងលិចព្រែកព្នៅ។ រួច គឿន នៅកងជាមួយលោកអ៊ីចឹងមិនអ៊ីចឹង! ហើយបើនៅកងជាមួយលោកគឺ យាមតាំងពីផ្សារថ្មី ទៅដល់គីឡូលេខ៦។ អត់ទៅដល់ព្រែកព្នៅទេ គឿន ហ្នឹងមិនអាចដើរទៅដល់ព្រែកព្នៅទេ។ ហេតុអីបានដឹងថា គេយកទៅសម្លាប់នៅនុំង?

[១៤:១១:២២]

**ផ៖** មួយសាហ្នឹងមួយក្រុមគេឲ្យទៅបីនាក់ មួយក្រុមបីនាក់ ដើម្បីឃោសនារកទាហានមួយសាហ្នឹង។ ដល់អ៊ីចឹងទៅ ដើរទៅបានមីក្រូអីគេស្រែកទៅ ហើយ គឿន ហ្នឹងគេអ្នកសម្លាប់ខ្លួនគេបានខ្ញុំហ៊ាននិយាយ។

**ស៖** ខ្ញុំចង់បញ្ជាក់ម្តងទៀត ថា គឿន ហ្នឹងជាយោធា ដែលគេទម្លាក់ពីថ្នាក់កងវរសេនាតូចអី ឬក៏កងអនុសេនា -- អំមិញលោកមាននិយាយអំមិញហ្នឹង មកដល់នៅកូនទាហានៗដូចលោកដែរ។ ម៉្លោះហើយគេឲ្យនៅត្រង់ណាគឺនៅត្រង់ហ្នឹង អាហ្នឹងខ្ញុំចង់បញ្ជាក់អ៊ីចឹងណ៎ា។ នៅត្រង់ណានៅត្រង់ហ្នឹងប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ហេតុអីបានជា គឿន ហ្នឹងដឹងគេយកទាហាន លន់ នល់ ទៅសម្លាប់ដល់ព្រែកព្នៅ។ នៅឆ្ងាយណាស់ព្រែកព្នៅ ជាង--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចច្រឡំអង្គហេតុរៀបចំ អង្គហេតុឡើងវិញឲ្យបានល្អ រវាង គឿន នៅក្នុងឋានៈជាប្រធានកងវរសេនាតូច ហើយនិង គឿន ខុសសីលធម៌ ត្រូវបានគេដកចេញ។ បញ្ហា គឿន ខុសសីលធម៌ដែលបានគេដកចេញដកឋានៈចេញ ទំនងជាសំណួរមិនសួរទាន់សួរដល់ទេ ហើយតាមឯកសារទំនងជាកើតឡើងក្រោយ នៅក្នុងអំឡុងពេលក្រោយថ្ងៃរំដោះ ១៧ មេសា ៧៥ ហ្នឹងច្រើនខែច្រើនថ្ងៃបានមានហេតុការណ៍នេះ។ ប្រសិនបើលោកច្របាច់បញ្ចូលគ្នា ដោយមិនសួរហេតុផលច្បាស់លាស់ទេ វានឹងកើតឡើងច្របូកច្របល់រវាងអ្នកសួរ និងអ្នកឆ្លើយហើយ។

[១៤:១៣:១១]

ឯកសារដូចជាមិនចង្អុលបង្ហាញអ៊ីចឹងទេ ហើយសំណួរតាំងពីព្រឹកមក គឺមិនមានហេតុផលអ៊ីចឹងទេសូមលោករៀបចំសំណួរឲ្យបាន ក្តាប់ឲ្យបាន សូមសួរឲ្យបានជាក់លាក់ បើមិនអ៊ីចឹងទេគឺនឹងអាចវិលវល់នៅបញ្ហានេះ នៅកន្លែងនេះ ដោយមិនមានផលប្រយោជន៍អ្វីនៅក្នុងការសួរដេញដោលនេះនោះទេ មានអត់មានតម្លៃឲ្យតុលាការគិតថា យកទៅវិភាគពិចារណាជាភស្តុតាងយ៉ាងដូចម្តេចទៅ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានបានណែនាំ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរបន្តសំណួរផ្សេង។ លោកបានចូលនៅក្នុងកងយោធារបស់សម្តេច នរោត្តម សីហនុ តាំងពីឆ្នាំ១៩៧២ លោកពេលដែលលោកវ៉ៃចូលដល់ភ្នំពេញ ពេលហ្នឹងខ្មែរក្រហមឈ្នះពួក លន់ នល់ ពេលហ្នឹងលោកដឹងទេថា សម្តេច នរោត្តម សីហនុ លោកបានចូលរួមមកភ្នំពេញជាមួយគ្នា នៅពេលជាមួយគ្នា ឬក៏ពេលណាទេ លោកអាចឆ្លើយបានទេ?

**ឆ៖** សម្តេច សីហនុ មកក្រោយ។ វ៉ៃដាច់ហើយ បានប៉ុន្មានខែទេ មកក្រោយ។

**ស៖** អរគុណ។ មុនពេលវ៉ៃយកភ្នំពេញមេនៅក្នុងកងមួយៗ ដូចលោកនៅក្នុងកងពលលេខ១ លោកនៅក្រុមមួយដែលមានគ្នា១២នាក់ ពេលមុនវ៉ៃចូលដល់ក្រុងភ្នំពេញ មានថ្នាក់លើហ្នឹង មេរបស់លោកមានបង្គាត់បង្រៀនឲ្យលោករៀបចំខ្លួន និងមុខងារត្រូវធ្វើអីទេ ពេលដែលចូលដល់ភ្នំពេញ?

**ឆ៖** ពីមុនមកគឺ គ្មានបានទេ -- វ៉ៃចូលហើយបានៗប្រាប់ថាឲ្យជម្លៀសប្រជាជនចេញ។ គ្មានបានរៀនសូត្រ ហើយគ្មានបានណែនាំអីទេ។ ដល់វ៉ៃចូលហើយបានថា ធ្វើម៉េចឲ្យប្រជាជនចេញទៅ គ្រាន់តែប៉ុណ្ណឹង។

[១៤:១៧:០៥]

**លោក សុន អរុណ៖**

ខ្ញុំអរគុណលោកសាក្សី។ ខ្ញុំអរគុណលោកប្រធាន។ ខ្ញុំមានសំណួរប៉ុណ្ណេះ សហភាតាខ្ញុំនឹងសួរបន្ត។ សូមអរគុណ។

**លោក ហ្សាស្តេ ប៉ៅ៖**

អរគុណលោក អរុណ ដែលបានផ្តល់វេទិកាឲ្យខ្ញុំ។ ហើយសូមជម្រាបសួរលោក ស៊ុំ ជា។ ខ្ញុំឈ្មោះ ហ្សាស្តេ ប៉ៅ។ ខ្ញុំជាមេធាវីការពារក្តីអន្តរជាតិសម្រាប់លោក នួន ជា។ ខ្ញុំនឹងព្យាយាមនិយាយឲ្យបានយឺត ដើម្បីងាយស្រួលដល់ការបកប្រែ។ ប្រសិនបើសំណួររបស់ខ្ញុំមិនច្បាស់ សូមលោកមេត្តាសួរខ្ញុំ ដើម្បីឲ្យខ្ញុំបញ្ជាក់ឡើងវិញបាន។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** សំណួរទី១របស់ខ្ញុំ គឺទាក់ទងទៅនឹងប្រធានបទ ដែលលោកទើបតែបាននិយាយ គឺនិយាយ

អំពីការទម្លាក់គ្រាប់បែកដោយអាមេរិក។ លោកបានបញ្ជាក់ថា ការទម្លាក់គ្រាប់បែកបង្ខំឲ្យលោកចូលទៅក្នុងចលនា។ ប៉ុន្តែលោកមិនបាននិយាយលម្អិតអំពីការទម្លាក់គ្រាប់បែកនោះទេ។ តើលោកអាចប្រាប់ខ្ញុំបានដែរឬទេ តើលោកខ្លួនលោកផ្ទាល់ហ្នឹង ធ្លាប់ឃើញដោយផ្ទាល់អំពីការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងដើមទសវត្សរ៍ឆ្នាំ៧០ ដែរឬទេ?

[១៤:១៨:៤៧]

**លោក ស៊ុំ ជា៖**

**ឆ៖** អាមេរិកទម្លាក់រន្ទះដូចបាយខុំ កំពង់ចាមអីទម្លាក់គ្មានសល់ទេ។ ផ្ទះសម្បែងអីឆេះខ្ទេចខ្ទីអស់។ សម្ដេចហ្នឹងកើតទ័ពហ្នឹង ដោយសារឆេះ ៗបានកើតទ័ពច្រើនហ្នឹង។

**ស៖** តើលោកធ្លាប់ឃើញការទម្លាក់ត្រឹមតែម្ដង ឬក៏ឃើញការទម្លាក់ច្រើនដងបន្តបន្ទាប់គ្នា?

**ឆ៖** ទម្លាក់រាល់ថ្ងៃ អាបេក៏ឃើញ អាមិកក៏ឃើញ អាស្លាបកាត់ឃើញមួយថ្ងៃៗមិនដឹងទម្លាក់ប៉ុន្មានដង។ ហ្នឹងទម្លាក់គ្រាប់បែក មិនចំពោះខេត្តណាៗទេ។ ខ្ញុំនិយាយតែខេត្តខ្ញុំមួយ កំពង់ចាម។ និយាយតែពីទម្លាក់មួយថ្ងៃៗកប់ព្រលប់។

**ស៖** តើមានសាច់ញាតិរបស់លោក ឬក៏មិត្តភក្តិរបស់លោកណាត្រូវបានស្លាប់នៅក្នុងការទម្លាក់គ្រាប់បែកនោះដែរឬទេ?

**ឆ៖** អត់មានទេ មានតែបងមួយគេយកទៅវៃចោល គាត់ហ្នឹងគ្រាន់ធ្វើទាហាន ១៨ -- ជំនាន់សីហនុ ១៨ខែ ស្រាប់តែមកដល់ផ្ទះវិញរកប្រពន្ធរកអី បានគេយកទៅវៃចោលបាត់។ ហ្នឹងគ្រាន់ទាហានឈប់ហើយយកទៅវៃចោល។ អាហ្នឹងបងបង្កើត និងបងថ្លៃមួយនិងកូនពីរបីនាក់ទៀត។ វៃអស់មួយពូជតែម្ដង អាហ្នឹងបងបង្កើតតែម្ដង។

**ស៖** លោកបានបញ្ជាក់ថា លោកបានឃើញការទម្លាប់គ្រាប់បែកជារៀងរាល់ថ្ងៃ ហើយលោកនិយាយថាជាការទម្លាក់ពង្រាយ តើលោកអាចបញ្ជាក់បានដែរឬទេ អំពីការបំផ្លិចបំផ្លាញ បានន័យថាការបំផ្លិចបំផ្លាញជាផ្នែកសម្ភារៈ ជាអគារ ឬក៏ជាអ្វី។ តើលោកអាចបញ្ជាក់បានទេអំពីការបំផ្លាញបែបនេះ?

[១៤:២១:៣៥]

**ឆ៖** គ្រាន់តែនៅក្នុងឃុំខ្ញុំប្រហែលជា ២០ខ្នងឆេះ គ្រាន់តែទម្លាក់គ្រាប់បែក។ ហើយវត្តអារាមខ្ទេចខ្ទី អាហ្នឹងគ្រាន់ៗតែប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ឃើញវាលស្រែត្រូវបានបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែកនេះដែរឬទេ?

**ឆ៖** បាទ ដែរឃើញ។ ឲ្យព្រៃរាងស្តើងៗទម្លាក់គ្រាប់បែក សុទ្ធតែរណ្តៅ តែឥឡូវគេលុបរណ្តៅអស់ហើយ។

**ស៖** លោកបាននិយាយអំពីបងរបស់លោកដែលត្រូវបានគេយកទៅសម្លាប់ តើលោកអាចប្រាប់បានទេ តាមដែលលោកដឹង តើអ្នកណាជាអ្នកទទួលខុសត្រូវលើការសម្លាប់បងប្រុសលោកនោះ?

**ឆ៖** អត់ដឹងៗពីណាផង ព្រោះខ្ញុំទៅធ្វើទ័ពបាត់ទៅ ស្រាប់តែមកដល់ផ្ទះអស់រលីង។ ខំតស៊ូឯណោះមកដល់ផ្ទះគេរើចោល។ ហើយគេមកឲ្យយើងមកលេងផ្ទះផង អត់ឲ្យមកលេង។ ទ័ពខំរើចង់ងាប់ហ្នឹង អត់ឲ្យមកលេងទេ សួរមើល៍ឲ្យតែទ័ពហៅសួរ បើបានមកលេងផ្ទះម្តង។

[១៤:២៣:៤៤]

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់បន្តនិយាយទៅដល់ពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញ ហើយលោកបានរៀបរាប់ប្រាប់អំពីទីកន្លែងដែលកងពលរបស់លោកកាន់កាប់ គឺពីផ្សារថ្មីទៅទួលគោក រហូតដល់ស្ពានជ្រោយចង្វា ហើយបន្តទៅដល់គីឡូម៉ែត្រលេខ៩។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ប្រសិនបើលោកប្រធានមិន -- ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបង្ហាញនូវផែនទីនៅលើអេក្រង់កុំព្យូទ័រ គឺផែនទីទីក្រុងភ្នំពេញ។ ឯកសារដែលមានលេខ D108/15/1.2 ហើយខ្ញុំឮថា សាក្សីគាត់មាន -- គាត់មិនពូកែក្នុងការអានអក្សរ ប៉ុន្តែយើងអាចនឹងបញ្ជាក់ជាភាសាខ្មែរ។ គឺមានភាសាខ្មែរនៅលើផែនទី ដើម្បីជាការជួយទៅដល់អង្គជំនុំជម្រះក៏ដូចជាសាធារណជន ដើម្បីឲ្យបានមើល ពិនិត្យមើលទៅលើរូបភាព ថាតើយើងកំពុងនិយាយពីតំបន់ណា អីតំបន់ណា។

ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញផែនទីនេះនៅលើអេក្រង់។ ថាតើលោកប្រធានមានការសម្រេចយ៉ាងដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

លោកសាក្សី ខ្ញុំគិតថា លោកឃើញនៅលើអេក្រង់ គឺនិយាយ -- គឺជារូបភាពផែនទី ហើយ

ខ្ញុំក៏មានឯកសារជាក្រដាស ដើម្បីឲ្យសាក្សីគាត់ពិនិត្យមើលឯកសារជាក្រដាស។ លោកប្រធាន តើខ្ញុំអាចប្រគល់ឯកសារជាក្រដាសជូនសាក្សីបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ។

[១៤:២៦:១៩]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមផ្តល់ពេលវេលាមួយនាទីជូនសាក្សី ដើម្បីគាត់ពិនិត្យមើលទៅលើផែនទី។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** សំណួរៗរបស់ខ្ញុំ ដែលចង់សួរលោកនៅពេលនេះ គឺមានលក្ខណៈសាមញ្ញទេ គឺខ្ញុំចង់និយាយអំពីតំបន់ដែលកងពលរបស់លោកបោះទីតាំងឈរជើង។ ខ្ញុំគិតថា ខ្ញុំនឹងសួរបីសំណួរ ដោយសារលោកឃើញអាន។ លោក ស៊ុំ ជា តើទាំងអស់នេះគឺជាតំបន់ដែលលោកត្រូវការពារ គឺតំបន់ដែលកងពលរបស់លោកត្រូវការពារ គឺតំបន់ផ្សារថ្មី ទួលគោក គីឡូម៉ែត្រលេខ៩ និងស្ពានជ្រោយចង្វា។ តើតំបន់ទាំងអស់នេះ គឺជាតំបន់ដែលកងពលរបស់លោក ដែលឈរជើងប្រចាំការ។ តើមែនដែរឬទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** ត្រូវហើយ។

[១៤:២៨:១៤]

**ស៖** ខ្ញុំឃើញថា នៅលើផែនទីត្រង់តំបន់ផ្សារថ្មី បើតាមដែរលោកដឹង តើកងពលរបស់លោកមានមកបោះទីតាំងនៅខាងត្បូងហួសពីតំបន់ផ្សារថ្មីដែរឬទេ?

**ឆ៖** អត់ទេ គេចែកគ្នា។ ចែកតាមកងពល អត់មានទៅជ្រែក ទៅខាងណោះបាន មកខាងណេះបាន អត់ទេ។

**ស៖** ហើយតំបន់មួយទៀត ដែលយើងឃើញនៅក្នុងផែនទីនេះ គឺតំបន់វត្តភ្នំ។ តើកងពលរបស់លោកមានភារកិច្ចការពារនៅតំបន់វត្តភ្នំដែរឬទេ?

**ឆ៖** បាទ មាន។

[១៤:២៩:៣៧]

**ស៖** សូមអរគុណ។ ខ្ញុំនឹងលើកយកប្រធានបទនេះ មកពិភាក្សានៅពេលក្រោយបន្តិចទៀត។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី។ ដូច្នេះសូមអនុញ្ញាតថាដកផែនទីហ្នឹងចេញពីលើអេក្រង់។ លោក ស៊ុំ ជា កាលពីព្រឹកនេះ លោកបានបញ្ជាក់ថា “នៅពេលដែលលោកមកដល់មន្ទីរពេទ្យកាល់ម៉ែត នៅពេលនោះ គឺថាវេជ្ជបណ្ឌិត និងបុគ្គលិកពេទ្យបានបោះបង់អ្នកជំងឺចោលបាត់ទៅហើយ”។ សំណួរទី១ របស់ខ្ញុំគឺថា តើលោកដឹងដែរឬទេថាតើនៅពេលណាដែលវេជ្ជបណ្ឌិត និងបុគ្គលិកពេទ្យនុ៎ងបោះបង់ចោលអ្នកជំងឺ? បានន័យថា ចាកចេញពីអ្នកជំងឺ។

**ឆ៖** បាទ អាថ្ងៃចូលតែម្តង ចូលវ៉ៃហ្នឹង។ ពេទ្យអីបាត់ម្ចាស់ការអស់ រត់ខ្ទេចគ្មានសល់ទេ នៅតែអ្នកជំងឺ និងបងប្អូន។ ពេទ្យបាត់អស់រលីង។

**ស៖** តើលោកមានបានឃើញថា វេជ្ជបណ្ឌិតហ្នឹងគាត់ចាកចេញដោយផ្ទាល់ភ្នែក ឬមួយក៏គាត់ឮ ឬមួយក៏លោកឮអំពីការចាកចេញរបស់វេជ្ជបណ្ឌិតនុ៎ង?

[១៤:៣១:២១]

**ឆ៖** គ្រាន់តែចូលទៅដល់បាត់ បាត់អស់ពេទ្យតែម្តង។ ឃើញដោយខ្លួនឯង ឃើញតែអ្នកជំងឺតែម្តង។ ព្រោះខ្ញុំគេឲ្យៗ ទៅវ៉ៃ អ៊ូ! គេឲ្យទៅយាមត្រង់នុ៎ង។ ប្រជាជនចេះតែចេញទៅ ពួកពេទ្យហ្នឹងបាត់ម្ចាស់ការអស់ហើយ ចេញតែម្តង។

**ស៖** តើលោកដឹងដែរឬទេថា ហេតុអ្វីបានជាវេជ្ជបណ្ឌិត និងបុគ្គលិកពេទ្យនោះ ត្រូវតែចាកចោលបុគ្គលិក ត្រូវតែចាកចោលអ្នកជំងឺ ដោយទុកចោលនៅក្នុងមន្ទីរពេទ្យ? តើមានមូលហេតុអ្វីដែរ?

**ឆ៖** ព្រោះខ្លាចគ្រាប់កាំភ្លើង ខ្លាចស្អីៗនុ៎ង បានរត់ចេញ។ ពេទ្យភ័យដែរ មិនមែនមិនភ័យឯណា។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីអានឲ្យសាក្សីស្តាប់នូវសម្រង់មួយដកចេញពីសៀវភៅកម្ពុជាឆ្នាំ១៩៧៥ ដល់ ១៩៨២ គឺឯកសារដែលមានលេខ D222/1.17 ហើយភាសាខ្មែរមានលេខ -- ភាសាអង់គ្លេស គឺមានលេខ ERN 00396998។ នេះគឺជាសៀវភៅរបស់ ម៉ៃខល វីកឃើរី ហើយឯកសារនេះគឺពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ ហើយខ្ញុំសូមអនុញ្ញាតអានជូនសាក្សីស្តាប់នូវសម្រង់ដែលដកចេញពីសៀវភៅនេះ។

[១៤:៣៣:៣៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំបានកត់សម្គាល់ថា មេធាវីការពារក្ដីគាត់ងើបឈរនៅពេលព្រឹកនេះ ដើម្បីរារាំងខាងព្រះរាជអាជ្ញាមិនឲ្យប្រើប្រាស់នូវចម្លើយ ឬក៏អ្វីដែលដកស្រង់ដោយផ្ទាល់ គឺថាឲ្យសួរតែអ្វីដែលសាក្សីគាត់ដឹង។ ដូច្នេះ គោលជំហររបស់យើងគឺថា ដើម្បីអាចប្រើប្រាស់ឯកសារបែបនេះបាន គួរតែមានការបង្ហាញថា សាក្សីគាត់មានចំណេះដឹង គឺគាត់ដឹង គាត់មានបទពិសោធន៍ ទាក់ទងទៅនឹងឯកសារទាំងអស់នេះ។ លុះត្រាតែមានការបញ្ជាក់បំភ្លឺទាំងអស់នេះបាន។ អានេះគឺជាអ្វីដែលគាត់បានជំទាស់មកខាងព្រះរាជអាជ្ញានៅព្រឹកនេះ។ ដូច្នេះហើយតាមទស្សនៈរបស់យើងទាល់តែគាត់អាចធ្វើដូច្នេះបាន ទើបមានលទ្ធភាពប្រើប្រាស់ឯកសារទាំងអស់នេះ។

[១៤:៣៤:៣៦]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំបានដាក់នូវលក្ខខណ្ឌនេះទៅលើព្រះរាជអាជ្ញា ហើយជំទាស់របស់ខ្ញុំគឺបើសិនជាយើងអានទៅលើប្រតិចារឹកគឺបាននិយាយថា ព្រះរាជអាជ្ញាបានដាក់ជាមូលដ្ឋានមួយ ដោយឲ្យចោទសួរជាសំណួរចំហ។ ប៉ុន្តែព្រះរាជអាជ្ញាមិនធ្វើទេ គាត់អានដោយផ្ទាល់។ ខ្ញុំ ពេលនេះ គឺខ្ញុំសួរជាសំណួរដោយផ្ទាល់។ ខ្ញុំសួរថា ហេតុអ្វីបានជាវេជ្ជបណ្ឌិតគាត់ចាកចេញពីអ្នកជំងឺ ហើយឥឡូវនេះ សាក្សីគាត់ឆ្លើយរួចទៅហើយ ទើបខ្ញុំមកបន្តសួរគាត់អំពីព័ត៌មានដែលខ្ញុំត្រូវដកស្រង់ចេញពីអ្នកនិពន្ធ អំពីប្រទេសកម្ពុជា។ ដូច្នេះ ខ្ញុំធ្វើការចោទសួរអំពីអ្វីដែលសាក្សីគាត់ដឹង។ ដូច្នេះហើយ ខ្ញុំគិតថា វាដូចជាមិនមានអ្វីដែលផ្ទុយនោះទេ។ តាមដែលខ្ញុំដឹង គឺថាតាមដំបូង គឺយើងសួរសំណួរទូលំទូលាយសិន បន្ទាប់មកទើបយើងបញ្ជាក់ទៅលើឯកសារ។ ដូច្នេះ យើងមិនមែនជំទាស់ទៅលើឯកសារ ឬក៏ការដកស្រង់អ្វីនោះឡើយ។ ដូច្នេះ អ្វីដែលចង់បញ្ជាក់ គឺថាមេធាវីការពារក្ដី នួន ជា ចង់បញ្ជាក់ថា យើងគួរតែមានសិទ្ធិប្រើប្រាស់ទៅលើឯកសារទាំងអស់នេះ ដើម្បីឲ្យមានជាគំរូដល់ការប្រើប្រាស់។

ដូច្នេះ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមអនុញ្ញាតអាននូវសម្រង់ដែលដកស្រង់ចេញពីសៀវភៅរបស់លោក ម៉ៃខល វីកឃើរី។

[១៤:៣៦:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចប្រគល់ភារៈជូនទៅលោកចៅក្រម ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ក្នុងការតាំងសំណួរ របៀបក្នុងការតាំងសំណួរចុងក្រោយអម្បាញ់មិញនេះ។ សូមអញ្ជើញលោកចៅក្រម ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះព្យាយាមធ្វើឱ្យមានភាពស៊ីសង្វាក់គ្នារវាងសេចក្តីសម្រេចកាលពីមុនៗ។ យើងមិនឃើញមានផលប្រយោជន៍ណាមួយក្នុងការលើកឡើងនូវសៀវភៅរបស់ ម៉ៃខល វីកឃើរី ដើម្បីយកមកធ្វើមូលដ្ឋាន សម្រាប់សួរសំណួរនោះទេ។ លោកអាចប្រើប្រាស់ខ្លឹមសារព័ត៌មានដែលមាននៅក្នុងសៀវភៅនោះបាន ក៏ប៉ុន្តែយើងត្រូវតែដឹងថា ម៉ៃខល វីកឃើរី គាត់មិនមែនជាសាក្សីរបស់យើងទេ គាត់មិនមានវត្តមាននៅទីភ្នំពេញនោះទេ។ ដូច្នេះខ្ញុំគិតថា មិនមានប្រយោជន៍អ្វីក្នុងការយោងទៅលើសៀវភៅរបស់គាត់នោះទេ។ លោកត្រូវបានអនុញ្ញាតឱ្យសួរសំណួរចំហទៅកាន់សាក្សីដូចជាករណីកាលពីព្រឹកមិញដែរសម្រាប់សហព្រះរាជអាជ្ញា។ ដូច្នេះ មិនមានហេតុផលណាមួយដែលអនុញ្ញាតឱ្យលោកដកស្រង់លម្អិតនូវខ្លឹមសារនៅក្នុងសៀវភៅរបស់ ម៉ៃខល វីកឃើរី នោះឡើយ។

[១៤:៤០:៤៨]

**លោក ហ្សាស្តី ប៉ៅ៖**

សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ ប៉ុន្តែឥឡូវនេះ គឺយើងដាក់ដូចជាច្បាស់លាស់អំពីបទដ្ឋានក្នុងការប្រើប្រាស់ឯកសារ ហើយខ្ញុំដឹងថាលោក ម៉ៃខល វីកឃើរី គាត់អត់នៅទីក្រុងភ្នំពេញទេនៅពេលនោះ។ ប៉ុន្តែដូចគ្នាដែរចំពោះ ដេវីដ ឆេនដ៍ល័រ ឬក៏ ហ្វីលីព ស្សូត ឬក៏សាក្សីដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងត្រូវស្តាប់ ដែលពួកគាត់ទាំងអស់នោះត្រូវចាត់ទុកថាជាសាក្សីដែល សាក្សីជំនាញដែលត្រូវបញ្ជាក់ព័ត៌មាន ថាព័ត៌មានពួកគាត់ត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ នេះគឺជាអ្វីដែលមេធាវីការពារក្តីចង់បញ្ជាក់ គឺយើងចង់បញ្ជាក់ថា តើទស្សនៈរបស់អ្នកជំនាញទាំងអស់នុ៎ង គឺផ្អែកទៅលើអង្គហេតុ ឬមួយក៏ជាព័ត៌មានដែលមិនត្រឹមត្រូវនោះ។

ដូច្នេះហើយយើងមិនយល់ច្បាស់ថា តើអ្នកជំនាញណាមួយដែលយើងអាចប្រើប្រាស់ឯកសារ

របស់គាត់ និងអ្នកជំនាញណាមួយដែលយើងមិនអាចប្រើប្រាស់ឯកសាររបស់គាត់បាន។ ផ្អែកទៅតាមការសម្រេច គឺថាខាង ហ្វីលីព ស្បត ត្រូវបាននិយាយដោយខាងព្រះរាជអាជ្ញា គឺថាព្រះរាជអាជ្ញាដែលមកចូលរួមនៅក្នុងថ្ងៃនេះ គឺនិយាយអំពីលោក ស្នឹត ផងដែរ។ ដូច្នេះ អានេះគឺជាអ្វីដែលភាគីម្ខាងទៀតបានប្រើប្រាស់។ ប៉ុន្តែគោលដៅរបស់យើង ដែលយើងចង់ប្រើប្រាស់នៅពេលនេះ គឺចង់បញ្ជាក់ថាតើការពិតវាយ៉ាងម៉េចដែរ? ហើយថាតើវាមានការបញ្ជាក់យ៉ាងម៉េចទៅលើការពិត?

[១៤:៤២:៣៨]

ខ្ញុំមិនមែនចង់និយាយថា ខ្ញុំជំទាស់ទៅលើអ្វីដែលមិនទាន់មាននោះទេ ប៉ុន្តែយើងចង់បញ្ជាក់ទៅលើព័ត៌មានដែលយើងមាននៅក្នុងសៀវភៅនោះ ដើម្បីផ្ទៀបទៅនឹងអ្វីដែលសាក្សីបានគាត់ -- ដែលគាត់បានដឹង។ ដូច្នេះ អានេះគឺជាអ្វីដែលយើងចង់ស្នើ ហើយយើងចង់ឲ្យអង្គជំនុំជម្រះសម្រេចថាតើអ្នកជំនាញណាដែលយើងប្រើប្រាស់ អ្នកជំនាញណាដែលមិនអាចប្រើប្រាស់ សាក្សីណាដែលអាចប្រើប្រាស់ និងសាក្សីណាដែលមិនអាចប្រើប្រាស់។ ឥឡូវហ្នឹងយើងដូចជាវង្វេងវង្វាន់អស់ហើយ យើងមិនដឹងថាត្រូវរៀបចំដោយរបៀបណានោះទេ។ ដូច្នេះ យើងចង់ឲ្យអង្គជំនុំជម្រះដោះស្រាយឲ្យច្បាស់លាស់អំពីបញ្ហាទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:៤៣:៣១]

**លោក ឌេល លីសាក់៖**

ខ្ញុំមានចំណុចមួយចំនួនដែលខ្ញុំចង់លើកឡើង។ មេធាវីការពារក្តីហាក់ដូចជាមានបញ្ហារហូតជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះ។ គឺថានៅពេលដែលយើង -- គាត់ធ្វើការជំទាស់មកខាងយើង គឺហាក់ដូចជាមិនមានបញ្ហា។ ចំពោះយើងគឺយើងយល់ច្បាស់អំពីបញ្ហាទាំងអស់នេះ។ យើងប្រើប្រាស់សៀវភៅរបស់លោក ហ្វីលីព ស្បត នៅពេលដែលយើងដកស្រង់នូវការសម្ភាសដែលគាត់ធ្វើជាមួយនឹង ភី ភួន នៅពេលដែល ភី ភួន មកផ្តល់សក្ខីកម្ម។ នេះគឺជាស្ថានភាពមួយដែលច្បាស់ ដែលថាព័ត៌មានដែលមាននៅក្នុងសៀវភៅហ្នឹងមិនមែនជាទស្សនៈរបស់ ហ្វីលីព ស្បត ទេ ប៉ុន្តែជាការកត់ត្រាចម្លើយរបស់សាក្សី ដែលបានមកចូលរួម។ នៅមានស្ថានភាពជាច្រើនទៀត ដែលវាមានមូលដ្ឋានស្របច្បាប់ត្រឹមត្រូវ ហើយតុលាការក៏បានបញ្ជាក់យ៉ាងច្បាស់។ ប៉ុន្តែមេធាវីការពារក្តីគាត់ហាក់ដូចជាធ្វើពុត ធ្វើមិន

ដឹង ថាមិនត្រូវប្រឈមជាមួយគំនិត ឬក៏សាកសួរជាមួយទស្សនៈរបស់អ្នកជំនាញទៅវិញ។

ចំពោះផ្នែករបស់លោក វីកឃើរី ផ្នែកសៀវភៅរបស់លោក វីកឃើរី ដែលមេធាវីចង់ប្រើប្រាស់ ប្រសិនបើវាជាការសម្ភាសរបស់សាក្សី ឬមួយក៏សម្ភាសជាមួយនឹងមេទាហានណាមួយនៅក្នុងកងវរសេនាតូចរបស់សាក្សីហ្នឹង យើងមិនជំទាស់នោះទេ។ ព្រោះថា ប្រសិនបើយើងយកព័ត៌មានបែបនេះមកសួរ គឺវាទាក់ទងទៅនឹងការយល់ដឹងរបស់សាក្សី ប៉ុន្តែខ្ញុំគិតថា ប្រហែលជាមិនមែនបែបនេះទេ។ ខ្ញុំគិតថា មេធាវីប្រហែលជាចង់អានទស្សនៈរបស់លោក វីកឃើរី ឬក៏ការសន្និដ្ឋានរបស់ វីកឃើរី ហើយមកសួរសាក្សីទៅវិញ។ ខ្ញុំគិតថា ការនេះជាការមិនត្រឹមត្រូវនោះឡើយ។ ខ្ញុំគិតថា មេធាវីហាក់ដូចជាធ្វើមិនសូវយល់ ឬក៏មិនសូវដឹងច្បាស់អំពីបញ្ហានេះ ធ្វើដូចជាមិនយល់ថាតើហេតុអ្វីបានជាគេមិនឲ្យគាត់ប្រើប្រាស់សៀវភៅរបស់ វីកឃើរី ទៅវិញ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកបន្តសំណួរ។ អង្គជំនុំជម្រះបានសម្រេចរួចហើយ។

**លោក ហ្សាស្តើ ប៉ោ៖**

អរគុណលោកប្រធាន។ ខ្ញុំនឹងបន្តការសួររបស់ខ្ញុំ។

[១៤:៤៦:១១]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក ស៊ុំ ជា លោកបានបញ្ជាក់ថា គឺលោកបញ្ជាក់នៅក្នុងការសម្ភាសជាមួយសហចៅក្រមស៊ើបអង្កេត ដែលថាលោកបានឮអំពីរឿងដែលថា ពួកខាងបូព៌ាគឺជាពួកខ្លាំងក្លានោះ ហើយលោកបានបញ្ជាក់ថា ក្រុម -- ទាហាននៅក្នុងក្រុមរបស់លោក ជាអ្នកប្រាប់អំពីខាងបញ្ហាទាំងអស់នេះ។ តើៗទាហាននៅក្នុងកងរបស់លោកហ្នឹង មានដែលប្រាប់លោកថាតើអាទ័ពបូព៌ាខ្លាំងជាងគេហ្នឹង តើខ្លាំងក្នុងផ្នែកណា ឬក៏ខ្លាំងក្នុងលក្ខណៈបែបណាដែរ? តើលោកអាចប្រាប់បានដែរឬទេ?

**លោក ស៊ុំ ជា៖**

**ឆ៖** បាទ ខ្លាំងត្រង់ជម្លៀសប្រជាជនចេញ។ ធ្វើម៉េចឲ្យប្រជាជនចេញ ខ្លាំងអ៊ីចឹង។

**ស៖** តាមដែលលោកដឹង ក្នុងពេលដែលលោកនៅទីក្រុងភ្នំពេញនោះ តើលោកធ្លាប់ឃើញទ័ពខាងបូព៌ានៅក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** គាត់នៅចាប់ពីផ្សារថ្មីទៅកើតអ៊ីចេះ មកតាមមាត់ទន្លេអ៊ីចេះ អាហ្នឹងខាងបូព៌ា។ ខាងនិរតី

នៅជ្រុង ចំខាងនិរតី។ ហ្នឹងគេចែកព្រំប្រទល់អ៊ីចឹង។ និរតីព័ទ្ធមកដល់ខាងពោធិ៍ចិនតុងឯណោះ។

[១៤:៤៨:១៤]

**ស៖** តើលោកធ្វើបែបណាទើបដឹងអំពីកងពលនានានៅក្នុងទីក្រុងនោះ?

**ឆ៖** ព្រោះចែកទៅតាមភូមិភាគ ភូមិភាគឧត្តរកងពល តារឿង។ ហ្នឹងចែកតាមភូមិភាគនិរតីឯណោះខាងភូមិ -- គេចែកតាមភូមិភាគបានដឹងបាទ។

**ស៖** លោកទើបបញ្ជាក់ថា ខាងទ័ពខាងប៉ូព៌ាគឺ គ្រប់គ្រងទៅលើខាងចាប់ពីផ្សារថ្មីមក។ តើលោកធ្វើយ៉ាងណាទើបដឹងថាទ័ពខាងប៉ូព៌ាហ្នឹង គ្រប់គ្រងទៅលើផ្នែកចាប់ពីផ្សារថ្មីមកនោះ? តើលោកធ្វើយ៉ាងណាទើបដឹងអំពីបញ្ហានេះ?

**ឆ៖** កងគេចែកគ្នា កងពលគេចែកគ្នាមួយចំហៀងផ្សារថ្មីទៅត្បូង អាហ្នឹងគឺខាងប៉ូព៌ា។ មកជ្រុងខាងណេះ ខាងនិរតី។ ខាងណេះគឺខាងឧត្តរ។ ចែកគ្នាអ៊ីចឹង។

[១៤:៥០:១០]

**ស៖** ខ្ញុំសូមសួរលោកទៅលើសំណួរនេះតាមបែបមួយផ្សេងទៀត។ តើលោកធ្លាប់ឃើញទាហានមកពីខាងប៉ូព៌ាដែរឬទេ?

**ឆ៖** អត់ដែលឃើញផង គឺខាងកងៗខ្ញុំគេថា នៅខាងៗត្បូងៗផ្សារថ្មី អាហ្នឹងសុទ្ធតែខាងពួកប៉ូព៌ា អាហ្នឹងខាងត្បូងផ្សារថ្មីមក។

**ស៖** តើលោកដឹងដែរឬទេ ថាទាហានមកពីខាងប៉ូព៌ានោះមានឯកសណ្ឋានដូចទាហានខ្មែរក្រហមដទៃទៀត ឬមួយក៏ពួកទ័ពខាងប៉ូព៌ាហ្នឹងមានឯកសណ្ឋានខុសពីគេ?

**ឆ៖** ដូចតែគ្នា ខោខ្មៅអាខ្មៅប្រដឹប មានស្អី។

[១៤:៥១:៣៧]

**ស៖** លោកបាននិយាយថា ទ័ពខាងលោកក៏បោះទីតាំងនៅជុំវិញវត្តភ្នំផងដែរ។ តើលោកដឹងដែរឬទេថា តើទ័ពប៉ូព៌ាហ្នឹងមានបោះទីតាំងនៅជុំវិញវត្តភ្នំនោះដែរឬទេ?

**ឆ៖** អត់ទេ អាហ្នឹងខាងឧត្តរហើយ ចាប់ពីផ្សារមកតាមមាត់ទន្លេហ្នឹងមកណេះ សុទ្ធតែឧត្តរទាំងអស់។

**លោក ហ្សាស្តេ ប៉ោះ**

លោកប្រធាន ខ្ញុំអាចបន្តការសួរសំណួរទៅមុខ តទៅមុខទៀត ប៉ុន្តែប្រសិនបើមើលតាមនាឡិកា

ខ្ញុំគិតថា តើយើងគួរតែបន្តទៅមុខទៀត ឬមួយក៏សម្រាក?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពេលនេះតទៅរហូតដល់ម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី ដប់នាទី។

សម្រាកចុះ!

[១៤:៥៣:១១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៣ នាទី ដល់ម៉ោង ១៥:១២ នាទី)*

[១៥:១១:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងមុននឹងផ្តល់វេទិកាជូនទៅលោកមេធាវីការពារក្តីលោក នួន ជា ក្នុងការសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះសូមសួរទៅការបែងចែកពេលវេលាយ៉ាងម៉េចដែរ លោកមេធាវី ជាមួយនឹងក្រុមមេធាវីការពារក្តីពីរក្រុមទៀត? លោកមេធាវី ហ្សាស្តេ ប៉ៅ តើការបែងចែកពេលវេលាក្នុងការសួរសាក្សីរូបនេះជាមួយនឹងមេធាវីការពារក្តីពីរក្រុមទៀត យ៉ាងម៉េចដែរ?

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ព័ត៌មានដែលខ្ញុំបានទទួលចុងក្រោយ គឺថាក្រុម អៀង សារី គាត់ត្រូវការពេលមិនលើសពី១០នាទីទេ។ ហើយក្រុម ខៀវ សំផន គឺថាមិនត្រូវការពេលវេលាអីដើម្បីសួរទៅសាក្សីនោះទេ។ ដូច្នេះ ក៏សូមសួរទៅបញ្ជាក់ទៅសហភាគីទាំងអស់ផង តើត្រឹមត្រូវទេ? ខ្ញុំសង្ឃឹម

ថាក្រុមមេធាវីការពារក្តីទាំងអស់អាចនឹងបញ្ចប់ការសួរដេញដោលសាក្សីរូបនេះនៅរសៀលនេះតែម្តង។ សូមអរគុណ។

[១៥:១៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ក្រុមមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ក្រុមយើងខ្ញុំត្រូវការតែ១០នាទីទេ គឺគ្រប់គ្រាន់ហើយ។ បាទ ១០នាទីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្នុងក្រុមរបស់យើងខ្ញុំ អត់មានសំណួរទេបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី ហ្សាស្តេី ប៉ៅ បន្តការតាំងសំណួរដេញដោលចំពោះសាក្សី សូមអញ្ជើញ!

[១៥:១៣:៤៨]

**លោក ហ្សាស្តេី ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** លោក ស៊ុំ ជា ដែលថានៅថ្ងៃនោះបានផ្តល់សក្ខីកម្មហើយ ថាលោកមិនត្រូវបានអនុញ្ញាតឱ្យដើរដោយសេរី ឬក៏ទៅទាក់ទងអ្នកណាផ្សេងទៀតក្រៅពីអ្នកនៅក្នុងអង្គភាពរបស់លោកទេ លោកទទួលបាននូវការណែនាំនេះយ៉ាងតឹងរ៉ឹងបំផុត។ តើលោកដឹងទេថា មានអ្វីអាចកើតឡើងទៅលើកងទ័ពណាដែលចង់ចូលទៅតំបន់ណាមួយ ទីតាំងណាមួយដែលត្រូវកងទ័ពនៅភូមិភាគផ្សេង ដូចជាភូមិភាគបូព៌ា ភូមិភាគនិរតីជាដើម។ តើមានអ្វីកើតឡើង បើប៉ានទៅចូលកាន់ទីតាំង ឬក៏តំបន់របស់គេនោះ?

**លោក ស៊ុំ ជា៖**

**ឆ៖** មួយជំនាន់ហ្នឹង ឲ្យតែប៊ានឆ្លងទៅ ស្រួលមិនស្រួលហ្នឹង ប្រហែសហ្នឹងបាត់ខ្លួនហើយ ខ្មែរៗគ្នាឯងហ្នឹង ពីភូមិភាគមួយទៅភូមិភាគមួយ អត់បានទេ ស្រួលមិនស្រួលបាត់ខ្លួនហើយ។ អ៊ីចឹងបានកងពលហាមផ្ដាច់អត់ឲ្យចូលទេ។

[១៥:១៥:១៤]

**ស៖** តើលោកមានបានដឹងអំពីការវាយប្រហារគ្នា វាយប្រយុទ្ធគ្នារវាងទាហានមកពីភូមិភាគផ្សេងៗគ្នាដែរឬទេ?

**ឆ៖** អត់ទេ។ មិនដែលទាហាន ហើយនិងទាហាន វ៉ៃគ្នា អត់ទេ មិនដែល។

**ស៖** បាទ ខ្ញុំសូមរៀបសំណួរឡើងវិញ។ តើអង្គភាពរបស់លោក ដែលប្រឈមមុខគ្នាជាមួយនឹងកងទ័ពមកពីភូមិភាគផ្សេងៗដែលព្យាយាមចូលមកដល់ទីកន្លែង ឬក៏តំបន់ដែលកងទ័ពរបស់លោកការពារដែរឬទេ?

**ឆ៖** អស់សួរយល់ ម្ដងទៀត។

[១៥:១៦:៣៧]

**ស៖** បាទ យើងខ្ញុំសូមរៀបសំណួរឡើងវិញ។ មុននេះ គឺលោកបានបញ្ជាក់ថា ទាហានដែលឆ្លងចូលទៅកាន់ទីតាំងផ្សេង ឬក៏ទីតាំងរបស់ភូមិភាគផ្សេងអាចនឹងបាត់ខ្លួនតែម្ដង។ សំណួររបស់ខ្ញុំគឺ តើទាហានអង្គភាពរបស់លោកនុ៎ង ដែលពើបប្រទះគ្នា ប្រឈមមុខដាក់គ្នាជាមួយនឹងទាហានខាងភូមិភាគបូព៌ា ឬក៏ភូមិភាគនិរតី ដែលព្យាយាមចូលមកកាន់ទីកន្លែងដែលកងទ័ពរបស់អង្គភាពកងទ័ពរបស់លោកការពារដែរឬទេ?

**ឆ៖** ដូចមិនដែលអីទេ។ អត់ដែលអី បើទំនាស់ -- ប៉ុន្តែពីដើមមកកងពលៗគេហាមគ្នាទេអាហ្នឹង គេមិនឲ្យដើរទាក់ទងគ្នាពីកងមួយទៅកងមួយ ភូមិភាគមួយទៅភូមិភាគមួយ គេហាមមិនឲ្យទៅ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអានន្ទូវសម្រង់មួយជូនសាក្សីស្តាប់ គឺឯកសារ E3/1568 ជាចម្លើយរបស់លោក ហេង សំរិន ដែលផ្តល់ការសម្ភាសទៅដល់អ្នកនិពន្ធ ប៊ែន ឃៀរនិន។ ERN ជាភាសាអង់គ្លេស 00651879, ERN ខ្មែរ 00713947, ជាបារាំង 00743351។ បាទ សូមការអនុញ្ញាតដើម្បីបង្ហាញជូនឯកសារនេះ។

[១៥:១៨:៣១]

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ អង្គជំនុំជម្រះបានសម្រេចម្តងហើយ មិនអនុញ្ញាតឲ្យលើកបទសម្ភាសន៍សាក្សីដកស្រង់យកមកធ្វើជាមូលដ្ឋានក្នុងការសួរទៅសាក្សីមួយទៀតទេ។ តែលោកមេធាវីអាចតាំងសំណួរណាដែលលោកយល់ឃើញថាចាំបាច់ចំពោះសាក្សី នូវបទពិសោធន៍ផ្ទាល់ខ្លួន ដែលគាត់ធ្លាប់ឆ្លងកាត់ ឬក៏ធ្វើការកត់សម្គាល់ដោយខ្លួនឯង ដែលពាក់ព័ន្ធនឹង -- អង្គហេតុដែលពាក់ព័ន្ធទៅនឹងបំណងនៃការសួរ។ រឿងដដែល ហើយលោកលើកមកដដែល អង្គជំនុំជម្រះសម្រេចរួចហើយ។

[១៥:១៩:២១]

**លោក ហ្វាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំយល់ឃើញថា នេះជាស្ថានភាពមួយផ្សេងគ្នា។ នេះមិនមានជាសាក្សីដែលបានស្តាប់យកចម្លើយដោយ ក.ស.ច.ស ទេ។ ហើយឯកសារក៏ដែលខាងអាចនឹងសួរទៅលើសាក្សីនេះបានសួរដោយត្រង់តែម្តងដើម្បី ខ្ញុំប្រើប្រាស់បច្ចេកទេសសួរផ្ទុញទៅលើសាក្សីរូបនេះតែម្តង ដោយប្រើសម្រង់នេះ។ ដូច្នេះ សេចក្តីសម្រេចដែលអង្គជំនុំជម្រះបានសម្រេចហាក់បីដូចជាមិនអនុវត្តបានក្នុងករណីនេះទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយករណីនេះ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២។ លោកអាចរកមើលនូវសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ លើករណីដូចគ្នានេះ តែមួយទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតមិនធ្វើដូច្នេះទេ។ មិនអាចដកស្រង់នូវខ្លឹមសារនៃសក្ខីកម្មចម្លើយសាក្សីណាមួយ យកមកសួរសាក្សីមួយទៀតបានទេ។

[១៥:២០:៣១]

**លោក ហ្វាស្តេ ប៉ោ៖**

ខ្ញុំយល់ឃើញថា កំពុងតែបាត់បង់ឱកាសសាកសួរសាក្សីរូបនេះ។ បញ្ហាដែលខ្ញុំលើកឡើងនេះគឺមិនទាន់បានដោះស្រាយទេ។ ខ្ញុំដឹងថា លោកស្រីចៅក្រម ខាតរ៉ាយថ៍ ក៏បានសម្រេចកាលពីប៉ុន្មានខែមុននេះ ដែលលោកស្រីចៅក្រមឡើងថា "វាជាករណីមួយ -- សូមដក -- ក្នុងការដកសម្រង់សម្តីរបស់សក្ខីកម្មពីសាក្សីណាមួយ ណាមកសួរបានដែរ ឲ្យតែមិនប្រើប្រាស់ ឬក៏បង្ហាញអត្តសញ្ញាណឈ្មោះ

របស់សាក្សីនោះ។ ដោយសារសាក្សីនោះ មិនមែនជាសាក្សីដែលត្រូវបានសួរដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតទេ”។

ដូច្នេះ ចំណុចនេះប្រហែលជាអាចនឹងមានសេចក្តីសម្រេចមួយផ្សេង ដែលអាចយកមកអនុវត្តក្នុងករណីបែបបាន។ ក៏ប៉ុន្តែកាលពីមុន ទាំងសហព្រះរាជអាជ្ញា ក៏ដូចមេធាវីការពារក្តី គឺថាបានប្រើប្រាស់ចម្លើយរបស់សាក្សីយកមកសួរបាន។ ដូច្នេះ សំណួររបស់យើងខ្ញុំ ថាតើការកែប្រែនេះ កែប្រែដោយរបៀបណា? ជាពិសេសសាក្សីរូបនេះ គឺគាត់ឆ្លើយផ្ទុយគ្នាទៅនឹងចម្លើយរបស់លោក ហេង សំរិន។ គឺថាចម្លើយពីរ គឺវាមានការចម្រូងចម្រាសគ្នា មិនស៊ីសង្វាក់គ្នា។ ហេតុដូច្នេះ បានជាយើងខ្ញុំចង់សាកសួរ សួរផ្ទាល់ទៅលើសាក្សីរូបនេះ។

[១៥:២១:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបឆាប់ទេ គឺតុលាការបានសម្រេចហើយ មេធាវីការពារក្តីអាចសួរសំណួរទាក់ទងទៅនឹងប្រភពណាមួយ ដែលមិនអាច -- អ្វីក៏ដោយដែលលោក ហេង សំរិន អាចមានឆ្លើយ ឬក៏មិនឆ្លើយនោះ គឺថាមិនអាចយកមកសួរផ្ទាល់សាក្សីរូបនេះបានទេ។

នេះគឺជាបញ្ហាមួយដែលមិនត្រឹមត្រូវទេ។ តុលាការបានសម្រេចហើយថា មេធាវីការពាក្តីអាចយកខ្លឹមសារ យកមកសាកសួរបាន ក៏ប៉ុន្តែត្រូវតែមានការជាប់ទាក់ទងទៅនឹងសាក្សីនេះផ្ទាល់តែម្តង។ ដូច្នេះ តាមជំហររបស់តំណាងសហព្រះរាជអាជ្ញា ខ្ញុំបានអានប្រតិចារឹក គឺថាបានបញ្ជាក់ហើយថា ការជំទាស់របស់យើងខ្ញុំទៅលើឯកសារនេះ លើកលែងតែខ្លឹមសារយកមកសួរនោះ គឺថាជាប់ទាក់ទងផ្ទាល់ទៅនឹងការយល់ដឹងរបស់សាក្សីរូបនេះ ទៅនឹងអ្វីដែលលោក ហេង សំរិន បានលើកឡើងអំពីបញ្ហាភូមិភាគបូព៌ានោះ។

[១៥:២៣:០៥]

ដូច្នេះ តំណាងសហព្រះរាជអាជ្ញា គឺអាចយល់ស្របទៅនឹងការប្រើប្រាស់ឯកសារនេះ ប៉ុន្តែមេធាវីការពារក្តីលោក នួន ជា កាលដែលយើងគឺថាបានជំទាស់ហើយ យើងបានផ្តល់ឱកាសឲ្យដោះស្រាយបញ្ហានេះ។ ដូច្នេះ យើងខ្ញុំសូមស្នើថា យើងខ្ញុំអាចយកប្រើប្រាស់ឱកាសឯកសារនេះ នៅក្នុងពេល

ណាក៏បាន តើអ៊ីចឹងទេ?

អ៊ីចឹង ជំហររបស់យើងខ្ញុំបានបង្ហាញច្បាស់ហើយថា លោកត្រូវបង្ហាញអំពីទំនាក់ទំនងដោយផ្ទាល់ ទៅនឹងការយល់ដឹងរបស់សាក្សីនេះ។ សូមអរគុណ។

**លោក ហ្សាស្តេី ប៉ោ៖**

ដើម្បីបង្ហាញនូវការជាប់ទាក់ទងគ្នា រវាងឯកសារដែលខ្ញុំចង់បង្ហាញ ដើម្បីបង្ហាញថា សក្ខីកម្មរបស់លោក ហេង សំរិន គឺជាបញ្ហាមួយដែលសាក្សីរូបនេះ ក៏បានផ្តល់សក្ខីកម្មដែរ។ ដូច្នេះ បើសិនណាជាយើងអាចពិភាក្សាគ្នា ដោយមិនមានវត្តមានសាក្សីនេះសិន ក៏បានដែរ។ យើងខ្ញុំសូមលើកឡើងថា ចម្លើយរបស់លោក ហេង សំរិន គឺជាប់ពាក់ព័ន្ធទៅនឹងការឆ្លើយរបស់សាក្សីនេះតែម្តង។ សូមអរគុណ។

[១៥:២៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៦:៥៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហ្សាស្តេី ប៉ោ អង្គជំនុំជម្រះបានសម្រេចកន្លងមករួចហើយ គឺមិនអនុញ្ញាតឲ្យមេធាវីដកស្រង់នូវចម្លើយសាក្សីផ្សេងទៀត យកមកសួរដេញដោលចំពោះសាក្សីមួយផ្សេងទៀតបានទេ។ តែមេធាវីអាចតាំងសំណួរជាទូទៅ ដោយផ្អែកលើខ្លឹមសារដែលខ្លួនយល់ដឹង ដែលឆ្លងកាត់តាមការអាន ការមើលឯកសារនោះរបស់ខ្លួន ធ្វើជាមូលដ្ឋានក្នុងការសួរ។ លោកអាចតាំងសំណួរបាន។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ហើយថា ខ្ញុំមិនអាចដកស្រង់ចម្លើយរបស់លោក ហេង សំរិន មកសួរបានទេ។ ដូច្នេះខ្ញុំសូមបន្តចូលទៅប្រធានបទមួយទៀត ដែលមានការពាក់ព័ន្ធ ហើយខ្ញុំនឹងសូមធ្វើការរៀបចំជាឃ្លាប្រយោគសំណួរឡើងវិញ។ ប្រធានបទថ្មីនេះជាប់មានការពាក់ព័ន្ធ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក ស៊ុំ ជា លោកបានឆ្លើយជូនតុលាការថា ទ័ពមកពីខាងភូមិភាគបូព៌ា គឺខ្លាំងក្លាណាស់ ហើយប្រភពផ្សេងទៀតបានបញ្ជាក់ថា ទ័ពភូមិភាគបូព៌ាជាទូទៅ តែងតែមានវិន័យ អាកប្បកិរិយា និងមានរបៀបរៀបរយច្រើនជាងទ័ពដទៃទៀតទាំងអស់។ តើធ្លាប់ដែល -- ធ្លាប់ឮសួរថាទ័ពខាងបូព៌ាហ្នឹង គឺមានអាកប្បកិរិយា មានឫកពារ ឬក៏ថាមានវិន័យហ្នឹង គឺល្អជាងទ័ពៗមកពីកន្លែងដទៃទៀត។

លោកដែលឮអ៊ីចឹងទេ?

[១៥:២៩:៣១]

**លោក ស៊ុំ ជា៖**

**ឆ៖** កងទ័ពបូព៌ា គឺគេថាខ្លាំងៗនេះ គឺមិនមែនខ្លាំង។ ទ័ពឧត្តរក៏ខ្លាំង ទ័ពនិរតីក៏ខ្លាំង ទ័ពបូព៌ាក៏ខ្លាំងៗក្នុងជម្លៀសប្រជាជនចេញទេ មិនមែនខ្លាំងអារឿងស្អីទេ។ ខ្ញុំនិយាយពីរដងហើយត្រង់ហ្នឹងបាទ។ ខាងៗឧត្តរហ្នឹងគេជម្លៀស គេនិយាយដោយស្រួល គេទៅៗ។ ឯណោះគេខ្លាំង គេថា តែមិនទៅឥឡូវហើយ! ខាងបូព៌ាគេថាអ៊ីចឹង។ អ៊ីចឹងបានខ្ញុំថាខ្លាំងនោះ។ បាទ សូមអស់បាទ។

**ស៖** ប្រហែលជាខ្ញុំយល់ចម្លើយចុងក្រោយរបស់លោកមិនច្បាស់ទេ។ ខ្ញុំសូមសួរសំណួរបន្តទៅទៀត តើលោកយល់ឃើញថា ទ័ពមកភូមិភាគឧត្តរ គឺមិនមានគឺថា ភាពខ្លាំងក្លា ឬក៏កាចយ៉ាងណានោះជាងភូមិភាគបូព៌ា អ៊ីចឹងមែនទេ?

[១៥:៣១:០៦]

**ឆ៖** ស្តាប់អត់យល់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំសំណួរសាឡើងវិញ! ហើយសំណួររបស់លោកមិនគប្បីឲ្យជាសំណួរបំណងឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋានទេ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោកសាក្សី ខ្ញុំសូមរៀបចំសំណួរ ហើយសួរលោកត្រង់ៗតែម្តង។ តើនេះជាការយល់ដឹងរបស់លោកឬ ដែលថាទ័ពមកពីឧត្តរមិនមានភាពកាចសាហាវ ឬក៏ថាមានភាពម៉ឺងម៉ាត់ជាងកងទ័ពបូព៌ាឬក៏យ៉ាងណា?

**លោក ស៊ុំ ជា៖**

**ឆ៖** បាទ ម៉ឺងម៉ាត់ៗ ទន់ភ្លន់ មានសីលធម៌ល្អ។

**ស៖** នៅពេលដែលលោកនិយាយថា កងទ័ពនេះគឺ ម៉ឺងម៉ាត់ សីលធម៌ល្អអីនេះ គឺលោកសំដៅទៅលើកងទ័ពមកពីភូមិភាគឧត្តរ ឬក៏យ៉ាងណា?

**ឆ៖** បាទ។

[១៥:៣៣:០៦]

**សៈ** តើវាត្រឹមត្រូវដែរទេ ដែលថាលោកមិនដែលដើរចូលទៅតំបន់ ដែលគ្រប់គ្រងដោយកងទ័ពមកភូមិភាគបូព៌ាទេ? តើនេះអ៊ីចឹងមែនទេ?

**ឆៈ** បាទ។

**សៈ** តើវាត្រឹមត្រូវទេ ដែលថាអ្វីដែលលោកដឹង អំពីអាកប្បកិរិយា របស់កងទ័ពភូមិភាគបូព៌ា គឺលោកស្តាប់ឮមកពីគេទេ ពីព្រោះលោកថា លោកឮគេនិយាយ តើអ៊ីចឹង ឬក៏យ៉ាងណា?

**ឆៈ** បាទ ត្រឹមត្រូវ។ នៅក្នុងកងខ្ញុំដែលអ្នកនិយាយ។ គេនិយាយប្រាប់។

**សៈ** អ្នកដែល -- តើមានអ្នកណាម្នាក់ដែលប្រាប់លោកថា កងទ័ពបូព៌ា អំពីអាកប្បកិរិយាអត្តចរិតរបស់កងទ័ពបូព៌ាហ្នឹង អ្នកដែលប្រាប់លោកហ្នឹងនៅរស់រានមានជីវិតទេ?

**ឆៈ** គេស្លាប់បាត់ហើយ។

**សៈ** ខ្ញុំសូមចូលទៅប្រធានបទមួយថ្មីទៀត និយាយអំពីការនិយាយតាមមីក្រូហ្វូន។ តាមចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតគឺថា "គេមានប្រើប្រាស់មីក្រូ ដែលគេបានរៀបចំអស់រយៈពេល ៧ថ្ងៃមុននឹងរំដោះទីក្រុងភ្នំពេញ"។ តើត្រឹមត្រូវទេដែលថាគេរៀបចំមីក្រូហ្នឹង ៧ថ្ងៃមុនថ្ងៃរំដោះទីក្រុងភ្នំពេញឯណោះ?

[១៥:៣៥:២៤]

**ឆៈ** ខ្ញុំអត់ដឹងផង នៅក្នុងកងខ្ញុំអី ដូចអត់គ្មានមីក្រូគ្មានអីទេ។ មិនដឹងបានមីក្រូពីណាមកនិយាយ។

**សៈ** បាទ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ខ្ញុំសូមអានចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ERN អង់គ្លេស 00223346, ERN ជាភាសាខ្មែរ 00205058។ សំណួរ "គឺតើគេធ្វើអ្វីទៀតក្រោយពីប្រជាជនចាកចេញពីទីក្រុងភ្នំពេញទៅ? រយៈពេល៧, ៨ថ្ងៃគេបានរៀបចំមីក្រូអំពាវនាវដល់ទាហាន លន់ នល់ អ្នកណាដែលមានតួនាទី ឋានន្តរស័ក្តិប៉ុនណានោះ គឺថាសូមឲ្យវិលមកអង្គភាពដើមវិញ។ ហើយក្នុងនោះក៏មានតាំងពីទាហានមានឋានន្តរស័ក្តិតូចតាចផងដែរ"។ បញ្ចប់ការដកស្រង់។ ដូច្នេះលោកសាក្សី ថាតើគេបានរៀបចំមីក្រូក្នុងរយៈពេល ៧ ឬក៏ ៨ថ្ងៃក្រោយថ្ងៃរំដោះនេះ គឺជាចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតមែនឬទេ? ដែលថាលោកថាគេរៀបចំមីក្រូដើម្បីប្រកាសអំពាវនាវដល់អ្នកទាំងនោះ ៧, ៨ថ្ងៃក្រោយរំដោះនោះ?

[១៥:៣៧:០៤]

**ឆ៖** អាហ្នឹង គឿន អ្នកនិយាយ ដែលថាត្រូវជិះឡានត្រូវទៅឃោសនា ដើម្បីរកចាប់ទាហានហ្នឹង ដើម្បីឃោសនាថាឲ្យអ្នកណាធ្វើការអី ឲ្យមកធ្វើការនៅទីក្រុងភ្នំពេញវិញ។ អាហ្នឹងរបស់ គឿន ដែលនៅក្នុងកងរបស់ខ្ញុំ អ្នកនិយាយប្រាប់ខ្ញុំ។

**ស៖** បាទ ដើម្បីឲ្យកាន់តែច្បាស់ តើខ្លួនលោកផ្ទាល់តែម្ដងធ្លាប់បានឮអំពីការប្រកាស ការអំពាវនាវ ឬក៏ការផ្សាយសំឡេងណាមួយតាមរយៈមីក្រូនេះដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ដូច្នេះ គឺមានន័យថាលោកដឹងដោយសារតែ គឿន ប្រាប់ទៅលោក អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ សូមត្រឡប់ទៅសំណួរដែលខ្ញុំបានសួរលោកហើយ លោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា "មីក្រូនេះគេរៀបចំឡើងបន្ទាប់ពី ៧ ឬក៏៨ថ្ងៃក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញ"។ តើនេះជាចម្លើយត្រឹមត្រូវមែនឬយ៉ាងណា ដែលថាគេបានរៀបចំមីក្រូហ្នឹងដើម្បីអំពាវនាវហ្នឹង គឺ ៧, ៨ថ្ងៃក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** អាហ្នឹងខ្ញុំអត់ដឹងផង មីក្រូតាមឡានហ្នឹង ខ្ញុំក៏អត់ដឹងទេ ឮតែ គឿន ហ្នឹងនិយាយ។ នៅភ្នំពេញហ្នឹងគ្មានឮមីក្រូប្រកាសឲ្យប្រជាជនចេញអី អត់ អត់មានឮសូរប្រកាស គ្រាន់តែប្រាប់តែពួកគេហៅថា "រំដោះ"ៗហ្នឹងថា "ឲ្យប្រជាជនហ្នឹងចេញទៅ"។ គ្រាន់តែថាអ៊ីចឹង ឲ្យចេញឲ្យរហ័សបន្តិច ៤, ៥ថ្ងៃ ចេញឲ្យអស់។ រួចដាក់ក្បាលដាក់អីដូច វាមិនឮៗគេប្រកាសៗមីក្រូផង។ ហើយទៅចាប់ទាហាននៅតាមផ្លូវរហូតទៅដល់ស្គន់ហ្នឹងក៏ ឮគឿន ទេដាក់ក្បាលមីក្រូតាមឡានទៅ ខ្ញុំក៏អត់បានឃើញ។ ប៉ុន្តែប្រកាស ៧, ៨ថ្ងៃហ្នឹង ដូចវាមិនឮមីក្រូតាមទីក្រុងភ្នំពេញ។

[១៥:៤០:០៧]

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ ខ្ញុំយល់ឃើញថាចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត លោកឆ្លើយថា "លោកបានដឹងថា គេមានប្រើមីក្រូ"។ ប៉ុន្តែសំណួរនោះ តើហេតុអ្វីបានជាលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា គេបានប្រើប្រាស់មីក្រូហ្នឹង ៧, ៨ថ្ងៃ ក្រោយថ្ងៃរំដោះហ្នឹង? ព្រោះនេះគឺជាចម្លើយរបស់លោកដែលឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលថាគេបានរៀបចំមីក្រូហ្នឹង ៧, ៨ ថ្ងៃក្រោយមក ក្រោយពីថ្ងៃរំដោះហ្នឹង?

**ឆ៖** បាទ ៧, ៨ ថ្ងៃហ្នឹង គឺឮ គឿន ថាជិះឡានទៅរក រកទៅ រកចាប់ទាហាន ចាប់អីហ្នឹង គាត់ថាដាក់ក្បាលមីក្រូ បាទ។ រឿងថា ក្បាលមីក្រូ ៧, ៨ ថ្ងៃហ្នឹងចាក់នៅទីក្រុងភ្នំពេញ អត់មានផ្សព្វផ្សាយស្អី ឲ្យប្រជាជនចេញអី អត់មានតែ អត់មានឮមីក្រូទេ។ ប៉ុន្តែត្រង់ឡានដាក់មីក្រូផ្សព្វផ្សាយទៅអាហ្នឹងខ្ញុំឮ គឿន ដែលអ្នកនិយាយហ្នឹង។

[១៥:៤១:៣៧]

**ស៖** សូមអរគុណច្រើន គឺច្បាស់ហើយ ចម្លើយរបស់លោកនេះ។ តាមដែលលោកដឹង នៅពេលដែលគេប្រើមីក្រូហ្នឹង ពី ៧, ៨ ថ្ងៃ ក្រោយរំដោះទីក្រុងភ្នំពេញ ថាតើលោកមានដឹងទេ តើនៅតែមានទាហាន លន់ នល់ លាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញដែរឬក៏យ៉ាងណា?

**ឆ៖** ដូចខ្ញុំប្រាប់ពីព្រឹកអីចឹង គ្មានទេ ស្អាតឆិញតែម្តងទីក្រុងភ្នំពេញបាទ។ កុំថាទាហាន ប្រជាជនមួយក៏គ្មានផង។ ៧, ៨ ថ្ងៃនេះគ្មាន គ្មានម្នាក់ រឿងទាហាន រឿងអីលាក់ដូចគ្មាន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំ។ សំណួរ តើលោកធ្លាប់ដែលឮប្រជាជននិយាយអំពីការផ្សាយសំឡេងតាមមីក្រូនេះ តើលោកធ្លាប់ឮប្រជាជននិយាយទេ ២ថ្ងៃមុនថ្ងៃរំដោះទីក្រុងភ្នំពេញមានការផ្សាយតាមមីក្រូ ដែលបង្គាប់បញ្ជាទៅឲ្យទាហាន នាយទាហាន ក៏ដូចជានិស្សិតពេទ្យ និងនៅកន្លែងផ្សេងទៀត គឺទាំងនៅ រួមទាំងនៅស្តាតអូឡាំពិកផង។ តើលោកមានដែលធ្លាប់ឮថាគេមានផ្សាយសំឡេងនៅតាមទីកន្លែងទាំងនេះដែរឬទេ?

**ឆ៖** មួយសាហ្នឹងមានចាក់ចម្រៀង ចាក់ពីមាត់ទន្លេមក មក -- មួយសាហ្នឹងគេចាក់ចម្រៀងបានដូចថា ផ្សាយអីៗ ខ្ញុំអត់ដឹងផង អត់ដឹង។ បើគេ ចម្រៀងគេ ថ្ងៃណាក៏បុណ្យៗមាន។ រាល់តែពេលព្រឹកឡើងចាក់តែអាហ្នឹង។

[១៥:៤៤:០២]

**ស៖** សូមអរគុណ។ ខ្ញុំសង្ឃឹមថា ខ្ញុំមិនបានរំលោភទៅលើសម្រេចរបស់អង្គជំនុំជម្រះទេ។ តែខ្ញុំសូមរៀបចំឃ្លាសំណួររបស់យើងខ្ញុំវិញ តែខ្ញុំ សុំ ក៏សុំការ និងធ្វើតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ លោក ហេង សំរិន បានផ្តល់ចម្លើយថា "កងទ័ពមកពីភូមិភាគបូព៌ាហ្នឹង ហើយតាមចម្លើយរបស់គាត់គឺថាឯកសណ្ឋានរបស់កងទ័ពភូមិភាគបូព៌ាខុសគ្នាពី -- ខាងនោះ គឺថាគាត់ស្លៀកខោអាវពណ៌កាគី ដែលវាខុសពីខាងដទៃទៀត ដែលស្លៀកឯកសណ្ឋានពណ៌ខ្មៅ ដែលកងទពខ្មែរក្រហមស្លៀកខោខ្មៅ អាវខ្មៅ"។ តើលោកធ្លាប់ដែលបានឃើញកងទ័ពនៅក្នុងទីក្រុងភ្នំពេញស្លៀកពាក់ឯកសណ្ឋានខុសគ្នាទេ ដូច

ជាពណ៌កាគី ៗ ឬក៏ពណ៌ក្រឡេក្រឡា ពណ៌ប៉ាក់ដែរឬទេ?

**ឆ៖** បាទ អាហ្នឹងវាហៅថា ចាប់ហួយ រឿងទាហាន បើជំនាន់ដំបូងអាហ្នឹងពាក់ខោអាវខ្មៅ ដល់តែវៃបានបន្ទាយណាមួយៗបានខោអាវហ្នឹងពាក់ ខោអាវហ្នឹង ខោកាគី អាវកាគី គឺជាចម្រុះគ្រប់ តែកងពលអ៊ីចឹង។ ចម្រុះតែម្តង អ្នកណាចង់ស្លៀកអីៗស្លៀកទៅ តែវៃបានពីទាហានស្លៀកតែម្តង។

**ស៖** សូមអរគុណលោកសាក្សី។ ហើយយោងទៅតាមចម្លើយរបស់ ហេង សំរិន នេះផងដែរ កងទ័ពមកពីភូមិភាគបូព៌ា បានកាន់កាប់តំបន់រហូតទៅដល់វត្តភ្នំ ដែលវាផ្ទុយទៅនឹងចម្លើយរបស់លោក ពីខាងដើមថា "កងទ័ពមកពីភូមិភាគឧត្តរកាន់កាប់តំបន់ម្តុំនោះ គឺថាគ្រប់គ្រងនៅតំបន់នោះ"។ តើអាច រំឭកដល់ការចងចាំរបស់លោកដែលថា លោកដែលបានបានឃើញកងទ័ពភូមិភាគបូព៌ានៅម្តុំវត្តភ្នំដែរ ឬទេ?

**ឆ៖** អត់ទេ មិនដែលឃើញសោះតែម្តង ព្រោះប្រធានកងពលទៅនៅក្បែរនុំងទៅហើយ។ តាឿង ហ្នឹង នៅក្បែរនុំង ហើយពួកបូព៌ាអីមកយាមដល់វត្តភ្នំណេះ។ ឥឡូវយើងគួរពិចារណាមើល។ បើកងពលវរសេនាតូច បងហាក់ អីគាត់ថាចែកព្រំប្រទល់គ្នាចាំយាម។

**ស៖** លោកបានឆ្លើយចំណុចនេះខ្លះៗរួចមកហើយ ប៉ុន្តែលោកអាចឆ្លើយបន្ថែមទៀតបានទេ តើ ហាក់ នោះ ប្រាប់លោកថាម៉េច និយាយអំពីការបែងចែកកន្លែងគ្រប់គ្រងនៅក្នុងទីក្រុងភ្នំពេញនេះ?

**ឆ៖** បងហាក់ គ្រាន់តែគាត់ជាវរសេនាតូច មិនមែនកងពលទេ ព្រោះមួយភូមិភាគវាមានប៉ុន្មាន កងពល យើងគិតពិចារណាមើល។ កងពល តាឿង មួយ អាហ្នឹងមួយកងពល។ ហើយមួយកងពល ហ្នឹងកាន់ ប៉ុន្មាននាក់? ប៉ុន្មានកូនទាហាន? ហើយមួយភូមិភាគហ្នឹងខ្ញុំមិនដឹងទេ ប្រហែលពីរបីកងពល នោះមួយភូមិភាគឧត្តរ។ ហើយក៏ខ្ញុំ ក៏ភ្លាប់បាន មិនអស់ដែរ។

[១៥:៤៨:៤១]

**ស៖** តើលោកដឹងទេថា មានភូមិភាគដទៃៗទៀតមានប៉ុន្មានកងពលដែរ?

**ឆ៖** អត់ដឹងផង ប៉ុន្តែយ៉ាងតិចក៏ត្រឹមបីកងពលដែរ។ គ្រាន់តែសន្និដ្ឋាន ស្មានទេ។ ប៉ុន្តែគ្រាន់តែ ស្មាន មួយភូមិភាគៗមិនមែនតិចទេ។ មួយខាង -- គ្រាន់តែឧត្តរមួយក៏មិនស្មើរតែ។ ឧត្តរយ៉ាងតិចគឺ បី ឬបួនកងពល។

**លោក ហ្សាស្តេ ប៉ោះ**

បាទ សូមអរគុណ លោក ស៊ុំ ជា។ ឥឡូវនេះ ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែដើម្បីជាប្រតិចារឹកគឺ

ថា ២សប្តាហ៍មុននោះ គឺថាខ្ញុំបានអះអាងថា លោក ហេង សំរិន គឺជាមេបញ្ជាការកងពលនៅក្នុងពេលរំដោះប្រជាជនចេញពីទីក្រុង -- ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដូច្នេះតាមដែលគាត់និយាយគឺថា គាត់ជាអនុប្រធានរណសិរ្សនៅតំបន់២៥ ហើយក្រោយមកក៏ក្លាយទៅជាកងពលមួយនៃភូមិភាគបូព៌ា។ ដូច្នេះ ជាការត្រឹមត្រូវ ដូចថាគាត់ទៅជាអនុប្រធានកងពល ហើយដល់ពេលរំដោះប្រជាជនចេញពីទីក្រុងភ្នំពេញ គាត់ក្លាយទៅជាៗមេបញ្ជាកងពល និងក្លាយទៅជាសេនាធិការរងនៃភូមិភាគបូព៌ា។ ឯកសារ E3/1568 ERN ជាភាសាខ្មែរ 00713545, ហើយជាភាសាអង់គ្លេស 00651886។ បាទ ខ្ញុំសូមអភ័យទោស ដែលបានលើកនូវចម្លើយដែលលោក ប៉ែន យៀវនិន បានមកសម្អាសនេះ គ្រាន់តែនេះដើម្បីជាបញ្ហានៃប្រតិចារឹក ក៏ប៉ុន្តែយើងខ្ញុំនៅតែសុំស្នើថា សុំឱ្យអង្គជំនុំជម្រះមេត្តាកោះហៅលោក ហេង សំរិន ដើម្បីឱ្យបានយល់អំពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ពាក់ព័ន្ធទៅនឹងទីតាំងដែលគាត់បានកាន់កាប់នៅ១៧ មេសា ៧៥។ គឺទីតាំងដែលខាងភូមិភាគបូព៌ាកាន់កាប់ ដែលគាត់បានឆ្លើយថា "កងទ័ពមិនត្រូវបានអនុញ្ញាតឱ្យដើរចេញពីកន្លែងមួយ ទៅកន្លែងមួយទៀត ពីកន្លែងភូមិភាគមួយកាន់ទៅកន្លែងភូមិភាគមួយកាន់ទៀត"។ ដូចតួយ៉ាង ដូចនិយាយថា "គាត់អាចដើរទៅកាន់ស្ពានទូតបារាំងដើរទៅកាន់ភូមិភាគបូព៌ាទេ"។

យើងខ្ញុំ ក៏ដូចជាសហភាតារបស់ខ្ញុំ លោក សុន អរុណ សូមអរគុណច្រើនលោក ស៊ុំ ជា ហើយខ្ញុំសូមជូនតួនាទីនេះ ទៅលោកមេធាវី ម៉ែខល កាណាវាស។ សូមអរគុណច្រើន។

[១៥:៥១:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ សូមជម្រាបសួរលោកសាក្សី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំ ហើយនិងលោក អាង ឧត្តម គឺជាមេធាវីការពារក្តីឱ្យលោក អៀង សារី ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីធ្វើការសួរលោក ហើយនៅពេលដែលលោកបានឆ្លើយទៅកាន់លោកប្រធាន

"ថាតើលោកមានចម្លើយប៉ុន្មានដែរ" លោកបាននិយាយថា "លោកមានតែមួយ" គឺថាមានការនិយាយយោងឯកសារតែមួយទេ ប៉ុន្តែខ្ញុំចង់ថាតើលោកមានការសម្ភាសលើកទី២ហ្នឹង គឺលើកទី២ហ្នឹង នៅពេលណាដែរ?

[១៥:៥២:៥៥]

**លោក ស៊ុំ ជា៖**

**ឆ៖** ភ្លេចថ្ងៃខែហើយ។

**ស៖** ឥឡូវនេះ យើងពិនិត្យមើលទៅលើបញ្ហានេះទាំងអស់គ្នា។ អ្នកដែលមកសម្ភាសលោកម្តងនោះ គឺថាអត់បានចេញជាកំណត់ត្រាអីនោះទេ។ តើលោកចាំទេ ថាអ្នកមកសម្ភាសលោកម្តង ដែលអត់មានចេញជាកំណត់ត្រាហ្នឹង តើគាត់មកពីខាងណាដែរ?

**ឆ៖** ម្តងមុនហ្នឹង មានឯកសារ តែម្តងក្រោយនោះ គេគ្រាន់តែហៅឲ្យខ្ញុំមក។ បើកណ្តាលគេមានពួកអាមេរិក។ អាមេរិកផ្ទាល់តែម្តង មកសម្ភាសខ្ញុំ។ អាមេរិកហ្នឹង វាចាំមួយកំណាត់ទៅខាងកំពង់ឆ្នាំង។ វាសួរបន្តិច។

**ស៖** អ៊ីចឹង បុគ្គលដែលមកសម្ភាសលើកទី១ហ្នឹង គឺជាបុគ្គលដែលមកសម្ភាសលើកទី២ ដដែលឬមួយក៏យ៉ាងម៉េចដែរ? តើគាត់មកពីអង្គភាពតែមួយ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** មានអង្គភាពណា?

[១៥:៥៤:៣៣]

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោកចាំស្តាប់សំណួរ។ សួរស្តាប់មិនបាន សួរសាជាថ្មីម្តងទៀត។ មេធាវីរបស់លោកសួរនៅពេលណាដែលប្រឹក្សា នៅពេលដែលសំណួរហ្នឹងសួរទម្លាក់កំហុសទៅលើលោកតែប៉ុណ្ណោះ។ មានបញ្ហាអីមិនច្បាស់ លោកអាចសុំឲ្យអ្នកសួរតាំងសំណួរជាថ្មីម្តងទៀត ដើម្បីលោកស្តាប់សំណួរបាន ហើយឆ្លើយតប។

លោកមេធាវីតាំងសំណួរជាថ្មីម្តងទៀត សំណួរចុងក្រោយនេះទំនងសាក្សីភ្លេចសំណួរហើយ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំនឹងសួរសាជាថ្មី លោកសាក្សី។ លោកបានជម្រាបមកយើងថា នៅក្នុងការសម្ភាសលើកទី១ មានមនុស្សមួយចំនួន ដែលថាពួកគាត់ជាជនជាតិអាមេរិកផងដែរ ហើយមកផ្តល់ឯកសារឲ្យលោកមើល ហើយសួរសំណួរដល់លោក។ ខ្ញុំចង់ដឹងថាតើអ្នកសួរហ្នឹង តើជាមនុស្សតែមួយដែលមកសម្ភាសលើកទី២ ទៀត ឬមួយក៏យ៉ាម៉េចដែរ ឬក៏ជាមនុស្សផ្សេងគ្នា?

[១៥:៥៥:៥៤]

**លោក ស៊ុំ ជា៖**

**ឆ៖** មនុស្សផ្សេងគ្នា។

**ស៖** សូមអរគុណ។ ថាតើពួកគាត់មកពីអង្គភាពតែមួយ គឺមកពីអង្គជំនុំជម្រះហ្នឹងមកសម្ភាសលោកនៅកំពង់ឆ្នាំងហ្នឹង ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បើគាត់ថាយកឯកសារពី១ហ្នឹងទៅ យកឯកសារពីហ្នឹងទៅ អាមេរិកគេមកយកឯកសារហ្នឹងទៅដែរ បានស្គាល់ផ្ទះខ្ញុំហ្នឹង។ ប៉ុន្តែខ្ញុំភ្លេចរឿងអង្គភាពគាត់។

**ស៖** តើលោកអាចប្រាប់យើងបានដែរឬទេ ថាតើពួកគាត់ហ្នឹងប្រាប់លោកថាគេជាអ្នកណាដែរ? តើអ្នកដែលទៅសម្ភាសលោកហ្នឹងមានណែនាំខ្លួនថា ពួកគាត់មកពីកន្លែងណា ឬក៏ប្រាប់លោកអំពីគោលដៅនៃការសម្ភាសអ្វីនោះដែរឬទេ?

**ឆ៖** ថាសម្ភាសចេញពីកន្លែងហ្នឹង ទៅសម្ភាសហ្នឹង។ កាត់ទោសខ្មែរក្រហមហ្នឹងគេទៅសម្ភាសម្តងមុនគេហ្នឹង ក្រោយមកបានអាមេរិកាំងទៅ ប៉ុន្តែគេយកឯកសារហ្នឹងទៅដែរ។

[១៥:៥៧:២០]

**ស៖** សូមអរគុណ។ លោកសាក្សីតើលោកអាចជម្រាបដែរទេ ថាការសម្ភាសហ្នឹងវាចំណាយប្រហែលប៉ុន្មានដែរ?

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា ប្រហែលជាមានការជំទាស់ហើយ ដូច្នេះខ្ញុំចង់ស្តាប់នូវការជំទាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ុនណា៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើនីតិវិធី និងបច្ចេកទេស នៅក្នុងការតាំងសំណួររបស់លោក ម៉ៃខល កាណាវាស។ ខ្ញុំយល់ឃើញថា អ្វីដែលគាត់ចោទសួរតាំងពីដើមរហូតមកដល់ពេលនេះ ខ្ញុំយល់ឃើញថាការសួរហ្នឹងគឺសួរក្រៅអង្គហេតុ ដែលបានកំណត់ដោយអង្គជំនុំជម្រះដែលបានកំណត់ថា ត្រូវសួរពាក់ព័ន្ធជាមួយនឹងដីកាដំណោះស្រាយ ក៏ដូចជាសួរទៅលើសំណុំរឿង០០២/០១។ ក៏ប៉ុន្តែលោក កាណាវាស បែរជាសួរទៅលើនីតិវិធីនៅក្នុងការសាកសួរទៅសាក្សីកន្លងមកទៅវិញ។

ដូច្នេះ ខ្ញុំសូមស្នើឲ្យលោក កាណាវាស ធ្វើការប្តូរនីតិវិធី និងបច្ចេកទេសក្នុងការសួរឲ្យពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលបានកំណត់ដោយអង្គជំនុំជម្រះ។ សូមអរគុណ។

[១៥:៥៨:៣៩]

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ដោយសារមានជំទាស់មួយទៀតហើយ។ អញ្ជើញ!

គាត់អង្គុយយូរ សំងំអ៊ីចឹងបានមានគេជំទាស់ ទើបគាត់ជំទាស់ដែរ។ កាលពីគេអត់ជំទាស់គាត់អង្គុយធ្វើមិនដឹងដែរ មិនដឹងយ៉ាងម៉េចបានជាអ៊ីចឹង។

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំសូមនិយាយដោយសង្ខេបទេ។ គោលជំហររបស់យើង គឺថាមេធាវីការពារក្តីគួរតែមានវិសាលភាពដែលបានកម្រិតកំណត់ ដើម្បីចោទសួរទៅលើសំណួរបែបនេះ។ ការជំទាស់របស់ខ្ញុំគឺត្រឹមតែថា មេធាវីគួរតែមានការបញ្ជាក់ឲ្យបានច្បាស់ ព្រោះថាវាហាក់ដូចជាមិនច្បាស់លាស់ថា តើការសម្ភាសទី១ ឬក៏ការសម្ភាសទី២ ដែលបានកត់ត្រា។ ហេតុដូច្នេះខ្ញុំគិតថា សំណួរហ្នឹងវាសួរហាក់ដូចជាធ្វើឲ្យច្របូកច្របល់យ៉ាងខ្លាំង។

[១៥:៥៩:៤៣]

ដូច្នេះគ្រាន់តែស្នើថាឲ្យមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់។ យើងមិនមានការជំទាស់ មិនមានការជំទាស់ទៅលើការចោទសំណួរនោះទេ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំគ្រាន់តែសូមឆ្លៀតឱកាសនេះ សូមឆ្លើយតប។ អ្វីដែលខ្ញុំចង់និយាយនៅពេលនេះ គឺថាដំបូងបំផុត ខ្ញុំសូមឆ្លើយតបទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ជាដំបូងគឺថា លោកប្រធានបានសួរទៅសាក្សី ហើយសាក្សីគាត់បានប្រាប់ថា គាត់បានសួរពីរដង ហើយបន្ទាប់មកខាងព្រះរាជអាជ្ញាងើបឈរឡើងថា មានតែមួយទេ ហើយឯកសារដែលយើងមានហ្នឹងគឺ មានតែមួយនោះទេ។ ហើយក៏ជាសក្ខីកម្មរបស់សាក្សីផងដែរ ពេញមួយក្នុងថ្ងៃនេះៗគឺថា នាំដែលយើងមកដល់ទីនេះបានគឺថា អ្វីដែលគាត់ឮនោះ គ្រាន់តែជាការឮចចាមអារ៉ាមប៉ុណ្ណោះ គឺថាគាត់មានការដឹងផ្ទាល់ខ្លួនតិចតួចប៉ុណ្ណោះ។

[១៦:០០:៣៧]

ដូច្នេះ ហើយខ្ញុំមានសិទ្ធិក្នុងការដេញដោលសួរសាក្សីនេះ ដើម្បីឲ្យដឹងអំពីភាពជឿទុកចិត្តបានរបស់សាក្សីនេះ។ ប្រសិនបើសាក្សីរូបនេះ ត្រូវបានគេចោទសួរដោយក្រុមអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមិនបានកត់ត្រា ដែលមិនមានកំណត់ហេតុស្ដាប់ចម្លើយ ដែលមិនមានឯកសារទាំងអស់ ប៉ុន្តែនៅពេលសម្ភាសនោះ គឺមានការផ្ដល់ឯកសារ ឲ្យឯកសារទៅសាក្សីមើល។ ដូច្នេះហើយការនេះគឺជាការ ហាក់ដូចជាផ្ដល់ឯកសារទៅឲ្យសាក្សី ហាក់ដូចជាបង្រៀនសាក្សីឲ្យដឹងអំពីព័ត៌មាន។ ដូច្នេះ អានេះគឺជាអ្វីដែលគាត់គួរតែនិយាយ។ យើងមិននិយាយអំពីដំណើរការនៃការសម្ភាសនោះទេ។ ខ្ញុំគិតថា តាមប្រព័ន្ធបារាំង គឺវាហាក់ដូចជារញ៉េរញ៉ៃណាស់ ប៉ុន្តែអ្វីដែលយើងចង់និយាយគឺថា នៅក្នុងលក្ខណៈទូទៅ គឺថាការស៊ើបអង្កេត នៅពេលដែលមកជួបសម្ភាសន៍ជាមួយសាក្សីនេះគឺ ហាក់ដូចជាការផ្ដល់ឲ្យមានការប៉ះពាល់ទៅដល់សក្ខីកម្មរបស់គាត់រួចទៅហើយ។

ដូច្នេះហើយខ្ញុំមានសិទ្ធិ ខ្ញុំមានតួនាទីក្នុងការសាកសួរទៅលើសាក្សីនេះ នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីឲ្យដឹងថាតើគាត់សម្ភាសប៉ុន្មានដង។ ហើយខ្ញុំសូមថ្លែងអំណរគុណ ដែលលោកបានចោទសួរសំណួរនេះ ហើយក៏ខ្ញុំសូមថ្លែងអំណរគុណ ចំពោះសាក្សីដែលគាត់មានការស្មោះត្រង់ ក្នុងការប្រាប់ដល់ខ្ញុំនូវចំណុចទាំងអស់នេះ។ ដូច្នេះ គោលដៅសំខាន់របស់ខ្ញុំគឺថា ប្រហែលជាខ្ញុំគិតថា ប្រហែលជាគាត់មានការច្របូកច្របល់បន្តិចបន្តួច ឬក៏ថាតើមិនច្បាស់ ថាតើឯកសារណា ដែលគាត់ដែលបានបង្ហាញចំពោះគាត់។ សូមអរគុណ។

[១៦:០២:១៥]

**ប្រធានអង្គជំនុំ៖**

លោក ម៉ៃខល កាណាវាស តាំងសំណួរសាជាថ្មីម្តងទៀត។ ពីព្រោះដើម្បីជាក់ច្បាស់ ពីព្រោះគោលដៅនៃការតាំងសំណួរ គឺមានគោលបំណងផ្សេងគ្នា។ ភាគីពាក់ព័ន្ធគឺ បានសួរសំណួរពាក់ព័ន្ធនឹងអង្គហេតុ ចំណែកឯលោកសួរគឺ ដើម្បីបញ្ជាក់ពីជំនឿទុកចិត្តលើសាក្សី លើសក្ខីកម្មរបស់សាក្សី។

អង្គជំនុំជម្រះអនុញ្ញាតឲ្យបន្តការសួរ ប៉ុន្តែសូមឲ្យសួរឲ្យបានជាក់ច្បាស់។ ទី១ ម្តងនៅឯណា ទី១ ហ្នឹង ថ្ងៃខែឆ្នាំណា។ ទី២ បើមានទី២ទៀត ធ្វើនៅទីកន្លែងណា នៅថ្ងៃខែឆ្នាំណា។ ទី៣ បើមានទី៣ទៀត តើធ្វើនៅថ្ងៃខែឆ្នាំណា នៅកន្លែងណា ដោយភ្នាក់ងារទៅពីអង្គភាពណាឲ្យបានច្បាស់លាស់ ចៀសវាងការសួរច្របូកច្របល់ ព្រោះសាក្សីមានកម្រិតយល់ដឹងបានប្រាប់ព្រឹកមិញហើយ គឺសាក្សីជាមនុស្សមិនចេះអក្សរទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណចំពោះការណែនាំលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សីឥឡូវនេះ យើងសូមផ្តោតទៅលើការសម្ភាសទាំងពីរ តើលោកចាំដែរឬទេថា តើការសម្ភាសទី១ ឬក៏ការសម្ភាសទី២ ដែលគេថតសំឡេងរបស់លោកដាក់ខ្សែអាត់នោះ?

**លោក ស៊ុំ ជា៖**

**ឆ៖** កាលហ្នឹង ទី១។

**ស៖** សូមអរគុណ។ តើនៅក្នុងការសម្ភាសទី១ ឬក៏ការសម្ភាសទី២ ដែលគេបង្ហាញឯកសារឲ្យលោកមើលនោះ?

**ឆ៖** ទី១។

[១៦:០៤:១៩]

**ស៖** តើគេសម្ភាសលោកហ្នឹង ចំណាយពេលអស់ប្រហែលប៉ុន្មានដែរ ការសម្ភាសលើកទី១ អស់ប៉ុន្មាន? ការសម្ភាសលើកទី២ អស់ប៉ុន្មាន?

**ឆ៖** មួយ ដំបូងគេប្រហែលជាកន្លះម៉ោង។ ឯកសារគេសួរចាប់ពីព្រឹកមកនោះ អានោះឯកសារខ្ញុំហើយនុ៎ង ចាប់អីពីណាៗមក គឺគាត់ឃើញក្នុងនោះ។ ហើយទី២ អាពួកអាមេរិក ប្រហែលជា ១០មីនុតទេ អាមេរិកគេសួររឿងផ្សេង។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ យើងសូមផ្តោតបន្តិចទៅលើសក្ខីកម្មរបស់លោក ដែលបានផ្តល់នៅទីនេះ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចមួយដែលលោកបានលើកឡើងកាលពីមុននេះ តើលោកចាំដែរឬទេថានៅពេលណាឲ្យប្រាកដ ដែលលោកទៅដល់ស្ថានទូតបារាំងបន្ទាប់ពីដួលរលំនៃរបប -- ក្រោយពីការដួលរលំទីក្រុងភ្នំពេញ? តើលោកចាំទេ តើកាលបរិច្ឆេទច្បាស់លាស់ពេលណាដែលលោកទៅដល់ស្ថានទូតបារាំង?

**ឆ៖** ៧៥ វ៉ៃចូលភ្នំពេញគឺ៧៥។ ហើយអង្គភាពខ្ញុំហ្នឹងវានៅៗនុ៎ង។

**ស៖** បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបានហ្នឹង តើក្រោយការរំដោះប៉ុន្មានថ្ងៃដែលលោកទៅប្រចាំការទៅបោះទីតាំងនៅទីនោះ តើនៅថ្ងៃទី១ ថ្ងៃទី២ ឬក៏ថ្ងៃទី៣ ក្រោយរំដោះភ្នំពេញហ្នឹង តើលោកអាចប្រាប់ខ្ញុំបានទេ?

**ឆ៖** ល្ងាក់ថ្ងៃទី៣ បានទៅនៅ។

**ស៖** សូមអរគុណ។ នៅក្នុងសក្ខីកម្មរបស់លោក គឺថានៅថ្ងៃទី៣ គឺថ្ងៃដែលលោកទៅដល់នោះ គឺថាស្ថានទូតបារាំងទាំងមូលហ្នឹង គឺអត់មានមនុស្សអ្វីទាល់តែសោះ។ តើអានេះគឺជាអ្វីដែលលោកចាំតើត្រឹមត្រូវដែរឬទេ?

[១៦:០៦:៣៧]

**ឆ៖** បាទ ត្រូវហើយ។

**ស៖** គឺនៅថ្ងៃទី៣ ដែលលោកទៅដល់ស្ថានទូតនោះ ហើយលោកបានធ្វើការពិនិត្យមើលថា តើមានមនុស្សក៏អត់? អាហ្នឹងគឺជាសក្ខីកម្មដែលលោកបានឆ្លើយនោះ តើមែនដែរឬទេ?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទមួយទៀត គឺលោកបាននិយាយអំពីការសម្លាប់មនុស្ស តើលោកអាចប្រាប់យើងបានដែរឬទេ ថាតើលោកចូលរួមបានប៉ុន្មានដងនៅក្នុងការសម្លាប់ទាហាន លន់ នល់ ដែលបានលើកទង់ជ័យ-ស ឬក៏ដែលបានសុំចុះចាញ់នោះ តើលោកបានចូលរួមប៉ុន្មានដង?

**ឆ៖** អត់បានសម្លាប់មនុស្សអីទេ បានតែ គឿន គេហៅថា គឿន ហ្នឹងអ្នកប៊ានអ្នកអី ដែល គឿន ដែលខ្ញុំនិយាយតាំងពីព្រឹកមកហ្នឹង។ ហើយដាក់ប្រកាសមីក្រូយកមកទាហាន លន់ នល់ ហ្នឹងមកចាញ់បោកពួកហ្នឹង ដោយគេយកមកសម្លាប់នៅព្រែកព្នៅ។ ខ្ញុំឮដោយសារ គឿន ហ្នឹងឯងទេបាទ។

[១៦:០៧:៥៤]

**ស៖** តើលោកឃើញ ការសម្លាប់មនុស្ស គឺការសម្លាប់ទាហាន លន់ នល់ហ្នឹង ឃើញប៉ុន្មានដងដែរ?

**ឆ៖** អត់ដែលឃើញផង ប៉ុន្តែឃើញតែ គឿន ហ្នឹងអ្នកនិយាយប្រាប់បាទ។ គឿន ហ្នឹងគឺអង្គភាពនៅជាមួយខ្ញុំ។

**ស៖** សូមអរគុណ។ អ៊ីចឹងបានន័យថា គឿន អ្នកប្រាប់លោក ប៉ុន្តែលោកអត់ដែលឃើញទេ អានេះគឺជាសក្ខីកម្មដែលលោកចង់ឆ្លើយអ៊ីចឹង តើមែនទេ?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** ដូច្នេះអ្វីដែលភាគច្រើនដែលលោកបានប្រាប់នៅថ្ងៃនេះ គឺជាអ្វីដែលលោកបានឮគេប្រាប់ មិនមែនបានន័យថាលោកបានឃើញដោយផ្ទាល់ ឬក៏លោកបានចូលរួមដោយផ្ទាល់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រូវ។

**ប្រធានអង្គជំនុំ៖**

កុំអាល់ឆ្លើយ! សូមលោកមេធាវី -- លោកតំណាងសហព្រះរាជអាជ្ញា អញ្ជើញ!

[១៦:០៩:១០]

**លោក ឌេល លីសាក់៖**

ការជំទាស់របស់ខ្ញុំ គឺចង់និយាយថាលោក កាណាវាស ហាក់ដូចជានិយាយលើសខ្លាំង ឬក៏ពន្លើសខ្លាំងពេកទាក់ទងទៅនឹងការសម្លាប់ទាហាន លន់ នល់ ឬក៏សម្លាប់អ្វីទាំងអស់។ នេះគឺ -- ដូច្នេះហើយគឺគាត់ហាក់ដូចជាចង់ពង្រីកវិសាលភាពទៅដល់សក្ខីកម្មទាំងអស់របស់សាក្សី គឺគាត់ពង្រីកការឃើញទាហាន លន់ នល់ ត្រូវគេសម្លាប់ ពង្រីកបន្តរហូតទៅដល់សក្ខីកម្មទាំងអស់របស់លោកសាក្សី។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំគិតថាយើងមានការផ្តល់ចម្លើយពីសាក្សីដែលថា គាត់ថា ៣ថ្ងៃក្រោយរំដោះគាត់បានទៅដល់ទួតបារាំង គាត់បានឃើញថាគ្មានមនុស្ស ឃើញថាស្ងាត់ជ្រងំទាំងអស់។ ដូច្នេះហើយ អ្វីៗទាំងអស់ ដែលសាក្សីបានបញ្ជាក់ហ្នឹង គឺវាហាក់បីដូចជាការដែលសាក្សីឮគេនិយាយនោះទេគឺមិនមែនបានចូលរួមរកឃើញដោយផ្ទាល់។ ដូច្នេះដោយសារតែមានបញ្ហាទាំងអស់នេះ ខ្ញុំមិនមានការចាំបាច់ ដើម្បីចោទសួរសាក្សីនេះបន្ថែមទៀតទេ។

ដូច្នេះសូមថ្លែងអំណរគុណចំពោះលោកសាក្សី ហើយសូមថ្លែងអំណរគុណចំពោះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ម៉េចទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន អំមិញថាអត់មានសំណួរទេ ហើយឥឡូវមានអីទេ ចុងក្រោយនេះ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមមេធាវីលោក ខៀវ សំផន អត់មានសំណួរអីទេបាទ។ សូមអរគុណ។

[១៦:១០:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ស៊ុំ ជា ការស្ដាប់សក្ខីកម្មរបស់លោក ដល់ពេលនេះបានចប់ហើយ អង្គជំនុំជម្រះ -- វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏ទីកន្លែងជាគោលដៅដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោក ស៊ុំ ជា ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃកន្លងមកនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចចូលរួមវិភាគទាននៅក្នុងការស្វែងរកការពិតនៃរឿងក្ដីនេះ។ សូមលោក ស៊ុំ ជា ជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងជំនាញក្នុងការបញ្ជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងដែលជាគោលដៅដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងឲ្យជូនដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-89 ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បន្ទប់រង់ចាំ សម្រាប់សាក្សីអ្នកជំនាញដែលនៅជាប់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

បាទ សវនាការថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយសវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-89 ដែលនឹងផ្តើមសួរដេញដោលដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀត។ សូមភាគី និងសាធារណជនជ្រាប។

[១៦:១២:២៨]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយនិងឲ្យនាំខ្លួនគាត់ទាំងពីររូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*